# ការរីកចម្រើននៃដំណើររបស់ពួកបរិសុទ្ធ

*ពីពិភពលោកនេះទៅកាន់ការដែលនឹងត្រូវមក*

**ផ្នែកទី១ [Volume I -2]**



ត្រូវបានសរសេរមកនៅក្រោមភាពស្រដៀងគ្នាទៅនឹងការយល់សប្តិដោយ

លោក John Bunyan

Recommend: White Young Jeon

Translator: Sreyleak Kohn

CRFI

អារម្ភកថា

គោលបំណងដែលខ្ញុំបានអធិស្ឋានសុំអោយព័ន្ធកិច្ចសម្រាប់ការសរសេរនេះនឹងត្រូវបានបង្កើតឡើងនៅក្នុងក្រុមជំនុំក្នុងប្រទេសកម្ពុជាជាយូរយារណាស់មកហើយ ហើយវាត្រូវបានជោគជ័យដោយផែនការណ៍របស់ព្រះ។ ខ្ញុំមានអារម្មណ៍រីករាយដែលបានបោះពុម្ពសៀវភៅចំនួន ៣ ក្បាលក្នុងប្រភេទកំរិតខ្ពស់ ហើយជាផលដំបូងសម្រាប់ការសេរនៃព័ន្ធកិច្ចរបស់ CEMFយើង។ ជាបឋម ខ្ញុំសូមសរសើរតម្កើងដល់ព្រះអម្ចាស់ដោយអស់ពីចិត្តចំពោះការបោះពុម្ពផ្សាយទាំងនេះដែលនិពន្ធដោយ John Bunyan ដែលបានបម្រើព្រះអម្ចាស់ជាគ្រូអធិប្បាយដ៏បរិសុទ្ធនៅឆ្នាំ ១៦៧៨ ទៅជាភាសាខ្មែរសំរាប់បេសកកម្មនៅប្រទេសកម្ពុជា។ នៅក្នុងប្រវត្តិសាស្រ្តពួកជំនុំ សៀវភៅនេះត្រូវបានអានជាសៀវភៅបន្ទាប់ពីបទគម្ពីរ។

ដោយសារភាសាខ្មែរពិបាកខ្លាំងពេក ខ្ញុំមិនហ៊ានធ្វើទេ ប៉ុន្តែព្រះបានរៀបចំក្រុមបកប្រែ CEMF សម្រាប់បេសកកម្មនេះ ហើយទីបំផុតតាមរយៈការលះបង់របស់គេ សៀវភៅនេះត្រូវបានបោះពុម្ពក្នុងឆ្នាំនេះ ក្នុងការរំលឹកខួប ១០០ ឆ្នាំចាប់តាំងពីក្រុមជំនុំកម្ពុជាបានទទួលដំណឹងល្អ ( ១៩២៣) ជាពិសេស កញ្ញា ស្រីល័ក្ខ ខន ដែលបម្រើការងារជាគ្រូបង្រៀនភាសាអង់គ្លេសនៃអនុវិទ្យាល័យ និងជាបុគ្គលិក CEMF ហើយនាងបានបញ្ចប់ការបកប្រែសៀវភៅដោយស៊ូទ្រាំទោះបីគាត់កំពុងសំរាកព្យាបាលរបួសដោយគ្រោះថ្នាក់របស់គាត់ក៏ដោយ។ ខ្ញុំកោតសរសើរនាងចំពោះទឹកចិត្តស្មោះត្រង់របស់នាងដែលស្រឡាញ់ព្រះអម្ចាស់និងដំណឹងល្អ។

ជាទូទៅផ្នែកមួយមានចំនួនច្រើន (៣៦៣ ទំព័រ); ខ្ញុំចែកវាជាបីភាគសម្រាប់ជួយអ្នកអានខ្មែរយើង។ សូមឱ្យព្រះគុណរបស់ព្រះនៅជាមួយពួកគេរហូតទៅ។

នៅក្នុងព្រះគ្រីស្ទ

ថ្ងៃទី ២២ ខែតុលាឆ្នាំ ២០២១

ដោយៈ លោកគ្រូបណ្ឌិត វ៉ាយ យ៉ុងចុន ( ប្រធាន CRFI & CEMF)

Sequence

ជ្រលងភ្នំនៃម្លប់សេចក្ដីស្លាប់ / 6

សាំញ៉ាំ / 18

ការជម្រុញលើកទឹកចិត្តនិងការទស្សទាយន៍របស់អ្នកផ្សាយដំណឹងល្អ / 36

ពិព័រណ៍នៃការឥតប្រយោជន៍ / 41

ការលំបាកវេទនា / 52

លោកដល់ទីបញ្ចប់ / 67

ដេម៉ាស់ / 87

ចូរចងចាំពីប្រពន្ធឡុត / 93

លសម្រាក/ 97

ផ្លូវក្បែរវាលស្មៅ / 101

យក្សនៃកាអស់សង្ឃឹម / 105

ភ្នំដែលគួរគាប់ចិត្ត / 115

## ជ្រលងភ្នំនៃម្លប់សេចក្ដីស្លាប់

ពេលនេះនៅទីបញ្ចប់នៃជ្រលងភ្នំ ដែលមានឈ្មោះថា ជ្រលងភ្នំនៃសេចក្ដីស្លាប់ ដែលគ្រីស្ទានត្រូវដើរកាត់នោះ ពីព្រោះផ្លូវទៅកាន់ទីក្រុងស្ថានសួគ៌ដែលលាតសន្ធឹងនៅកណ្ដាលជ្រលងភ្នំនោះ។ ពេលនេះ ជ្រលងភ្នំនេះជាទីដែលស្ងាត់ជ្រងំ ដែលហោរាយេរេមាបានរៀបរាប់ថា "ទីរហោស្ថាន ជាទឹកដីទីរហោស្ថាននិងរណ្ដៅ ជាទឹកដីដែលមានគ្រោះអត់ឃ្លាន និងជាម្លប់សេចក្ដីស្លាប់ ជាទឹកដីដែលមនុស្ស (មានតែគ្រីស្ទានប៉ុណ្ណោះ) ដែលឆ្លងកាត់តាមនោះ ហើយជាទីដែលគ្មានមនុស្សណារស់នៅសោះ។"

**"គេក៏មិនបានសួរថា ព្រះយេហូវ៉ាដែលនាំយើងរាល់គ្នាឡើងចេញពីស្រុកអេស៊ីបមក ហើយបាននាំយើងដើរកាត់ទីរហោស្ថាន ជាកន្លែងដែលមានសុទ្ធតែវាលខ្សាច់និងជង្ហុក គឺជាទីមានតែដីហួតហែង និងម្លប់នៃសេចក្ដីស្លាប់ទទេ ជាកន្លែងឥតមានមនុស្សដើរកាត់ ឬមនុស្សណាអាស្រ័យនៅឡើយ។ តើទ្រង់នៅឯណា?"      យេរេមា 2:6**

ពេលនេះគ្រីស្ទានកាន់តែលំបាកទៅ លំបាកជាងការវាយជាមួយនឹងអាប៉ូឡេអុងទៅទៀត ជាលទ្ធផលដែលអ្នកនឹងត្រូវជួប។

ខ្ញុំបានឃើញនៅក្នុងសុបិនរបស់ខ្ញុំបន្ទាប់មកថា នៅពេលដែលគ្រីស្ទានបានទៅដល់ព្រំប្រទល់នៃម្លប់សេចក្ដីស្លាប់ នៅទីនោះបានជួបមនុស្សពីរនាក់ ជាកូនៗដែលបាននាំដំណឹងអាក្រក់ពីទឹកដីដែលល្អ ដែលធ្វើឱ្យត្រឡប់ទៅវិញយ៉ាងរហ័ស។

‟អ្នកទាំងនោះក៏បង្កបង្កើតរឿងអាក្រក់ពីស្រុកដែលគេបានសង្កេតមើលនោះ ដោយប្រាប់ដល់ពួកកូនចៅអ៊ីស្រាអែលថា ស្រុកដែលយើងបានដើរកាត់ ហើយសង្កេតមើលនោះ ជាស្រុកដែលបង្ហិនបង្ហោចដល់អ្នកដែលអាស្រ័យនៅ។ ឯមនុស្សដែលយើងឃើញទាំងប៉ុន្មានក៏សុទ្ធតែមានមាឌធំៗ។″ ជនគណនា 13:32

ដែលគ្រីស្ទានបាននិយាយដូច្នេះទៅកាន់ពួកគេ

គ្រីស្ទានៈ តើអ្នកកំពុងទៅណា?

បុរសទាំងពីរៈ ពួកគេបាននិយាយថា "ត្រឡប់ក្រោយៗ ហើយយើងចង់ឱ្យអ្នកធ្វើដូចនេះដែរ ប្រសិនបើជាអ្នកឱ្យរង្វាន់ជាជីវិត ឬជាសេចក្តីសុខសាន្តនោះ។″

គ្រីស្ទានៈ គ្រីស្ទានបាននិយាយថា ‟តើមានបញ្ហាអ្វីទៅ?″

បុរសទាំងពីរៈ ‟បញ្ហា?″ ពួកគេបានពោលថា ‟យើងបានធ្វើដំណើរតាមផ្លូវដែលអ្នកកំពុងទៅដែរ ហើយបានទៅដល់ឆ្ងាយ ហើយតាមពិតទៅយើងទៅជិតផុតក៏ត្រឡប់មកវិញ ដោយសារបើយើងបានទៅឆ្ងាយបន្តិច នោះយើងមិនអាចនឹងយកដំណឹងមកប្រាប់អ្នកនៅទីនេះទេ។″

គ្រីស្ទានៈ តើហេតុអ្វីទៅ គឺយើងស្ទើរតែនៅក្នុងជ្រលងភ្នំនៃម្លប់សេចក្តីស្លាប់ហើយ។

**"ទោះបើទ្រង់បានបំបាក់បំបែកយើងខ្ញុំ នៅទីរបស់ឆ្កែព្រៃ ហើយគ្របយើងខ្ញុំដោយម្លប់នៃសេចក្តីស្លាប់ក៏ដោយ។" ទំនុកដំកើង 44:19**

**"ឯអស់អ្នកដែលអង្គុយនៅទីងងឹត ហើយក្នុងម្លប់នៃសេចក្តីស្លាប់ ជាពួកអ្នកដែលជាប់មានសេចក្តីវេទនា ហើយនឹងចំណងច្រវាក់។" ទំនុកដំកើង 107:10**

ប៉ុន្តែជាការល្អយើងបានមើលទៅខាងមុខយើង ហើយបានឃើញគ្រោះថ្នាក់មុខដែលយើងទៅដល់វា។

គ្រីស្ទាន៖ គ្រីស្ទានបានពោលថា "តើអ្នកបានឃើញអ្វីដែរ?"

បុរសទាំងពីរ៖ ឃើញ! គឺជ្រលងភ្នំនោះ ដែលងងឹតដូចជារណ្តៅ។ នៅទីនោះយើងក៏បានឃើញយមបាល

**បុរសទាំងពីរ៖** បានឃើញ! ដោយជ្រលងភ្នំនោះ ដែលងងឹតដូចជម្រាលភ្នំ។ យើងក៏បានឃើញនៅទីនោះយមបាល សត្វរុយ និងសត្វនាគរណ្តៅ។ យើងក៏បានស្លាប់ឮនៅក្នុងជ្រលងភ្នំនោះនូវសម្លេង ដែលស្រែកថ្ងូរឥតឈប់ឈរដូចប្រជាជនមានទុក្ខវេទនាដែលគ្មាននរណាអាចរស់បាន។ ហើយនៅលើជ្រលងភ្នំនោះមានពពកដ៏គួរឱ្យសង្វេគនៃភាពច្របូកច្របល់។ សេចក្តីស្លាប់ក៏បានត្រដាងស្លាបរបស់វាលើនោះដែរ។ និយាយម៉្យាងវាគួរអោយខ្លាចណាស់ ដោយគ្មានសណ្តាប់ធ្នាប់។

"សូមឱ្យថ្ងៃដែលខ្ញុំកើតមកត្រូវវិនាសទៅ គឺជាយប់ដែលគេប្រកាសថា មានកូនមកចាប់ផ្ទៃនោះ។" យ៉ូប 3:5

"ជាស្ថានដែលងងឹតឈឹងដូចជាយប់ជ្រៅ ជាទីម្លប់នៃសេចក្ដីស្លាប់ ដែលឥតមានរបៀបអ្វី ជាកន្លែងដែលទាំងពន្លឺ ក៏ដូចជាកណ្ដាលអាធ្រាតដែរ។" យ៉ូប 10:22

គ្រីស្ទានៈ បន្ទាប់មកគ្រីស្ទាននិយាយថា "ខ្ញុំមិនទាន់យល់ឃើញនូវឡើយ ដោយអ្វីដែលអ្នកបាននិយាយ តែនោះជាផ្លូវរបស់ខ្ញុំទៅកាន់ស្ថានដែលប្រាថ្នាចង់បាន។"

បុរសទាំងពីរៈ "សុំឱ្យវាជាផ្លូវរបស់អ្នកចុះ យើងនឹងមិនរើសយកវាធ្វើជារបស់យើងឡើយ" ដូច្នេះពួកគេក៏បានចែកផ្លូវទៅ ហើយគ្រីស្ទានបានទៅតាមផ្លូវរបស់គាត់ តែគាត់នៅតែកាន់ដាវនៅជាប់នឹងដៃរបស់គាត់ដដែល ដោយខ្លាចថាគាត់នឹងត្រូវគេធ្វើបាប។

បន្ទាប់មកខ្ញុំបានឃើញសុបិនរបស់ខ្ញុំថា រហូតមកដល់ជ្រលងភ្នំនេះ ដែលខាងស្ដាំដៃនោះមានរណ្ដៅជ្រៅ។ រណ្ដៅនោះគឺជាកន្លែងដែលមនុស្សខ្វាក់បានដឹកនាំមនុស្សខ្វាក់គ្រប់វ័យឱ្យចូលទៅ ហើយបានស្លាប់ទាំងពីរនាក់នៅទីនោះ។ ជាថ្មីម្ដងទៀត មើលខាងឆ្វេងដៃ ក៏មានភក់ដ៏គ្រោះថ្នាក់ ដែលសូម្បីតែមនុស្សល្អដួលដែរ ក៏មិនអាចរកបាតសម្រាប់នឹងជើងរបស់គាត់ឈរបានដែរ។ គ្រានោះស្ដេចដាវីឌក៏បបានដួលម្ដងដែរ។ ហើយគ្មាននរណាម្នាក់

សង្ស័យថាបានបាក់បែកខ្ទេចខ្ទីឡើយ ហើយនឹងមានអ្នកដែលអាចយកគាត់ចេញពីទីនោះបានដែរ ។

**"សូមស្រង់ទូលបង្គំឡើងចេញពីល្បាប់ កុំឱ្យទូលបង្គំផុងចុះទៅឡើយ សូមប្រោសឱ្យទូលបង្គំបានរួចពីពួក ដែលស្អប់ទូលបង្គំ ហើយពីទឹកជ្រៅផង។"**
**ទំនុកដំកើង 69:14**

ផ្លូវនៅទីនេះក៏មានផ្លូវចង្អៀតខ្លាំងផងដែរ ហេតុដូច្នេះហើយគ្រីស្ទានល្អកាន់តែផ្តោតទៅលើវាថែមទៀត។ ព្រោះនៅពេលដែលគាត់បានស្វែងរកនៅទីងងឹត ដើម្បីចៀសវាងពីរណ្តៅនៅដៃម្ខាង គាត់បានត្រៀមខ្លួនរួចហើយដើម្បីបោះចូលទៅក្នុងភក់ដៃម្ខាងទៀត។ នៅពេលដែលគាត់ព្យាយាមភៀសខ្លួនចេញពីភក់ដោយគ្មានការប្រុងប្រយ័ត្នខ្ពស់ នោះគាត់ក៏បានត្រៀមខ្លួនធ្លាក់ចូលប្រឡាយភក់ជាស្រេច។ គាត់បន្តដំណើរទៅមុខទៀត ហើយខ្ញុំបានឮគាត់ស្រែកថ្ងូរយ៉ាងខ្លាំង។ ក្រៅពីគ្រោះថ្នាក់ដូចដែលបានរៀបរាប់ខាងលើ ផ្លូវនៅទីនេះងងឹតយ៉ាងខ្លាំងហើយនៅពេលដែលគាត់លើកជើងឡើងឆ្ពោះទៅមុខ នោះគាត់មិនដឹងថាទីណា ឬនៅលើអ្វី ដែលគាត់គួរដាក់វាបន្ទាប់ទេ។

ប្រហែលជានៅកណ្តាលជ្រលងភ្នំនេះ ខ្ញុំយល់ថាជាមាត់នរក ហើយវាបញ្ឈរនៅផ្លូវនោះយ៉ាងរឹងមាំដែរ។ ឥឡូវនេះគ្រីស្ទានគិតថា តើខ្ញុំត្រូវធ្វើអ្វី? ហើយអណ្តាតភ្លើងនិងផ្សែងនឹងចេញមកយ៉ាងច្រើនសន្ធឹកសន្ធាប់ ដោយមានផ្កាភ្លើងនិងសំលេងរំខាន (អ្វីដែលមិនយកចិត្តទុកដាក់ចំពោះដាវរបស់គ្រីស្ទាន ដូចជាអាប៉ូឡេអុងពីមុនដែរ) ដែលថាគាត់ត្រូវបានគេបង្ខំឱ្យលើកដាវរបស់

គាត់ ហើយយកអាវុធមួយផ្សេងទៀត ដែលគេហៅថា "ការអធិស្ឋានទាំងអស់" ។

**"ព្រមទាំងប្រើសេចក្ដីអធិស្ឋាន និងសេចក្ដីទូលអង្វរគ្រប់យ៉ាង ដើម្បីអធិស្ឋានដោយព្រះវិញ្ញាណរាល់ពេលរាល់វេលា ហើយចាំយាមក្នុងនោះឯង ដោយនូវគ្រប់ទាំងសេចក្ដីខ្ជាប់ខ្ជួន និងសេចក្ដីទូលអង្វរឱ្យពួកបរិសុទ្ធទាំងអស់។" អេភេសូ 6:18**

ដូច្នេះគាត់បានយំនៅត្រចៀករបស់ខ្ញុំថា "ឱព្រះអម្ចាស់អើយ ខ្ញុំសូមអង្វរទ្រង់ឱ្យ រំដោះព្រលឹងរបស់ទូលបង្គំផង!"

**"នោះខ្ញុំបានអំពាវនាវដល់ព្រះនាមព្រះយេហូវ៉ាថា ឱព្រះយេហូវ៉ាអើយ ទូលបង្គំសូមអង្វរដល់ទ្រង់ សូមប្រោសព្រលឹងទូលបង្គំឱ្យរួចផង។" ទំនុកដំកើង 116:4**

ដូច្នេះគាត់បានបន្តដំណើរទៅមុខទៀត ប៉ុន្តែនៅតែមានអណ្ដាតភ្លើងកំពុងឆេះរាលដាលដល់គាត់។ គាត់ក៏បានលឺសំលេងនិងវិលវល់ទៅមក។ ពេលខ្លះគាត់នឹកស្មានថាគាត់នឹងត្រូវបានហែកបំណែកៗ ឬជាន់ឈ្លីដូចភក់ជ្រាំនៅតាមផ្លូវ។ ការមើលឃើញដ៏គួរឱ្យភ័យខ្លាចនេះត្រូវបានបង្ហាញឱ្យឃើញ ហើយសំលេងគួរឱ្យខ្លាចទាំងនេះត្រូវបានស្ដាប់ឮ ដោយគាត់នៅចម្ងាយជាច្រើនម៉ាយល៍ជាមួយគ្នា។ ហើយមកដល់កន្លែងមួយដែលគាត់គិតថា គាត់បានឮសម្លេងពពួកសត្វមួយក្រុមកំពុងតែមករកគាត់ គាត់ក៏ឈប់ ហើយចាប់ផ្ដើមធ្វើអ្វីដែលគាត់ត្រូវធ្វើបំផុត។ ពេលខ្លះគាត់បានគិតថានឹងត្រឡប់ក្រោយវិញ។ បន្ទាប់មកគាត់បានគិតថា គាត់ប្រហែលជាមកដល់ពាក់កណ្ដាលជ្រលងភ្នំហើយ។ គាត់ក៏នឹកឃើញពីរបៀបដែលគាត់បានឆ្លងកាត់គ្រោះ

ថ្នាក់ជាច្រើនរួចទៅហើយហើយគ្រោះថ្នាក់នៃការវិលត្រឡប់អាចមានច្រើន
ជាងការឆ្ពោះទៅមុខ ដូច្នេះគាត់បានសំរេចចិត្តបន្តដំណើរទៅមុខទៀត។
ប៉ុន្តែពួកសត្វនោះមើលទៅដូចជាជិតមកដល់ហើយកាន់តែជិតហើយ។ ប៉ុន្តែ
នៅពេលដែលពួកគេបានមកស្ទើរតែជិតគាត់ហើយនោះ គាត់ក៏បានស្រែក
យំដោយសំលេងយ៉ាងខ្លាំងថា "ខ្ញុំនឹងដើរដោយកម្លាំងរបស់ព្រះជាអម្ចាស់"។
ដូច្នេះពួកវាក៏បានត្រលប់ទៅវិញ ហើយមិនបានមកជិតទៀតឡើយ។

រឿងមួយដែលខ្ញុំនឹងមិនអនុញ្ញាតឱ្យរអិលនោះគឺ ខ្ញុំបានកត់សំគាល់ថាសព្វថ្ងៃនេះគ្រីស្ទានដ៏កំសត់មានអារម្មណ៍ច្របូកច្របល់ណាស់ ដែលគាត់មិនស្គាល់សម្លេងរបស់ខ្លួន។ ដូច្នេះក៏ខ្ញុំដឹងអំពីរឿងនេះ លុះពេលដែលគាត់ទៅដល់មាត់រណ្តៅដែលកំពុងឆេះ មនុស្សម្នាក់នៅក្នុងចំណោមមនុស្សអាក្រក់បានដើរតាមពីក្រោយគាត់ ហើយបោះជំហានមកកាន់គាត់យ៉ាងស្ងាត់ៗ ហើយបានពោលពាក្យប្រមាថព្រះជាម្ចាស់យ៉ាងក្រអឺតក្រទមជាខ្លាំង ដែលលោកស្មានថាបានចេញមកពីគំនិតរបស់លោកផ្ទាល់។ នេះបានធ្វើឱ្យគ្រីស្ទាន រឹតតែពិបាកជាងអ្វីៗទាំងអស់ដែលគាត់បានជួបពីមុន! សូម្បីតែគិតថាគាត់គួរតែប្រមាថដល់ទ្រង់ ដែលគាត់ស្រឡាញ់ខ្លាំងពីមុន! ប៉ុន្តែតើគាត់អាចគេចពីការនោះបានទេ ថាគាត់នឹងមិនធ្វើវាទេ។ ប៉ុន្តែគាត់មិនបានសំរេចចិត្ត ហើយក៏មិនបញ្ឈប់ត្រចៀក ហើយក៏មិនដឹងថាការប្រមាថទាំងនោះមកពីណាដែរ។

នៅពេលគ្រីស្ទានបានធ្វើដំណើរក្នុងសភាពមិនសប្បាយរីករាយអស់ពេលល្មមដែរ គាត់បានគិតថាគាត់បានឮសម្លេងបុរសម្នាក់ ដែលដើរនៅខាងមុខ

គាត់និយាយថា "បើទោះជាខ្ញុំដើរកាត់ជ្រលងនៃស្រមោលសេចក្តីស្លាប់ ខ្ញុំនឹងមិនខ្លាចការអាក្រក់ឡើយ ដោយសារទ្រង់គង់នៅជាមួយខ្ញុំ។"

**"អើ ទោះបើទូលបង្គំដើរកាត់ច្រកភ្នំនៃម្លប់សេចក្តីស្លាប់ក៏ដោយ គង់តែមិនខ្លាចសេចក្តីអាក្រក់ណាឡើយ ដ្បិតទ្រង់គង់នៅជាមួយនឹងទូលបង្គំ ព្រនង់ហើយនឹងដំបងរបស់ទ្រង់កំសាន្តចិត្តទូលបង្គំ។" ទំនុកដំកើង 23:4**

បន្ទាប់មកគាត់ក៏រីករាយ ហើយដោយហេតុផលនោះក៏

ទីមួយ ដោយសារគាត់បានប្រមូលពីពេលនោះមកថា មនុស្សដែលកោតខ្លាចដល់ព្រះបាននៅក្នុងជ្រលងភ្នំនេះដូចជាខ្លួនគាត់ដែរ។

ទីពីរ ដោយការនោះគាត់បានយល់ឃើញថា ព្រះបានគង់នៅជាមួយពួកគេបើទោះជានៅក្នុងសភាពដែលងងឹតនិងវេទនាបែបនោះក៏ដោយ ហើយហេតុអ្វីបានជាមិនមែនខ្ញុំដែរនោះ។ គាត់បានគិតថា បើទោះដោយសារសេចក្តីកំសោយដែលនៅកន្លែងនោះក៏ដោយ តើខ្ញុំមិនអាចដឹងការនោះទេឬអី?

**"មើល ទ្រង់យាងកាត់មុខខ្ញុំ តែខ្ញុំមិនឃើញទេ ទ្រង់ក៏យាងហួសទៅ តែខ្ញុំមិនដឹងសោះ។" យ៉ូប 9:11**

ទីបី ដោយការនោះគាត់សង្ឃឹមថា (គាត់អាចវ៉ាដាច់ពួកគេ) ដើម្បីមានគ្នាទៅ។ ដូច្នេះគាត់ក៏បន្តហៅអ្នកដែលនៅពីមុន។ ប៉ុន្តែគាត់មិនដឹងថាត្រូវឆ្លើយ

យ៉ាងណាទេ ពីព្រោះគាត់ក៏បានគិតតែខ្លួនគាត់តែម្នាក់ឯងដែរ។នោះពេលថ្ងៃក៏មកដល់ បន្ទាប់មកគ្រីស្ទានបាននិយាយថា "ទ្រង់បានប្រែស្រមោលនៃសេចក្តីស្លាប់ទៅជាពេលព្រឹកព្រលឹមហើយ"។

**"ចូរស្វែងរកព្រះដែលទ្រង់បានបង្កើតផ្កាយកូនមាន់ និងផ្កាយនាយព្រាន ក៏ធ្វើឱ្យម្លប់នៃសេចក្តីស្លាប់ប្រែរជាព្រលឹមស្រាង ហើយឱ្យថ្ងៃត្រឡប់ជាយប់វិញ ព្រមទាំងហៅទឹកសមុទ្រមក រួចចាក់ទៅលើផែនដី។ ព្រះនាមទ្រង់គឺព្រះយេហូវ៉ា។" អេម៉ុស 5:8**

ឥឡូវនេះ ពេលព្រឹកកំពុងតែខិតមកដល់ គាត់បានក្រឡេកមើលទៅក្រោយវិញ។ មិនមានបំណងចង់ត្រឡប់មកវិញទេ ប៉ុន្តែដើម្បីមើលឃើញដោយពន្លឺថ្ងៃ តើគ្រោះថ្នាក់អ្វីដែលគាត់បានឆ្លងកាត់ក្នុងភាពងងឹត។ ដូច្នេះគាត់បានឃើញស្នាមជង្ហុក ដែលនៅជាប់នឹងនៅម្ខាង និងអណ្តូងដែលនៅម្ខាងទៀត។ ហើយផ្លូវដែលតូចចង្អៀតដែលនៅចន្លោះទាំងពីរនោះ។ ឥឡូវនេះគាត់បានឃើញយមបាល និង វិញ្ញាណ និងនាគនៃរណ្តៅនោះ ប៉ុន្តែនៅឆ្ងាយពីគ្នានោះ ព្រោះពេលជិតភ្លឺ ពួកវាមិនបានចូលមកជិតទេ។ គេបានរកព្រះអង្គឃើញដូចមានចែងទុកក្នុងគម្ពីរថា "ព្រះអង្គឈ្វេងយល់អ្វីៗដែលស្ថិតនៅក្នុងទីងងឹត ហើយព្រះអង្គក៏ចាំងពន្លឺលើស្រមោលនៃសេចក្តីស្លាប់។"

**"ទ្រង់បើកអស់ទាំងសេចក្តីជ្រៅជ្រះចេញពីងងឹតមក ក៏នាំយកម្លប់សេចក្តីស្លាប់ចេញមកដាក់នៅពន្លឺដែរ។" យ៉ូប 12:22**

ឥឡូវនេះ គ្រីស្ទានមានការប៉ះពាល់យ៉ាងខ្លាំងទៅនឹងសេចក្តីប្រោសលោះរបស់គាត់ ពីគ្រោះថ្នាក់ទាំងអស់នៃផ្លូវតែម្នាក់ឯងរបស់គាត់។ គ្រោះថ្នាក់នេះ ទោះបីគាត់ខ្លាចវាច្រើនជាងមុនក៏ដោយ ក៏គាត់បានឃើញពួកគេកាន់តែ

ច្បាស់ដែរ ដោយសារពន្លឺនៃថ្ងៃបានធ្វើឱ្យពួកគេលេចច្បាស់មកដល់គាត់ ប្រហែលជាពេលនេះព្រះអាទិត្យរះហើយ - នេះជាសេចក្តីមេត្តាករុណាមួយទៀតចំពោះគ្រីស្ទាន។ អ្នកត្រូវកត់សំគាល់ថា ទោះបីផ្នែកទីមួយនៃជ្រលងភ្នំនៃម្លប់សេចក្តីស្លាប់ គឺមានគ្រោះថ្នាក់ក៏ដោយ ផ្នែកទីពីរនេះដែលគាត់មិនទាន់ត្រូវទៅក៏ដោយ បើអាចធ្វើបាន វានឹងមានគ្រោះថ្នាក់ច្រើនជាងនេះទៅទៀត។ ពីកន្លែងដែលគាត់ឈរឥឡូវនេះ សូម្បីតែនៅចុងជ្រលងភ្នំក៏ដោយក៏ផ្លូវបានដាក់ពេញដោយអន្ទាក់ អន្ទាក់ជុង និងអួននៅទីនេះ។ វាដូចជាពេលដែលគាត់បានមកដល់ផ្នែកដំបូងនៃផ្លូវ គាត់មានព្រលឹងមួយពាន់ ដោយហេតុដែលពួកគេត្រូវបានគេដេញចោល។ ប៉ុន្តែដូចដែលខ្ញុំបាននិយាយនៅពេលនេះ ព្រះអាទិត្យកំពុងរះ។ បន្ទាប់មកគាត់និយាយថា "ទៀនរបស់គាត់ភ្លឺលើក្បាលខ្ញុំហើយដោយពន្លឺរបស់ទ្រង់ខ្ញុំនឹងឆ្លងកាត់ភាពងងឹត"។

**"គឺកាលចង្កៀងនៃទ្រង់បានភ្លឺមកលើក្បាលខ្ញុំ ហើយខ្ញុំបានដើរកាត់ទីងងឹត ដោយសារពន្លឺទ្រង់។" យ៉ូប 29:3**

ដូច្នេះដោយសារពន្លឺនេះ គាត់បានទៅដល់ទីបំផុតនៃជ្រលងភ្នំ។ ឥឡូវនេះ ខ្ញុំបានឃើញនៅក្នុងក្តីសុបិន្តរបស់ខ្ញុំថា នៅចុងបញ្ចប់នៃជ្រលងភ្នំនេះមាន ឈាម ឆ្អឹង ផេះនិងសាកសពមនុស្សនៅលាយឡំគ្នា ទាំងអ្នកធ្វើធម្មយាត្រាដែលបានទៅតាមផ្លូវនេះពីមុនផង ហើយខណៈពេលដែលខ្ញុំកំពុងស្វែងរកអ្វីដែលគួរតែជាហេតុផលនោះ។ ខ្ញុំបានឃើញនៅពីមុខខ្ញុំបន្តិចជារូងភ្នំ ដែលមានយក្សពីរ គឺសម្តេចពោប និងអ្នកកាន់សាសនា ដែលបានរស់នៅក្នុងសម័យចាស់ ដោយសាអំណាចនិងភាពផ្តាច់ការរបស់ពួកគេ ដែលធ្វើឱ្យមាន ឆ្អឹង ឈាម ផេះជាដើមរបស់មនុស្សដែលនៅទីនោះ ដែលត្រូវបានគេ

សម្លាប់យ៉ាងសាហាវ។ ប៉ុន្តែនៅកន្លែងនេះគ្រីស្ទានបានទៅដោយគ្មានគ្រោះថ្នាក់អ្វីឡើយ ហើយដែលខ្ញុំបានឆ្ងល់ខ្លះដែរ។ ប៉ុន្តែខ្ញុំបានដឹងចាប់តាំងពីសម្តេចពោបបានស្លាប់អស់ជាយូរថ្ងៃហើយ ហើយសម្រាប់ម្នាក់ផ្សេងទៀតទោះបីជាគាត់នៅរស់ក៏ដោយ ដោយសារអាយុហើយនឹងច្រាស់ដ៏មុតរបស់គាត់ ដែលគាត់បានជួបនៅពេលនៅក្មេង គាត់បានទៅជាឆ្កួតនិងស្ពឹកសន្លាក់ ដែលពេលនេះគាត់ធ្វើអ្វីមិនច្រើនជាជាងការអង្គុយនៅមាត់រូងភ្នំកំពុងញញឹមដាក់អ្នកធ្វើធម្មយាត្រា នៅពេលពួកគេដើរកាត់នោះ ហើយខាំក្រចករបស់គាត់ ពីព្រោះគាត់មិនអាចមករកពួកគេបាន។

ដូច្នេះខ្ញុំបានឃើញគ្រីស្ទានបានបន្តដំណើរទៅមុខទៀត។ នៅចំពោះមុខបុរសចំណាស់ដែលអង្គុយនៅមាត់រូងគាត់មិនអាចប្រាប់ពីអ្វីដែលត្រូវគិតនោះទេ ជាពិសេសនោះទេព្រោះគាត់បាននិយាយជាមួយគាត់ ទោះបីគាត់មិនអាចទៅតាមគាត់បានក៏ដោយ បាននិយាយថា "អ្នកនឹងមិនទៅណាឡើយ រហូតទាល់តែអ្នកច្រើនទៀតត្រូវបានដុត។" ប៉ុន្តែលោកបានរក្សាភាពស្ងប់ស្ងៀម ហើយបានដាក់ទឹកមុខយ៉ាងល្អវិញ។ ហើយដូច្នេះបានឆ្លងកាត់ទៅនិងមិនបានទទួលការឈឺចាប់ឡើយ។ បន្ទាប់មកគ្រីស្ទានបានច្រៀងចំរៀង

"ឱ ពិភពលោកនៃភាពអស្ចារ្យអើយ! ខ្ញុំមិនអាចនិយាយតិចជាងនេះទេ ថាខ្ញុំនឹងត្រូវបានរក្សានៅក្នុងសេចក្តីទុក្ខព្រួយ ដែលខ្ញុំបានជួបនៅទីនេះ! ឱ មានពរហើយដៃដែលបានរំដោះខ្ញុំពីការនោះ ពីគ្រោះថ្នាក់ដែលនៅក្នុងទីងងឹតអារក្ស នរក និងអំពើបាប ដែលបានមកកាន់ខ្ញុំកាលដែលខ្ញុំនៅក្នុងនោះ។ ពិតណាស់ អន្ទាក់ និងរណ្តៅ និង អន្ទាក់ និងសំណាញ់ ដែលនៅតាមផ្លូវ

របស់ខ្ញុំ ដែលខ្ញុំអាចនឹងត្រូវជាប់ដោយភាពល្ងង់ខ្លៅ ដែលចងរឹត និងទម្លាក់ចុះទៅ តែកាលដែលខ្ញុំនៅរស់ សូមឱ្យព្រះយេស៊ូវបានពាក់មកុដចុះ!”

# សាំញ៉ាំ

លើសពីនោះទៀត ខ្ញុំបានឃើញនៅក្នុងសុបិនរបស់ខ្ញុំថា ពេលដែលគេបន្ត ដំណើរទៅ នោះស្មោះត្រង់គាប់ជួនក៏បានមើលទៅម្ខាង ក៏បានឃើញបុរសម្នាក់ឈ្មោះថា សាំញ៉ាំ ដែលកំពុងដើរពីចម្ងាយនៅក្បែរពួកគេ ដោយសារនៅទីនេះមានចន្លោះសម្រាប់ពួកគេដើរ។ គាត់ជាបុរសខ្ពស់ម្នាក់ ហើយហាក់ដូចជាគាត់មកពីចម្ងាយមិនមែននៅក្បែរឡើយ។ ទៅកាន់បុរសនេះស្មោះត្រង់បាននិយាយបែបនេះ

ស្មោះត្រង់៖ មិត្តអើយ តើទៅណា? តើអ្នកកំពុងទៅកាន់ប្រទេសនៃស្ថានសួគ៌មែនទេ?

សាំញ៉ាំ៖ ខ្ញុំកំពុងទៅកន្លែងដូចគ្នាហ្នឹងដែរ។

ស្មោះត្រង់៖ អីចឹងល្អហើយ។ អីចឹងខ្ញុំសង្ឃឹមថានឹងបានអ្នកជាគ្នាដ៏ល្អ។

សាំញ៉ាំ៖ ដោយបំណងល្អនោះខ្ញុំនឹងធ្វើជាអ្នករួមដំណើរជាមួយអ្នក។

ស្មោះត្រង់៖ អីចឹងតោះយើងទៅជាមួយគ្នា ហើយចូរយើងយកពេលមកជជែកគ្នាពីការដែលមានប្រយោជន៍វិញ។

សាំញ៉ាំ៖ ការដែលនិយាយរឿងដែលល្អជាមួយអ្នក ឬអ្នកផ្សេងទៀតសម្រាប់ខ្ញុំជាការដែលគួរទទួលយកបានណាស់។ ហើយរីករាយដែលខ្ញុំបានជួបនឹងអ្នកដែលមានទំនោរទៅរកអំពើល្អ។ ដ្បិតបើនិយាយតាមត្រង់ទៅ

មានមនុស្សតិចទេដែលចង់ចំណាយពេលរបស់ពួកគេ (កាលដែលគេនៅក្នុងការធ្វើដំណើរ) តែគេជ្រើសរើសមកនិយាយពីការដែលគ្មានប្រយោជន៍ជាង ហើយនេះជាបញ្ហាមួយមកដល់ខ្ញុំ។

ស្មោះត្រង់៖ នោះជាការមួយដែលត្រូវទួញសោកជាពិត តើការអ្វីទៅដែលមានតម្លៃសម្រាប់អណ្តាតនិងមាត់របស់មនុស្សនៅលើផែនដី ដែលជាការរបស់ព្រះនៃស្ថានសួគ៌នោះ?

សាំញ៉ាំ៖ ខ្ញុំចូលចិត្តអ្នកខ្លាំងណាស់ ដោយសារការដែលអ្នកនិយាយពេញដោយសេចក្តីជំនឿ។ ហើយខ្ញុំនឹងបន្ថែមលើហ្នឹងទៀតថា តើការអ្វីដែលគួរឱ្យគាប់ចិត្ត និងការអ្វីដែលមានប្រយោជន៍ ដែលត្រូវនិយាយពីការរបស់ព្រះនោះ?

ការអ្វីដែលគួរឱ្យពេញចិត្តនោះ? ការនោះគឺ ប្រសិនបើបុរសម្នាក់មានសេចក្តីអំណរនៅក្នុងការដែលអស្ចារ្យ ឧទាហរណ៍ដូចជា ប្រសិនបើបុរសម្នាក់ចូលចិត្តនិយាយពីប្រវត្តិសាស្រ្ត ឬពីអាថ៌កំបាំងអ្វី ឬប្រសិនបើបុរសម្នាក់ចូលចិត្តនិយាយពីការអស្ចារ្យ ការប្លែកៗ ឬនិមិត្តសញ្ញាផ្សេងៗ។ តើគាត់នឹងរកឃើញការដែលត្រូវបានកត់ត្រាទុកជាសេចក្តីអំណរ និងត្រូវបានរក្សាទុកដោយផ្អែមល្ហែមដូចជានៅក្នុងព្រះគម្ពីរបរិសុទ្ធបាននៅទីណាទៅ?

ស្មោះត្រង់៖ ពិតណាស់ តែដើម្បីទទួលបានប្រយោជន៍ពីការទាំងនោះនៅក្នុងការជជែករបស់យើង នោះជាការដែលយើងនឹងតាក់តែងទេ។

សាំញ៉ាំ៖ ហ្នឹងជាអ្វីដែលខ្ញុំបាននិយាយនោះ ដោយសារការដែលនិយាយរឿងនោះជាការដែលមានប្រយោជន៍។ ធ្វើដូច្នោះមនុស្សនឹងទទួលបានចំណេះដឹងជាច្រើន សម្រាប់ការដែលឥតប្រយោជន៍ខាងលោកិយ និងផលប្រយោជន៍នៃការពីខាងលើ (ជាទូទៅ) ប៉ុន្តែដែលជាក់លាក់នោះ ដោយការនេះម្នាក់នឹងរៀនពីភាពចាំបាច់នៃការកើតជាថ្មី ភាពខ្វះខាតនៃការប្រព្រឹត្តរបស់យើង សេចក្តីត្រូវការនូវសេចក្តីសុចរិតរបស់ព្រះគ្រីស្ទ និងការផ្សេងទៀត។ ក្រៅពីនោះ ដោយការនេះម្នាក់នឹងបានរៀនថាអ្វីដែលត្រូវតែលន់តួបាបដែលត្រូវជឿ ដែលត្រូវអធិស្ឋាន ដែលត្រូវរងវេទនា និងដែលត្រូវចូលចិត្តផង។ ដោយការនេះម្នាក់នឹងបានរៀនពីជាសេចក្តីសន្យាដ៏អស្ចារ្យ និងការលួងលោមចិត្តមកពីដំណឹងល្អ ជាការកំសាន្តចិត្តរបស់គាត់។ លើសពីនោះទៀត ដោយការនេះ ម្នាក់នឹងរៀនបដិសេធគំនិតដែលខុសឆ្គង ទៅដើរតាមសេចក្តីពិត និងណែនាំដល់មនុស្សល្ងង់ផង។

ស្មោះត្រង់៖ ការទាំងនេះសុទ្ធតែពិត ហើយខ្ញុំរីករាយនឹងស្តាប់ការទាំងនេះពីអ្នក។

សាំញ៉ាំ៖ អាក្រក់ណាស់! សេចក្តីប្រថ្នានេះជាហេតុដែលមនុស្សតិចតួចណាស់យល់ពីសេចក្តីត្រូវការខាងសេចក្តីជំនឿ ហើយភាពចាំបាច់នៃការប្រព្រឹត្តរបស់ព្រះគុណនៅក្នុងព្រលឹង ដើម្បីទទួលបានជីវិតអស់កល្បជានិច្ច។ តែរស់នៅតាមក្រិត្យវិន័យដោយមិនដឹងខ្លួន ដោយការនោះមនុស្សមិនអាចទទួលបាននគរស្ថានសួគ៌។

ស្មោះត្រង់៖ តែ ដោយការទុកចោលរបស់អ្នកនោះ ចំណេះដឹងខាងស្ថានសួគ៌នៃការទាំងនេះជាអំណោយទានរបស់ព្រះ គ្មានមនុស្សណាដែលទទួលបានដោយការប្រព្រឹត្តរបស់មនុស្សឡើយ ឬដោយការជជែករបស់ពួកគេនោះឡើយ។

សាំញ៉ាំ៖ ការទាំងនេះខ្ញុំបានដឹងច្បាស់ណាស់។ ដោយសារមិនមានអ្នកដែលបានទទួលអ្វី ក្រៅពីការដែលផ្តល់មកពីស្ថានសួគ៌នោះទេ។ ការទាំងនេះជាព្រះគុណ មិនមែនដោយការប្រព្រឹត្តឡើយ។ ខ្ញុំអាចឱ្យខគម្ពីរដល់អ្នករាប់រយដែលនឹងបញ្ជាក់អះអាងពីការនេះ។

ស្មោះត្រង់៖ "ល្អហើយអីចឹង" ស្មោះត្រង់បាននិយាយថា "តើអ្វីទៅជាការមួយដែលយើងនឹងរកឃើញនៅក្នុងការជជែកគ្នារបស់ពួកយើងនៅពេលនេះ?"

សាំញ៉ាំ៖ អ្វីដែលអ្នកនឹងនិយាយ នោះខ្ញុំនឹងនិយាយពីការពីស្ថានសួគ៌ ឬការពីផែនដី។ ការពីសីលធម៌ ឬការបែបផ្សាយដំណឹងល្អ ពីការបរិសុទ្ធ ឬការដែលស្មោគគ្រោក ដែលពីអតីតកាល ឬការដែលនឹងត្រូវមក ការដែលមកពីសាសន៍ដទៃ ឬការដែលនៅផ្ទះ ការដែលសំខាន់ជាង ឬការដែលតាមកាលៈទេសៈ។ ដែលត្រូវបានផ្តល់មកជាប្រយោជន៍ដល់យើង។

ស្មោះត្រង់៖ ពេលនេះស្មោះត្រង់ចាប់ផ្តើមឆ្ងល់ ហើយក៏បោះជំហានទៅរកគ្រីស្ទាន (ដោយសារតែគាត់បានដើរតែឯងរហូតមក) បាននិយាយទៅកាន់គាត់ថា (តែនិយាយដោយថ្នមៗ) "តើអ្នករួមដំណើរដ៏ក្លាហានយ៉ាងណាហ្នំដែលយើងមាន! ពិតណាស់បុរសនេះនឹងធ្វើឱ្យការធ្វើធម្មយាត្រានេះល្អឥតខ្ចោះ។"

គ្រីស្ទានៈ ដូចនោះគ្រីស្ទានក៏បានញញឹមដោយស្រគត់ស្រគុំ ហើយនិយាយថា "បុរសនេះដែលបានធ្វើឱ្យអ្នកត្រូវសណ្ដំដោយសារអណ្ដាតនៃមនុស្សម្ដែអ្នកនេះដែលមិនបានស្គាល់គាត់សោះ។"

ស្មោះត្រង់ៈ អីចឹង តើអ្នកស្គាល់គាត់ទេ?

គ្រីស្ទានៈ ស្គាល់គាត់! ស្គាល់គាត់ជាងដែលគាត់ស្គាល់ខ្លួនឯងផង។

ស្មោះត្រង់ៈ សូមប្រាប់មក តើគាត់ជាអ្វី?

គ្រីស្ទានៈ ឈ្មោះរបស់គាត់គឺសាំញ៉ាំ។ គាត់រស់នៅក្នុងស្រុករបស់យើង ឆ្ងល់ថាអ្នកបែរជាមិនស្គាល់គាត់វិញ ខ្ញុំគ្រាន់តែគិតថាស្រុករបស់យើងវាធំទូលាយបន្តិច។

ស្មោះត្រង់ៈ តើគាត់ជាកូនរបស់អ្នកណា? ហើយគាត់រស់នៅម្តុំណាដែរ?

គ្រីស្ទានៈ គាត់ជាកូនប្រុសរបស់ម្នាក់ឈ្មោះ និយាយបានល្អ។ គាត់រស់នៅផ្លូវដែលនិយាយឡិឡក់ ហើយគាត់ត្រូវបានស្គាល់ដោយគ្រប់គ្នានូវឈ្មោះសាំញ៉ាំនៅក្នុងផ្លូវដែលនិយាយឡិឡក់ ហើយមិនយកឈ្មោះអណ្ដាតដ៏ពូកែរបស់គាត់ គាត់ជាមនុស្សដែលគួរឱ្យអាណិត។

ស្មោះត្រង់ៈ ពិតណាស់ គាត់ហាក់ដូចជាមនុស្សដែលល្អណាស់។

គ្រីស្ទានៈ គឺសម្រាប់តែអ្នកដែលមិនបានស្គាល់គាត់ច្បាស់ប៉ុណ្ណោះ ដោយសារជាល្អបំផុតនៅក្រៅប្រទេស នៅក្បែរផ្ទះវិញគាត់អាក្រក់ណាស់។

ការដែលអ្នកនិយាយថាគាត់ជាមនុស្សល្អ បាននាំឱ្យគំនិតរបស់ខ្ញុំគិតដល់ អ្វីដែលខ្ញុំបានសង្កេតនៅក្នុងកិច្ចការរបស់អ្នកជាត់ពណ៌ ដែលរូបភាពរបស់គាត់បានបង្ហាញមកយ៉ាងស្រស់ស្អាតពីចម្ងាយ តែនៅយ៉ាងជិតវិញ មិនគួរឱ្យពេញចិត្តសោះ។

ស្មោះត្រង់៖ តែខ្ញុំបានគិតថាអ្នកគ្រាន់តែនិយាយលេងប៉ុណ្ណោះ ដោយសារអ្នកញញឹម។

គ្រីស្ទាន៖ ខ្ញុំមិនបាននិយាយលេងសើចឡើយ បើទោះជាខ្ញុំញញឹមក៏ដោយនៅក្នុងបញ្ហានេះ ឬខ្ញុំត្រូវចោទប្រកាន់អ្នកណាម្នាក់ដោយខុសឆ្គងនោះឡើយ។ ខ្ញុំចង់ផ្តល់នូវការរកឃើញដែលច្រើនជាងនេះពីគាត់។ បុរសនេះគឺសម្រាប់គ្នាណាទាំងអស់ ការជជែកទាំងអស់ ដូចដែលគាត់និយាយជាមួយអ្នកពេលនេះ នោះគាត់នឹងនិយាយនៅពេលដែលគាត់នៅកន្លែងផឹកស៊ី ហើយកាលណាមានគ្រឿងស្រវឹងច្រើននៅមកុដរបស់គាត់ នឹងមានការទាំងនេះកាន់តែច្រើននៅក្នុងមាត់របស់គាត់ សាសនាមិនមាននៅក្នុងចិត្ត ឬនៅផ្ទះ ឬនៅក្នុងការសន្ទនារបស់គាត់ទេ អ្វីទាំងអស់ដែលនៅលើអណ្តាតរបស់គាត់និងសាសនារបស់គាត់ គឺជាការបង្កើតសម្លេងនឹងការនោះ។

ស្មោះត្រង់៖ អ្នកនិយាយអីចឹង! អីចឹងខ្ញុំត្រូវបុរសនេះបោកខ្លាំងហើយ។

គ្រីស្ទាន៖ ត្រូវបញ្ឆោត! អ្នកនឹងប្រាកដពីវា។ចូរចង់ចាំសុភាសិតដែលថា "ពួកគេចេះតែនិយាយ តែមិនធ្វើសោះ។ តែនគររបស់ព្រះមិនមែននៅក្នុងពាក្យសំដីទេ តែនៅក្នុងអំណាចវិញ។"

“អ្វីៗដែលគេបង្រៀនអ្នករាល់គ្នា ចូរស្ដាប់ ហើយយកទៅប្រតិបត្ដិតាមទៅ តែកុំយកតម្រាប់តាមអំពើដែលគេប្រព្រឹត្ដឡើយ ដ្បិតគេមិនប្រតិបត្ដិតាមសេចក្ដីដែលគេបង្រៀននោះទេ។” **ម៉ាថាយ 23:3**

“ដ្បិតព្រះរាជ្យរបស់ព្រះជាម្ចាស់មិនមែនស្ថិតនៅលើពាក្យសម្ដីទេ គឺស្ថិតនៅលើការប្រព្រឹត្ដវិញ។” **កូរិនថូសទី១** 4:20

គាត់និយាយពីការអធិស្ឋាន ការលន់តួបាប សេចក្ដីជំនឿ និងការកើតជាថ្មី។ តែគាត់ដឹងតែពីការនិយាយពីរឿងទាំងនោះប៉ុណ្ណោះ។ ខ្ញុំបាននៅក្នុងគ្រួសាររបស់គាត់ ហើយបានសង្កេតមើលគាត់ទាំងនៅក្នុងផ្ទះនិងខាងក្រៅផង។ ហើយខ្ញុំដឹងថាអ្វីដែលខ្ញុំបាននិយាយពីគាត់សុទ្ធតែជាការពិត។ ផ្ទះរបស់គាត់ជាសាសនាដែលទទេរ ប្រៀបបីដូចនឹងរសជាតិនៃផ្ទែកសរបស់ស៊ុតដែរ។ មិនមានការអធិស្ឋាន ហើយក៏មិនមានសញ្ញានៃការប្រែចិត្ដពីអំពើបាបដែរ។ គ្រឹះប្រភេទនេះបម្រើព្រះបានប្រសើរជាគាត់ផង។ គាត់ជាស្នាមប្រឡាក់ ជាការចោទប្រកាន់ និងជាសេចក្ដីអាម៉ាសរបស់សាសនាដល់អស់អ្នកដែលស្គាល់គាត់។

“អ្នកអួតអាងលើក្រឹត្យវិន័យ តែអ្នកបែរជាបង្អាប់កិត្ដិយសព្រះជាម្ចាស់ ដោយប្រព្រឹត្ដល្មើសក្រឹត្យវិន័យ។ ដូចមានចែងទុកមកថា *ព្រោះតែអ្នករាល់គ្នាបានជាសាសន៍ដទៃប្រមាថព្រះនាមរបស់ព្រះជាម្ចាស់*។” **រ៉ូម 2:23, 24**

វាពិបាកនឹងមានពាក្យល្អៗនៅទីបញ្ចប់នៃទីក្រុងដែលគាត់រស់នៅណាស់

ដោយសារគាត់។ ដូច្នេះមនុស្សទូទៅដែលស្គាល់គាត់តែងនិយាយថា "អ្នកបរិសុទ្ធនៅខាងក្រៅ និងជាអារក្សនៅក្នុងផ្ទះ។" គ្រួសារដែលក្រីក្ររបស់គាត់ក៏ឃើញថាដូច្នោះដែរ។ គាត់ជាមនុស្សឈ្លើយ ស្រែកគំហកដាក់ ហើយមិនមានហេតុផលដល់អ្នកបម្រើរបស់គាត់ ដែលពួកគេមិនចេះធ្វើសម្រាប់គាត់ ឬនិយាយទៅគាត់ឡើយ។ អ្នកដែលមានការជាមួយគាត់ និយាយថា ជាការប្រសើរជាងដែលទៅនិយាយជាមួយនឹងជនជាតិតួគីជាងនិយាយជាមួយគាត់។ ដោយសារនៅក្នុងដៃរបស់ពួកគេមានការដោះស្រាយដែលត្រឹមត្រូវជាង។ សាំញ៉ាំនេះ បើអាចទោរួច នឹងធ្វើលើសពីពួកគេទៅទៀត ដែលបោកប្រាស់ លួងលោម ហើយយកឈ្នះពួកគេ។ ក្រៅពីនោះ គាត់បានប្រដៅកូនៗរបស់គាត់ឱ្យដើរតាមជំហានរបស់គាត់។ ហើយប្រសិនបើគាត់រកឃើញភាពភ័យខ្លាចដោយល្ងង់ខ្លៅនៅក្នុងពួកគេ (ដូចនោះគាត់ហៅថាជារូបរាងលេចមកដំបូងនៃសតិល្អ) គាត់ហៅពួកគេថាជាមនុស្សល្ងីល្ងើនិងល្ងង់ខ្លៅ ហើយនឹងប្រើពួកគេច្រើនទៀត ឬដោយនិយាយណែនាំពួកគេនៅមុខអ្នកដទៃ។ សម្រាប់ផ្នែករបស់ខ្ញុំ ខ្ញុំមានគំនិត គឺដោយជីវិតទុច្ចរិតរបស់គាត់ វាបានធ្វើឲ្យមនុស្សជាច្រើនត្រូវជំពប់ដួលនិងដួល។ ប្រសិនបើព្រះមិនហាមឃាត់ទេ មនុស្សជាច្រើនទៀតនឹងត្រូវវិនាសផងដែរ។

ស្មោះត្រង់៖ ពិតណាស់ បងប្អូនរបស់ខ្ញុំអើយ ខ្ញុំជឿអ្នកហើយ មិនមែនដោយសារអ្នកនិយាយថាអ្នកស្គាល់គាត់នោះទេ តែដោយសារ ដូចជាគ្រីស្ទានអ្នកបានធ្វើការរាយការណ៍ពីមនុស្ស។ ដោយសារខ្ញុំមិនអាចគិតបានថាអ្នកនិយាយពីការទាំងនេះដោយបំណងអាក្រក់ឡើយ តែដោយសារវាដូចជាអ្វីដែលអ្នកនិយាយហើយ។

គ្រីស្ទានៈ ខ្ញុំមិនបានស្គាល់គាត់ជាងអ្នកនោះទេ ខ្ញុំអាចនឹងគិតពីគាត់ដូចដែលអ្នកបានគិតពីដំបូងដែរ។ គាត់បានទទួលដំណឹងទាំងនេះនៅដៃរបស់ពួកគេដែលជាសត្រូវរបស់សាសនា ខ្ញុំគួរតែបានគិតថាវាជាការចោទប្រកាន់ (ដែលជាញឹកញាប់ចេញមកពីមាត់របស់មនុស្សអាក្រក់ដែលចូលទៅក្នុងគំនិតរបស់មនុស្សនិងការអះអាងរបស់ពួកគេ)។ ប៉ុន្តែការទាំងនេះនិងការជាច្រើនទៀតសុទ្ធតែអាក្រក់ដូចគ្នា ដែលដោយសារការយល់ដឹងរបស់ខ្ញុំនោះខ្ញុំអាចបញ្ជាក់ថាគាត់មានកំហុសនោះ។ ក្រៅពីនោះ មនុស្សល្អមានសេចក្តីអាម៉ាស់នឹងគាត់។ ពួកគេមិនអាចនឹងហៅគាត់ថាបងប្អូនឬជាមិត្តបានឡើយ ដោយស្មោះរបស់គាត់នៅក្នុងចំណោមពួកគេធ្វើឱ្យពួកគេអៀនខ្មាស់ប្រសិនបើពួកគេស្គាល់គាត់!

ស្មោះត្រង់៖ ពិតណាស់ ខ្ញុំឃើញថាការនិយាយនិងការធ្វើជាការពីរផ្សេងគ្នា។ ហើយបន្ទាប់មក ខ្ញុំគួរតែសង្កេតមើលការខុសប្លែកគ្នានេះ។

គ្រីស្ទានៈ ជាការពីរផ្សេងគ្នាពិតមែន ហើយដែលប្លែកគ្នាដូចជាព្រលឹងនិងរូបកាយដែរ។ ប្រសិនបើរូបកាយមិនមានព្រលឹង នោះជាសាកសពវិញ។ ដូច្នេះ ប្រសិនបើមានតែ "ការនិយាយ" តែមួយ នោះវាជាសាកសពដូចគ្នាដែរ។ ព្រលឹងរបស់សាសនាជាផ្នែកនៃការប្រព្រឹត្តនោះឯង។ "សាសនាដែលបរិសុទ្ធនិងមិនបំភ្លៃ នៅចំពោះព្រះនិងព្រះវរបិតាជាការនេះ គឺការទៅសួរសុខទុក្ខក្មេងកំព្រា និងស្រីមេម៉ាយនៅពេលដែលមានទុក្ខលំបាក និងការរក្សាខ្លួនឲ្យពីលោកិយ។"

**"ចូរប្រតិបត្តិតាមព្រះបន្ទូល កុំគ្រាន់តែស្តាប់ទាំងបញ្ឆោតចិត្តខ្លួនឯងប៉ុណ្ណោះ**

ឡើយ។ អ្នកណាស្ដាប់ព្រះបន្ទូលហើយ មិនប្រតិបត្តិតាម អ្នកនោះប្រៀបបាននឹងមនុស្សម្នាក់ឆ្លុះកញ្ចក់មើលមុខខ្លួន។ លុះពិនិត្យមើលរួចហើយ ក៏ចេញទៅស្រាប់តែភ្លេចមិនដឹងថាមុខខ្លួនឯងដូចម្ដេចផង។ រីឯអ្នកដែលយកចិត្តទុកដាក់ពិនិត្យមើលក្រឹត្យវិន័យដ៏គ្រប់លក្ខណៈ ជាក្រឹត្យវិន័យដែលផ្ដល់សេរីភាព ហើយព្យាយាមប្រតិបត្តិតាមយ៉ាងជិតដល់ គឺមិនគ្រាន់តែស្ដាប់ រួចភ្លេចអស់ទៅ អ្នកនោះនឹងមានសុភមង្គលក្នុងកិច្ចការដែលខ្លួនធ្វើជាមិនខាន។ ប្រសិនបើនរណាម្នាក់នឹកស្មានថាខ្លួនជាអ្នកកាន់សាសនា តែមិនចេះទប់អណ្ដាតខ្លួន អ្នកនោះបញ្ឆោតខ្លួនឯងហើយ ហើយសាសនាដែលខ្លួនកាន់នោះ ក៏គ្មានប្រយោជន៍អ្វីដែរ។ រីឯសាសនាដ៏បរិសុទ្ធ ឥតខ្ចោះនៅចំពោះព្រះភ័ក្ត្រព្រះបិតាជាម្ចាស់វិញ គឺស្ថិតនៅលើការទៅសួរសុខទុក្ខក្មេងកំព្រា និងស្ត្រីមេម៉ាយដែលមានទុក្ខលំបាក ព្រមទាំងស្ថិតនៅលើការរក្សាខ្លួនឲ្យផុតពីអំពើសៅហ្មងរបស់លោកីយ៍នេះ។″ យ៉ាកុប 1:22-27

ស្មោះត្រង់៖ អីចឹង ប្រសិនជាអ្នកចង់ ចូរបកស្រាយពីសញ្ញាសម្គាល់ផ្សេងទៀតនៃកិច្ចការរបស់ព្រះគុណដែលបង្ហាញមកនៅទីនេះ។

សាំញ៉ាំ៖ ទេ ដោយសារខ្ញុំឃើញថាយើងមិនត្រូវគ្នាសោះ។

ស្មោះត្រង់៖ អីចឹង បើអ្នកមិននិយាយទេ តើអ្នកអាចឱ្យខ្ញុំនិយាយបានទេ?

សាំញ៉ាំ៖ អ្នកអាចប្រើសិរីភាពរបស់អ្នកបាន។

ស្មោះត្រង់៖ កិច្ចការរបស់ព្រះគុណបង្ហាញខ្លួនមកទាំងដល់អ្នកដែលមានវា ឬដល់អ្នកដែលចោទត្រូវវាចោទប្រកាន់ផងដែរ។ សម្រាប់អ្នកដែលមានព្រះ

គុណ នោះវានឹងផ្តល់នូវការផ្លាស់ប្រែចេញពីអំពើបាប ជាពិសេសភាពពុករលួយខាងធម្មជាតិរបស់គេ និងអំពើបាបដែលមិនព្រមជឿ ដែលដោយសារការទាំងនោះដែលគាត់នឹងត្រូវជំនុំជំរះ ប្រសិនបើគាត់មិនបានទទួលព្រះគុណពីព្រះហស្តរបស់ព្រះដោយសេចក្តីជំនឿលើអង្គព្រះយេស៊ូវគ្រីស្ទ។ រូបភាពនិងអត្ថន័យនៃការទាំងនេះធ្វើឱ្យគាត់មានសេចក្តីអាម៉ាសនិងទួញសោកដោយសារអំពើបាប ហើយឱ្យគាត់បានរកឃើញថែមទៀតពីព្រះអង្គសង្គ្រោះនៃលោកិយនេះ និងភាពចាំបាច់បំផុតនៅក្នុងការចូលទៅជិតទ្រង់ដើម្បីបានជីវិត ដោយសារការនោះគាត់នឹងស្រេកឃ្លានចង់បានទ្រង់ ដែលស្រេកឃ្លានជាដើម។ សេចក្តីសន្យាត្រូវបានបង្កើតមក។ ឥឡូវនេះ យោងតាមកម្លាំងនិងភាពកំសោយនៃសេចក្តីជំនឿរបស់គាត់នៅក្នុងព្រះសង្គ្រោះរបស់គាត់ នោះក៏ដូចជាសេចក្តីអំណរនិងសេចក្តីសុខសាន្តរបស់គាត់ដែរ ក៏ដូចជាសេចក្តីស្រឡាញ់របស់គាត់ដល់ភាពបរិសុទ្ធ ក៏ដូចជាបំណងប្រាថ្នារបស់គាត់ចង់ស្គាល់ទ្រង់ថែមទៀត ហើយក៏ដូចជាចង់បម្រើទ្រង់នៅក្នុងលោកិយនេះ។ បើទោះជាខ្ញុំនិយាយថាវាបង្ហាញមកបែបនេះនៅក្នុងមនុស្សម្នាក់នោះ តែវាកើតឡើងដោយកម្រដែលគាត់អាចសរុបបានថាវាជាកិច្ចការនៃព្រះគុណ ពីព្រោះភាពពុករលួយរបស់គាត់ពេលនេះ និងដោយសារហេតុផលដែលគាត់បានបំភ្លៃ ដែលធ្វើឱ្យគាត់កាត់ស្រាយបញ្ហានេះមិនបានត្រឹមត្រូវ។ ដូច្នេះនៅក្នុងគាត់ដែលមានកិច្ចការនេះ នោះត្រូវមានការជំនុំជំរះឱ្យបានត្រឹមត្រូវ មុនពេលគាត់អាចសរុបសេចក្តីបាននឹងធឹងថា វាជាកិច្ចការនៃព្រះគុណ។

‶កាលណាទ្រង់បានយាងមកហើយ នោះនឹងសំដែងឱ្យមនុស្សលោកដឹងច្បាស់ ពីអំពើបាប ពិសេចក្តីសុចរិត ហើយពីសេចក្តីជំនុំជំរះ។ គឺពីអំពើបាបដោយព្រោះគេមិនជឿដល់ខ្ញុំ។″ យ៉ូហាន 16:8, 9

‶វេទនាណាស់ខ្ញុំ តើអ្នកណានឹងជួយខ្ញុំឱ្យរួច ពីតួសេចក្តីស្លាប់នេះទៅបាន។″ រ៉ូម 7:24

‶អ្នកណាដែលជឿ ហើយទទួលបុណ្យជ្រមុជទឹក នោះនឹងបានសង្គ្រោះ តែអ្នកណាដែលមិនព្រមជឿ នោះនឹងត្រូវទោសវិញ។″ ម៉ាកុស 16:16

‶តើឯងបានពិចារណា ឃើញទទឹងនិងបណ្តោយនៃផែនដីឬ ចូរប្រាប់មកចុះ បើឯងដឹងសេចក្តីទាំងអស់នេះហើយ។″ ទំនុកដំកើង 38:18

‶ក្រោយដែលទ្រង់បានទាញញាក់ទូលបង្គំមកវិញ នោះទូលបង្គំបានប្រែគំនិតឡើងជាពិត កាលដែលទូលបង្គំទទួលបានសេចក្តីប្រៀនប្រដៅហើយ នោះក៏វាយទះភ្លៅខ្លួន ទូលបង្គំមានសេចក្តីខ្មាស អើក៏ជ្រប់មុខផង ពីព្រោះទូលបង្គំធន់រងសេចក្តីអាម៉ាសខ្មាសនៃវ័យក្មេង។″ យេរេមា 31:19

‶យើងដឹងថាមនុស្សមិនរាប់ជាសុចរិត ដោយប្រព្រឹត្តតាមក្រឹត្យវិន័យនោះឡើយ គឺដោយសេចក្តីជំនឿជឿដល់ព្រះយេស៊ូវគ្រីស្ទវិញ ហេតុនោះបានជាយើងជឿដល់ព្រះគ្រីស្ទយេស៊ូវ ដើម្បីឱ្យបានរាប់ជាសុចរិត ដោយសារសេចក្តីជំនឿជឿដល់ព្រះគ្រីស្ទ នោះមិនមែនដោយការប្រព្រឹត្តតាមក្រឹត្យវិន័យទេ ពីព្រោះគ្មានមនុស្សណាបានរាប់ជាសុចរិត ដោយប្រព្រឹត្តតាមក្រឹត្យវិន័យឡើយ។″ កាឡាទី 2:16

“ហើយគ្មានសេចក្តីសង្គ្រោះ ដោយសារអ្នកណាទៀតសោះ ដ្បិតនៅក្រោមមេឃ គ្មាននាមឈ្មោះណាទៀតបានប្រទានមកមនុស្សលោក ឱ្យយើងរាល់គ្នាបានសង្គ្រោះនោះឡើយ។” កិច្ចការ 4:12

“មានពរហើយអស់អ្នកដែលស្រេកឃ្លាននូវសេចក្តីសុចរិត ដ្បិតអ្នកទាំងនោះនឹងបានឆ្អែត។” ម៉ាថាយ 5:6

“ទ្រង់ក៏មានបន្ទូលមកខ្ញុំថា ស្រេចហើយអញជាអាល់ផា និងអូមេកា គឺជាដើមហើយជាចុង បើអ្នកណាស្រេក អញនឹងឱ្យអ្នកនោះផឹកពីរន្ធទឹកនៃជីវិត ឥតយកថ្លៃ។” វិវរណៈ 21:6

“ដ្បិតយើងបានសុចរិតដោយមានចិត្តជឿ ហើយក៏បានសង្គ្រោះដោយមាត់ទទួលថ្លែងប្រាប់។” រ៉ូម 10:10

“បងប្អូនអើយ ចូរត្រាប់តាមខ្ញុំគ្រប់គ្នា ហើយពិចារណាមើលឱ្យស្គាល់ពួកអ្នកដែលដើរ ដូចជាយើងបានធ្វើក្បួនឱ្យអ្នករាល់គ្នាហើយ។” ភីលីព 3:17

“មានពរហើយអស់អ្នកដែលមានចិត្តបរិសុទ្ធ ដ្បិតអ្នកនោះនឹងបានឃើញព្រះ។” ម៉ាថាយ 5:8

សម្រាប់ការផ្សេងទៀត វាបង្ហាញមកដូច្នេះ

1. ដោយសារការសារភាពសេចក្តីជំនឿរបស់គាត់នៅក្នុងព្រះយេស៊ូវគ្រីស្ទបែបពិសោធន៍។ 2. ដោយជីវិតដែលឆ្លើយតបទៅនឹងការសារភាព ដែលរស់

នៅក្នុងជីវិតដែលបរិសុទ្ធ ចិត្តបរិសុទ្ធ គ្រួសារដែលបរិសុទ្ធ (ប្រសិនបើគាត់មានគ្រួសារ) ហើយដោយការសន្ទនាដែលបរិសុទ្ធនៅក្នុងលោកនេះ ដែលជាទូទៅបង្រៀនគាត់ឱ្យស្អប់អំពើបាបរបស់គាត់ខាងក្នុង និងខ្លួនគាត់ ដោយសារការទាំងនោះជាសម្ងាត់ ត្រូវលុបបំបាត់វាចេញពីក្រុមគ្រួសារ ហើយលើកស្ទួយភាពបរិសុទ្ធនៅក្នុងលោកិយនេះវិញ មិនមែនគ្រាន់តែនិយាយតែម្យ៉ាងនោះទេ ដែលដូចជាមនុស្សកំពុត ឬមនុស្សសាំញ៉ាំធ្វើនោះទេ តែដោយការប្រព្រឹត្តដោយសេចក្តីជំនឿនិងសេចក្តីស្រឡាញ់ដោយអំណាចរបស់ព្រះបន្ទូល។

"បើអ្នករាល់គ្នាស្រឡាញ់ខ្ញុំ ចូរកាន់តាមបញ្ញត្តិរបស់ខ្ញុំចុះ។" យ៉ូហាន 14:15

"អ្នកណាដែលថ្វាយដង្វាយជាសេចក្តីអរព្រះគុណ នោះក៏លើកដំកើងអញដែរ ហើយអញនឹងសម្តែងសេចក្តីសង្គ្រោះរបស់ព្រះដល់អ្នកណាដែលរៀបផ្លូវរបស់ខ្លួនឱ្យត្រង់។" ទំនុកដំកើង 50:23

"កាលពីដើមត្រចៀករបស់ទូលបង្គំបានគ្រាន់តែឮថ្លែងពីទ្រង់ប៉ុណ្ណោះ តែឥឡូវនេះ ភ្នែកទូលបង្គំបានឃើញទ្រង់ជាក់វិញ។ បានជាទូលបង្គំខ្ពើមដល់ខ្លួន ហើយក៏ប្រែចិត្ត ដោយក្រាបនៅក្នុងធូលីដី ហើយនឹងផេះ។" យ៉ូប 42:5, 6

"នៅក្នុងស្រុកនោះ ឯងរាល់គ្នានឹងនឹកចាំពីអស់ទាំងអំពើ និងកិរិយាទាំងប៉ុន្មានរបស់ខ្លួន ជាការដែលនាំឱ្យឯងស្មោគគ្រោក នោះឯងរាល់គ្នានឹងខ្ពើមខ្លួនដោយព្រោះអំពើអាក្រក់ទាំងប៉ុន្មាន ដែលឯងបានធ្វើនោះ។" អេសេគាល 20:43

ហើយពេលនេះ លោកអើយ សម្រាប់ការរៀបរាប់ដ៏ខ្លីនេះពីកិច្ចការនៃព្រះគុណ និងការបង្ហាញការនេះ ប្រសិនបើអ្នកមានការជំទាស់នោះ ក៏និយាយមក។ បើមិនមានទេ សូមឱ្យខ្ញុំបានបកស្រាយដល់អ្នកនូវសំណួរទីពីរទៀតវិញ។
សាំញ៉ាំ៖ ទេ ចំណែកខ្ញុំវិញពេលនេះមិនមានអ្វីត្រូវជំទាស់ទេ តែខ្ញុំត្រូវស្តាប់វិញ។ អីចឹងសូមឱ្យខ្ញុំបានស្តាប់នូវសំណួរទីពីររបស់អ្នកវិញ។

ស្មោះត្រង់៖វាគឺការនេះ។ តើអ្នកបានបទពិសោធន៍នៃការបកស្រាយបំបូងរបស់ការនេះទេ? ហើយតើជីវិតនិងការសន្ទនារបស់អ្នកបានបង្ហាញដូចគ្នាទេ? ឬសាសនារបស់អ្នកឈរតែនៅលើពាក្យសម្ដីនិងនៅក្នុងអណ្ដាត ហើយមិននៅក្នុងទង្វើនិងសេចក្ដីពិតទេឬយ៉ាងណា? សូមអ្នកមេត្តាឆ្លើយប្រាប់ខ្ញុំពីការនេះផង សូមកុំនិយាយលើសពីអ្វីដែលអ្នកដឹងពីព្រះខាងលើទ្រង់នឹងមានបន្ទូលថាអាម៉ែនទៅកាន់ការនោះ ហើយគ្មានអ្វីក្រៅពី ការដែលសតិរបស់អ្នកអាចបញ្ជាក់ពីអ្នកបាន ដោយសារមិនមែនជាម្នាក់ដែលសរសើរខ្លួនឯងដែលត្រូវទទួលស្គាល់នោះទេ តែជាអ្នកដែលព្រះអម្ចាស់ជាអ្នកសរសើរវិញ។ ក្រៅពីនោះទៀត ការដែលនិយាយថាខ្ញុំអញ្ចេះឬអញ្ចុះនោះ កាលដែលការសន្ទនានរបស់ខ្ញុំនិងអ្នកជិតខាងរបស់ខ្ញុំប្រាប់ថាខ្ញុំកុហក់វិញនោះ នោះវាជាការដ៏អាក្រក់បំផុត។

សាំញ៉ាំ៖ បន្ទាប់មកសាំញ៉ាំពីដំបូងចាប់ផ្ដើមអៀន តែក៏បានធូរស្បើយ ដូច្នេះគាត់ក៏ឆ្លើយតបថា "អ្នកបានមានបទសោធន៍ហើយពេលនេះ ទៅដល់ឧត្ដមគតិ និងព្រះផង។ ហើយការដែលសុំដល់ទ្រង់នូវភាពត្រឹមត្រូវពីអ្វីដែលបាននិយាយនោះ។ ការនិយាយបែបនេះខ្ញុំមិនចង់បានទេ ហើយខ្ញុំក៏មិនឆ្លើយនឹង

សំណួរបែបនោះដែរ ដោយសារខ្ញុំមិនរាប់ខ្លួនថាមានទាក់ទងនឹងការនោះទេ លើកលែងតែអ្នកគិតថាខ្លួនសួរសំណួរនិងឆ្លើយផង ហើយបើទោះជាអ្នកគួរតែធ្វើដូច្នោះក៏ដោយ ខ្ញុំនៅតែមិនព្រមឱ្យអ្នកធ្វើជាចៅក្រមរបស់ខ្ញុំឡើយ។ តែសូមអ្នកប្រាប់ខ្ញុំផង ថាហេតុអ្វីបានជាអ្នកសួរសំណួរបែបនេះ?"

ស្មោះត្រង់៖ ដោយសារខ្ញុំបានឃើញអ្នកផ្លោះទៅនិយាយ ហើយដោយសារខ្ញុំមិនបានដឹងថាអ្នកមានតែទំនោរទៅរក។ ក្រៅពីនោះ បើប្រាប់អ្នកត្រង់ទៅ ខ្ញុំបានឮពីអ្នកថា សាសនារបស់អ្នកគឺនៅក្នុងការជជែក។ ហើយការសន្ទនារបស់អ្នកដែលផ្តល់ការសារភាពដោយមាត់នេះនូវការកុហក។ គេនិយាយថា អ្នកជាស្នាមនៅក្នុងចំណោមគ្រីស្ទាន ហើយសាសនាបង្ហាញមកកាន់តែអាក្រក់ដោយសារការសន្ទនាដែលអាក្រក់របស់អ្នក ដែលមានមនុស្សមួយចំនួនបានជំពប់ដួលដោយសារផ្លូវទុច្ចរិតរបស់អ្នករួចទៅហើយ ហើយថា មានមនុស្សជាច្រើនទៀតដែលកំពុងមានគ្រោះថ្នាក់នឹងត្រូវវិនាសដូចគ្នា។ សាសនារបស់អ្នក ហើយនិងផ្ទះប្រមឹក និងសេចក្តីលោភលន់ និងភាពមិនស្អាត និងការស្បថ និងការកុហក និងរក្សាគូរកនដែលឥតប្រយោជន៍ និងការផ្សេងទៀត។ល។ នឹងឈរជាមួយគ្នា។ សុភាសិតត្រូវណាស់ដែលនិយាយពីអ្នក ដែលនិយាយពីស្រីសំផឹង ដែលនិយាយថា "នាងជាសេចក្តីអាម៉ាស់ដល់មនុស្សស្រីទាំងអស់" ដូច្នេះអ្នកជាសេចក្តីអាម៉ាសដល់អ្នកដែលសារភាពទាំងអស់។

សាំញ៉ាំ៖  ក្នុងកាលដែលអ្នករួចរាល់នឹងទាញយករឿងចេញមកហើយ ដើម្បីនឹងកាត់ទោសដោយរហ័សដូចដែលអ្នកបានធ្វើហើយនោះ ខ្ញុំមិនអាចធ្វើអ្វីបានក្រៅពីសរុបថា អ្នកជាមនុស្សម្នាក់ដែលពេញដោយកំហឹងនិងសេចក្តី

សោកសៅ ដែលមិនសាកសមនឹងពិភាក្សាជាមួយឡើយ ហើយនិយាយលាយចេញទៅ!

គ្រីស្ទាន៖ បន្ទាប់មកគ្រីស្ទានក៏បានចេញមក ហើយនិយាយជាមួយបងប្អូនរបស់គាត់ថា "ខ្ញុំបានប្រាប់អ្នកថាវានឹងកើតឡើង។ ពាក្យពេចន៍របស់អ្នកនិងតណ្ហារបស់គាត់នឹងមិនត្រូវគ្នាឡើយ។ គាត់សុខចិត្តចាកចេញពីអ្នក ជាជាងកែប្រែជីវិតរបស់គាត់។ តែគាត់បានទៅបាត់ហើយ ដូចដែលខ្ញុំបាននិយាយហើយ ចូរឱ្យគាត់ទៅចុះ។ ការបាត់បង់មិនមែនជារបស់អ្នកណាឡើយ តែជារបស់គាត់វិញ។ គាត់បានជួយយើងកុំឱ្យនឹងពិបាកដើរចេញពីគាត់ហើយ ដោយសារគាត់នៅតែបន្តដូចដែលខ្ញុំបានគិតរួចហើយ។ គាត់ជាយ៉ាងណានោះគាត់នឹងត្រូវបានលុបចេញពីគ្នារបស់យើង។ ក្រៅពីនោះ ដូចជាពួកសាវកបាននិយាយថា "ចូរដកខ្លួនរបស់អ្នកចេញពីមនុស្សបែបនោះ។"

ស្មោះត្រង់៖ តែខ្ញុំរីករាយដែលយើងមានការជជែកគ្នាបន្តិចនេះជាមួយគាត់។ គាត់អាចនឹងគិតពីវាម្តងទៀត។ ទោះជាយ៉ាងណា ខ្ញុំបានដោះស្រាយយ៉ាងច្បាស់ជាមួយគាត់ហើយ ហើយខ្ញុំបានរួចផុតពីឈាមរបស់គាត់ហើយ ប្រសិនបើគាត់ស្លាប់។

គ្រីស្ទាន៖ អ្នកធ្វើបានល្អហើយដែលបាននិយាយច្បាស់ៗជាមួយគាត់ ដូចដែលអ្នកបានធ្វើនោះ។ មានតែការដោះស្រាយដោយស្មោះត្រង់តិចបណ្តោះសព្វថ្ងៃនេះ ហើយវាបានធ្វើឱ្យសាសនាត្រូវជាស្អុយគគ្រុកនៅក្នុងច្រមុះរបស់មនុស្សជាច្រើនបែបនេះហើយ។ ដោយសារមានល្ងីល្ងើតាប៉ៃបែបនេះ ដែលសាសនារបស់គេមានតែនៅក្នុងពាក្យសម្តីដែលទុច្ចរិតហើយ

អសារឥតការនៅក្នុងការសន្ទនារបស់ពួកគេ ដែល(ទទួលស្គាល់ច្រើននៅក្នុងចំណោមការប្រកបរបស់ពួកបរិសុទ្ធ) ដែលធ្វើឱ្យលោកិយជំពប់ដួល ដែលធ្វើឱ្យមានស្នាមដល់គ្រីស្ទាន ហើយធ្វើឱ្យទុកព្រួយដល់ភាពស្មោះត្រង់។ ខ្ញុំប្រាថ្នាចង់ឱ្យមនុស្សទាំងអស់នឹងដោះស្រាយជាមួយមនុស្សបែបនោះដូចដែលអ្នកបានធ្វើដែរ។ បន្ទាប់មកពួកគេនឹងអាចកាន់តែសុខស្រួលថែមទៀតជាមួយនឹងសាសនា ឬជាគ្នារបស់ពួកបរិសុទ្ធនឹងទៅជាក្តៅសម្រាប់ពួកគេវិញ។

បន្ទាប់មកស្មោះត្រង់បាននិយាយថា

"របៀបដែលសាំញ៉ាំបានទាញបន្ទាត់របស់គាត់មកដំបូង។ ការដែលគាត់និយាយដោយក្លាហានយ៉ាងណា! កាលដែលគាត់ស្មានថានឹងដេញអ្នកផ្សេងទៀតដែលនៅមុខគាត់ទៅយ៉ាងណា! តែបន្តិចមកកាលដែលស្មោះត្រង់និយាយជាកិច្ចការចេញពីចិត្ត ដូចជាព្រះច័ន្ទដែលឆ្លងផុតថ្ងៃពេញបូរមីចូលទៅក្នុងរលកនោះ ហើយដូចនេះមានតែអ្នកដែលធ្វើកិច្ចការចេញពីចិត្តទេដែលដឹង។"

ដូច្នេះពួកគេបានដើរបន្តទៅទៀតដោយជជែកគ្នាពីអ្វីដែលពួកគេបានឃើញនៅតាមផ្លូវ ហើយធ្វើឱ្យដំណើររបស់ពួកគេកាន់តែស្រួល ជាផ្លូវដែលដោយគ្មានចម្ងល់អាចនឹងគួរឱ្យធុញទ្រាន់បំផុត ដោយសារពេលនោះពួកគេបានឆ្លងកាត់ទីរហោស្ថាន។

## ការជម្រុញលើកទឹកចិត្តនិងការទស្សទាយន៍របស់អ្នកផ្សាយដំណឹងល្អ

នៅពេលនេះកាលដែលគេទៅជិតផុតទីរហោស្ថានហើយនោះ ស្មោះត្រង់បានយកភ្នែកមើលមកក្រោយ ហើយបានឃើញម្នាក់ដែលលកំពុងតែដេញតាមពួកគេ ហើយគាត់បានស្គាល់គាត់។ "អូ" ស្មោះត្រង់បាននិយាយទៅកាន់បងប្អូនរបស់គាត់ថា "តើអ្នកណាដែលមកនោះ?" បន្ទាប់មកគ្រីស្ទានបានមើលទៅ ហើយនិយាយថា "គឺជាសំឡាញ់របស់ខ្ញុំឈ្មោះ អ្នកផ្សាយដំណឹងល្អ"។ "អេ ជាសំឡាញ់របស់ខ្ញុំដែរតើ" ស្មោះត្រង់បានពោលដូច្នេះ "គាត់ជាអ្នកដែលប្រាប់ខ្ញុំឱ្យមកតាមផ្លូវទៅកាន់ឃ្លោងទ្វារនេះ។" ពេលនេះអ្នកផ្សាយដំណឹងល្អបានមកទាន់ពួកគេ ហើយបានរាក់ទាក់ជាមួយពួកគេ។

អ្នកផ្សាយដំណឹងល្អ៖ សូមឱ្យសេចក្តីសុខសាន្តបាននៅជាមួយនឹងអ្នក សំឡាញ់របស់ខ្ញុំអើយ ហើយសូមឱ្យសេចក្តីសុខសាន្តបាននៅជាមួយអ្នកដែលជួយដល់អ្នកដែរ!

គ្រីស្ទាន៖ សូមស្វាគមន៍ ស្វាគមន៍ សំឡាញ់ផ្សាយដំណឹងល្អរបស់ខ្ញុំអើយ! ទឹកមុខរបស់អ្នកនាំឱ្យខ្ញុំចង់ចាំពីសេចក្តីសប្បុរសរបស់អ្នកពីបុរាណ និងពលកម្មដែលមិនចេះហត់របស់អ្នកសម្រាប់ការល្អដ៏អស់កល្បជានិច្ចរបស់ខ្ញុំ។

ស្មោះត្រង់៖ "ហើយស្វាគមន៍មួយពាន់ដង" ស្មោះត្រង់បានពោលដូច្នេះ "មានគ្នាដូចជាអ្នក អូអ្នកផ្សាយដំណឹងល្អអើយ តើជាការដែលយើងប្រាថ្នាចង់បានយ៉ាងណាទៅសម្រាប់អ្នកធ្វើធម្មយាត្រាដ៏កំសត់ដូចជាយើងនេះ!"

អ្នកផ្សាយដំណឹងល្អ៖ បន្ទាប់មកអ្នកផ្សាយដំណឹងល្អបាននិយាយថា "តើមានអ្វីកើតឡើងដល់អ្នកដែរ មិត្តអើយ តាំងពីយើងចែកផ្លូវគ្នាមកនោះ? តើអ្នកបានជួបជាមួយអ្វីខ្លះ ហើយតើអ្នកបានប្រព្រឹត្តបែបម៉េចដែរ?"

បន្ទាប់មកគ្រីស្ទាននិងស្មោះត្រង់បានប្រាប់គាត់គ្រប់រឿងដែលបានកើតឡើងដល់ពួកគេនៅតាមផ្លូវ ហើយពីសេចក្តីលំបាកអ្វីខ្លះនិងលំបាកយ៉ាងណាខ្លះដែលគេបានជួបរហូតមកដល់ទីនោះ។

អ្នកផ្សាយដំណឹងល្អ៖ "ខ្ញុំពិតជាមានអំណរណាស់" អ្នកផ្សាយដំណឹងល្អបានិយាយបែបនេះ "មិនមែនដែលអ្នកបានជួបនឹងទុក្ខលំបាកទេ តែដោយអ្នកបានយកឈ្នះបាន និងដោយការដែលអ្នកមានផង (មិនថាដោយមានសេចក្តីកំសោយយ៉ាងច្រើនក៏ដោយ) នៅតែបន្តនៅតាមផ្លូវរហូតមកដល់ថ្ងៃនេះ។ ខ្ញុំបាននិយាយហើយថាខ្ញុំរីករាយពិតពីការនេះ ហើយដោយយល់អ្នកនិងខ្ញុំផង។ ខ្ញុំបានសាបព្រោះ ហើយអ្នកបានច្រូតកាត់ ហើយថ្ងៃនោះនឹងមកដល់ដែលអ្នកដែលសាបព្រោះនិងអ្នកដែលច្រូតកាត់នឹងអរសប្បាយជាមួយគ្នា។ គឺប្រសិនបើអ្នកនៅបន្ត ដោយសារដល់ពេលវេលា នោះអ្នកនឹងច្រូតកាត់បាន ប្រសិនបើអ្នកមិនរសាយចិត្តទេ។ មកុដនៅចំពោះអ្នក ហើយវាមិនចេះខូចទេ។ ដូច្នេះចូរអ្នករត់ទៅនោះអ្នកនឹងបានទទួលវា។ មានមនុស្សមួយចំនួនដែលចេញមកចង់បានមកុដនេះ ហើយបន្ទាប់ពីគេបានចេញមកឆ្ងាយដើម្បីវាហើយ មានអ្នកផ្សេងទៀតមកហើយដណ្តើមវាយកពីគេទៅ! ដូច្នេះសូមកាន់ឱ្យជាប់នូវអ្វីដែលអ្នកមាន កុំឱ្យអ្នកណាយកមកុដរបស់អ្នកឡើយ។"

“អ្នកណាដែលច្រូតនោះបានរង្វាន់ ក៏ប្រមូលផលសម្រាប់ជីវិតដ៏នៅអស់កល្បជានិច្ច ដើម្បីឱ្យអ្នកដែលព្រោះ និងអ្នកដែលច្រូត បានអរសប្បាយផងគ្នា។” យ៉ូហាន 4:36

“កុំឱ្យយើងណាយចិត្តនឹងធ្វើការល្អឡើយ ដ្បិតបើមិនរសាយចិត្តទេ នោះដល់កំណត់យើងនឹងច្រូតបានហើយ។” កាឡាទី 6:9

“តើអ្នករាល់គ្នាមិនដឹងទេឬអី ថាពួកអ្នកដែលរត់នៅទីប្រណាំង គេរត់ទាំងអស់គ្នា ប៉ុន្តែមានតែមួយទេដែលបានរង្វាន់ ដូច្នេះ ចូររត់បែបឱ្យបានរង្វាន់ចុះ។ ហើយអស់អ្នកដែលតយុទ្ធគ្នា គេខំអត់សង្កត់ចិត្តគ្រប់ជំពូក គឺធ្វើដូច្នេះដើម្បីឱ្យបានតែភួងជ័យដែលត្រូវពុករលួយ ទៃយើងរាល់គ្នាវិញ គឺឱ្យបាមកុដមួយដែលមិនចេះពុករលួយឡើយ ។ បានជាខ្ញុំខំរត់យ៉ាងដូច្នោះ មិនបែបដូចជាមិនស្គាល់ផ្លូវទេ ខ្ញុំក៏ខំប្រដាល់យ៉ាងដូច្នោះដែរ មិនមែនដូចជាដាល់ខ្យល់ទេ។ គឺខ្ញុំវាយដំរូបកាយខ្ញុំ ទាំងបង្ខំឱ្យចុះចូល ក្រែងក្រោយដែលខ្ញុំបានប្រដៅមនុស្សឯទៀតហើយ នោះខ្លួនខ្ញុំត្រូវចោលចេញវិញ។” កូរិនថូសទី១ 9:24-27

“មើល អញមកជាឆាប់ហើយ ចូរកាន់ខ្ជាប់តាមសេចក្តីដែលឯងមានហើយចុះ ដើម្បីកុំឱ្យអ្នកណាយកមកុដរបស់ឯងបានឡើយ។” វិវរណៈ 3:11

អ្នកមិនទាន់ចេញផុតពីគ្រាប់កាំភ្លើងរបស់អារក្សនូវឡើយទេ អ្នកមិនទាន់បានប្រយុទ្ធដោយចេញឈាមនូវឡើយ ដែលព្យាយាមប្រឆាំងទាស់នឹងអំពើ

បាប។ សូមឱ្យអាណាចក្ររបស់ព្រះបាននៅខាងមុខអ្នក ហើយជឿរឹងមាំនូវការដែលអ្នកមើលមិនឃើញ។ សូមកុំឱ្យអ្វីដែលនៅម្ខាងនៃលោកិយនេះចូលទៅក្នុងខ្លួនអ្នកឡើយ។ ហើយលើសពីនោះទៀត មើលទៅក្នុងចិត្តរបស់អ្នកឱ្យបានល្អ និងតណ្ហារបស់អ្នកផង ដោយសារពួកវាជាសេចក្តីបញ្ឆោតលើសជាងការទាំងអស់ ហើយក៏អាក្រក់បំផុត។ ចូរដាក់មុខរបស់អ្នកដូចជាកាំបិតមុតស្រួច។ អ្នកមានគ្រប់ចេស្តាទាំងនៅស្ថានសួគ៌និងនៅផែនដីនៅខាងអ្នកហើយ។"

បន្ទាប់មកគ្រីស្ទានបានអរគុណគាត់ដែលបានផ្តល់ការជម្រុញលើកទឹកចិត្ត ហើយបានប្រាប់គាត់ទាំងប៉ុន្មាន ដែលពួកគេចង់ឱ្យគាត់និយាយច្រើនទៀតប្រាប់ពួកគេ សម្រាប់ជាចំនួយរបស់ពួកគេដល់ទីបំផុតនៃផ្លូវ ហើយលើសពីនោះទៀត ដោយថាពួកគេបានដឹងច្បាស់ថា គាត់ជាហោរាម្នាក់ ហើយអាចប្រាប់ពួកគេពីការដែលអាចនឹងកើតឡើងដល់ពួកគេ ហើយពីរបៀបដែលពួកគេអាចនឹងគេចផុតនិងយកឈ្នះលើការទាំងនោះ។ ដែលស្មោះត្រង់បានសំណូមពរនិងយល់ស្របផងដែរ។ ដូច្នេះអ្នកផ្សាយដំណឹងល្អបានចាប់ផ្តើមដូចតទៅ

អ្នកផ្សាយដំណឹងល្អ៖ កូនរបស់ខ្ញុំអើយ អ្នកបានស្តាប់ឮព្រះបន្ទូលនៃសេចក្តីពិតនៃដំណឹងល្អ ដែលអ្នកត្រូវ "ដោយឆ្លងកាត់សេចក្តីលំបាកវេទនាជាច្រើនដើម្បីចូលទៅក្នុងនគរស្ថានសួគ៌។" ហើយម្តងទៀត នៅគ្រប់ទីក្រុងទាំងអស់ចំណងនិងសេចក្តីទុក្ខលំបាកដែលនៅជាប់នឹងអ្នក ហើយដូច្នេះអ្នកមិនត្រូវសង្ឃឹមថាអ្នកនឹងធ្វើធម្មយាត្រានេះដោយគ្មានជួបការទាំងនេះឡើយ នៅក្នុងប្រភេទមួយចំនួនឬបែបផ្សេងទៀត។ អ្នកបានរកឃើញអ្វីមួយពីសេចក្តីពិតពី

ទីបន្ទាល់ទាំងនេះដែលនៅលើអ្នករួចរាល់ហើយ ហើយច្រើនទៀតនឹងមកតាមភ្លាម។ ដោយសារពេលនេះ ដូចដែលអ្នកឃើញថា អ្នកស្ទើរតែចេញផុតពីទីរហោស្ថាននេះហើយ ហើយដូច្នេះអ្នកនឹងទៅដល់ក្រុងមួយភ្លាម ដែលអ្នកនឹងជួបពីមួយទៅមួយនៅចំពោះអ្នក ហើយនៅក្រុងនោះអ្នកនឹងមិនងាយនឹងត្រូវសត្រូវធ្វើបាបណាស់ ជាសត្រូវដែលនឹងខិតខំប្រឹងប្រែងយ៉ាងខ្លាំងតែពួកគេនឹងសម្លាប់អ្នក។ តែអ្នកត្រូវប្រាកដថា មានម្នាក់ឬអ្នកទាំងពីរត្រូវតែបោះត្រានូវទីបន្ទាល់ដែលអ្នកកាន់ដោយនូវឈាមនោះ តែអ្នកត្រូវតែស្មោះត្រង់រហូតដល់ស្លាប់ចុះ នោះស្តេចទ្រង់នឹងប្រទានមកុដជីវិតដល់អ្នក។ អ្នកដែលនឹងត្រូវស្លាប់នៅទីនោះ តើទោះជាការស្លាប់មិនមែនតាមបែបធម្មជាតិក៏ដោយ ហើយសេចក្តីឈឺចាប់របស់គាត់អាចជាខ្លាំងក៏ដោយ គាត់នៅតែប្រសើរជាងអ្វីដែលជារបស់គ្នាគាត់ផង មិនមែនដោយសារត្រឹមតែគាត់នឹងមកដល់ទីក្រុងបរិសុទ្ធឆាប់នោះទេ តែដោយសារគាត់នឹងគេចផុតពីសេចក្តីលំបាកជាច្រើនដែលអ្នកផ្សេងទៀតនឹងជួបរហូតដល់ផុតនៃការធ្វើដំណើរនេះ។ តែនៅពេលដែលអ្នកមកដល់ក្រុង ហើយនឹងឃើញថាត្រូវបានសម្រេចអ្វីដែលខ្ញុំបាននិយាយទាក់ទងរួចហើយនៅទីនេះ បន្ទាប់មកចូរចង់ចាំពីមិត្តរបស់អ្នក ហើយធ្វើខ្លួនដូចជាមនុស្សប្រុស ហើយតាំងចិត្តរក្សាព្រលឹងរបស់អ្នកសម្រាប់ព្រះរបស់អ្នកដោយធ្វើការល្អ ដូចសម្រាប់ព្រះអាទិករដ៏ស្មោះត្រង់ផង។

## ពិព័រណ៍នៃការឥតប្រយោជន៍

បន្ទាប់មកខ្ញុំបានឃើញនៅក្នុងសុបិនរបស់ខ្ញុំថា នៅពេលដែលពួកគេចេញផុតពីវាលរហោស្ថាន ពេលនេះពួកគេបានឃើញទីក្រុងមួយនៅចំពោះពួកគេ ហើយឈ្មោះរបស់ទីក្រុងនោះគឺ "ការឥតប្រយោជន៍"។ ហើយនៅទីក្រុងនោះមានការរក្សាយ៉ាងត្រឹមត្រូវដែលហៅថា "ពិព័រណ៍នៃការឥតប្រយោជន៍"។ វាត្រូវបានរក្សាពេញមួយឆ្នាំហើយ។ វាមានឈ្មោះថា ពិព័រណ៍នៃការឥតប្រយោជន៍ ដោយសារទីក្រុងដែលវាត្រូវបានរក្សាវាស្រាលជាង ការឥតប្រយោជន៍ហើយក៏ដោយសារអ្វីដែលនៅទីនោះត្រូវបានលក់អស់ ឬអ្វីដែលចេញមកពីទីនោះជាការអសាឥតការទទេរ។ ប្រៀបដូចជាពាក្យរបស់អ្នកប្រាជ្ញពោលថា "ការទាំងអស់ដែលចេញមកជាការឥតប្រយោជន៍។"

"អស់ទាំងសាសន៍រាប់ដូចជាទទេសោះនៅចំពោះទ្រង់ ទ្រង់រាប់គេទុកដូចជាតិចជាងសូន្យទៅទៀត ហើយជាឥតប្រយោជន៍ផង។" **អេសាយ 40:17**

"ការឥតប្រយោជន៍ទទេៗ នេះជាពាក្យរបស់គ្រូប្រដៅពោលទុកថា ការឥតប្រយោជន៍ទទេៗ គ្រប់ទាំងអស់សុទ្ធតែអត់ប្រយោជន៍ទទេ" **សាស្ដា 1:2**

"យើងបានឃើញបណ្តាការដែលមានធ្វើនៅក្រោមថ្ងៃ ហើយមើល ការទាំងនោះសុទ្ធតែឥតប្រយោជន៍ទទេ ក៏ជាអសារឥតការផង" **សាស្ដា 1:14**

“គ្រានោះ យើងបានត្រួតមើលគ្រប់ទាំងការដែលដៃយើងបានធ្វើ និងការនឿយហត់ដែលយើងបានខំបង្កើតនោះ ហើយមើល សុទ្ធតែឥតប្រយោជន៍ ហើយអសារឥតការទទេ ឥតមានផលប្រយោជន៍អ្វីនៅក្រោមថ្ងៃឡើយ។” សាស្តា 2:11

“ហេតុនោះ យើងបានស្អប់ជីវិត ពីព្រោះការដែលបានធ្វើនៅក្រោមថ្ងៃ ជាការលំបាកដល់យើង ដ្បិតការទាំងអស់សុទ្ធតែឥតប្រយោជន៍ ហើយជាអសារឥតការទទេ។” សាស្តា 2:17

“អើ បើមនុស្សណារស់នៅជាយូរឆ្នាំ នោះគួរឱ្យ មានសេចក្តីអំណរចំពោះគ្រប់ឆ្នាំទាំងនោះចុះ តែត្រូវឱ្យ នឹកដល់អស់ទាំងថ្ងៃ ដែលមានសេចក្តីងងឹតដែរ ពីព្រោះនឹងមានជាច្រើនទៀត គ្រប់ទាំងអស់ដែលត្រូវមក សុទ្ធតែជាការឥតប្រយោជន៍ទទេ។” សាស្តា 11:8

នេះមិនមែនជាការដែលត្រូវសាងមកថ្មីៗនេះទេ តែជាការដែលមាននៅតាំងតែពីបុរាណមកម្ល៉េះ។ ខ្ញុំនឹងបង្ហាញពីប្រភពដើមរបស់វា។

ស្ទើរតែប្រាំពាន់ឆ្នាំមុខមកម្ល៉េះ មានអ្នកធ្វើធម្មយាត្រាម្នាក់ដែលដើរទៅកាន់ទីក្រុងបរិសុទ្ធ ដូចជាបុរសស្មោះត្រង់ទាំងពីរនាក់នេះដែរ និងបីលសេប៊ុល អាប៉ូឡេអ៊ុង និង ពួកកងទ័ព ជាមួយនឹងបក្សពួករបស់ពួកគេ ដោយមើលឃើញផ្លូវដែលអ្នកធ្វើធម្មយាត្រារៀបចំមក ដែលផ្លូវរបស់ពួកគេឆ្លងកាត់ទីក្រុងរបស់អសាឥតការ នោះពួកគេត្រូវបង្ខំឱ្យរៀបចំភារកិច្ចនៅទីនេះ ជាកិច្ចការ

ដែលត្រូវលក់របស់ទាំងអស់ដែលឥតប្រយោជន៍គ្រប់ប្រភេទ ហើយដែលវាត្រូវនៅជាប់ជាយូរឆ្នាំ។ ដូច្នេះដោយសារកិច្ចការនេះសុទ្ធតែជាទំនេញដែលលក់ចេញ ដូចជាផ្ទះ ដី ជំនួញ ទីកន្លែង កិត្តិយស អ្វីដែលប្រាថ្នាចង់បានតំណែង ប្រទេស នគរ តណ្ហា សេចក្ដីរីករាយ និងការអរសប្បាយគ្រប់ប្រភេទ ប្រៀបដូចជាស្ត្រីសំផឹង មេស្រីខូច ប្រពន្ធ ប្ដី កូន ចៅហ្វាយ អ្នកបម្រើជីវិត ឈាម រូបរាងកាយ ព្រលឹង ប្រាក់ មាស គុជ ថ្មមានតម្លៃ និងអ្វីក្រៅពីនោះទៀត។

ហើយលើសពីនោះទៀត នៅក្នុងកិច្ចការនេះមានអ្នកបោកបញ្ឆោតគ្រប់ពេលវេលា ការបោកប្រាស់ ល្បែងស៊ីសង ការលេងសើច សេចក្ដីល្ងង់ខ្លៅ សត្វស្វាអេបស៍ មនុស្សខិលខូច និងការបោកប្រាស់ និងការគ្រប់ប្រភេតដូចនោះ។

នេះជាការដែលនឹងត្រូវឃើញផងដែរ ដែលវាមិនមានប្រយោជន៍អ្វីទាំងអស់ គឺការលួចប្លន់ ការសម្លាប់ សេចក្ដីកំផឹត ស្បថដោយខុសឆ្គង និងអ្វីដែលមានឈាមក្រហម។

ហើយដូចជានៅក្នុងកិច្ចការផ្សេងទៀតដែលមានពេលតិចបំផុត មានជួរជាច្រើននិងផ្លូវមួយចំនួន នៅក្រោមឈ្មោះដែលសាកសមរបស់ពួកគេ នៅកន្លែងដែលទំនេញទាំងនោះត្រូវលក់ចេញទៅ។ ដូច្នេះនៅទីនេះអ្នកមានទីកន្លែង ជួរ ផ្លូវនានាដែលសាកសម (ដូចជា ប្រទេស និងនគរផ្សេងៗ) ជាកន្លែងដែលទំនេញនៃជំនួញនោះត្រូវរកឃើញយ៉ាងរហ័សបំផុត។ នេះគឺជាជួររបស់ពួកអង់គ្លេស ជួររបស់បារាំង ជួររបស់អ៊ីតាលី ជួរអេស្ប៉ាញ ជួរអាឡឺ

ម៉ង់ ជាកន្លែងដែលការឥតប្រយោជន៍ជាច្រើនត្រូវលក់ចេញ។ តែសម្រាប់ជំនួញផ្សេងទៀតវិញ ផលិតផលណាមួយដែលជាមេលើអស់ទាំងជំនួយដូច្នេះទំនេញរបស់ក្រុងរ៉ូម ហើយនឹងទំនេញរបស់នាងត្រូវបានគេផ្សព្វផ្សាយយ៉ាងខ្លាំងនៅក្នុងជំនួញនេះ។ មានតែជនជាតិអស់គ្លេសយើងទេ និងអ្នកផ្សេងទៀតមិនបានចូលចិត្តទីនោះឡើយ។

ពេលនេះដូចដែលខ្ញុំបាននិយាយហើយ ផ្លូវទៅកាន់ទីក្រុងបរិសុទ្ធលាតសន្ធឹងតាមទីក្រុងនេះ ជាកន្លែងដែលមានជំនួញខាងសេចក្តីតណ្ហាត្រូវបានរក្សា ហើយអ្នកដែលចូលទៅទីក្រុងនោះ ហើយមិនដើរតាមក្រុងនេះ នោះត្រូវចាកចេញពីលោកិយនេះទៅ។

**"តែពាក្យនោះមិនសំដៅចំពោះមនុស្សកំផិតរបស់ផងលោកីយ៍នេះ ឬមនុស្សលោភ មនុស្សប្លន់កំហែង ឬមនុស្សថ្វាយបង្គំរូបព្រះនោះទេ ដ្បិតបើដូច្នោះនោះត្រូវតែចេញឱ្យ ផុតពីលោកីយ៍នេះទៅ" កូរិនថូសទី១ 5:10**

ស្តេចលើទាំងស្តេចផ្ទាល់ កាលនៅទីនេះបានឆ្លងកាត់ក្រុងនេះទៅកាន់ប្រទេសរបស់ទ្រង់ផ្ទាល់ ហើយនៅថ្ងៃដែលភ្លឺចេសផងដែរ ហើយតាមខ្ញុំគិតវាជាប៊ីលសេប៊ុល ដែលជាមេនៃជំនួញនេះ ដែលបានអញ្ជើញគាត់ឱ្យទិញការឥតប្រយោជន៍របស់វាទាំងនេះ។ ដែលនឹងធ្វើឱ្យវាបានក្លាយជាមេលើជំនួញនេះ ចង់ឱ្យគេផ្តល់ការគោរពដល់វានៅពេលដែលគេឆ្លងកាត់ទីក្រុងនោះ។ ហើយដោយសារទ្រង់ជាម្នាក់ដែលមានកិត្តិយស បីលសេប៊ុលបាននាំទ្រង់ពីផ្លូវមួយទៅផ្លូវមួយ ហើយបង្ហាញទ្រង់នូវគ្រប់នគរនៃផែនដីទាំង

អស់នៅក្នុងពេលដ៏ខ្លី ដែលថា បើអាចទៅរួចត្រូវគេល្បួងឱ្យបាន ព្រះដ៏មានពរនេះបានបញ្ចុះតម្លៃនិងទិញការដែលឥតប្រយោជន៍មួយចំនួនពីគេ។ តែទ្រង់មិនមានគំនិតចង់បានទំនិញទាំងនោះទេ ដូច្នេះក៏បានចាកចេញពីទីក្រុងនោះដោយមិនបានបន្សល់ទុកអ្វីច្រើនសូម្បីតែក៏មិនទុកនៅលើការឥតប្រយោជន៍ទាំងនោះដែរ។

"មួយទៀត អារក្សបាននាំទ្រង់ទៅលើកំពូលភ្នំយ៉ាងខ្ពស់ ក៏បង្ហាញអស់ទាំងនគរក្នុងលោកីយ៍ និងសិរីលំអរបស់នគរទាំងនោះថ្វាយទ្រង់ទត" ម៉ាថាយ 4:8

"អារក្សក៏នាំទ្រង់ទៅលើកំពូលភ្នំយ៉ាងខ្ពស់ បង្ហាញនគរនៅលោកីយ៍ទាំងអស់ក្នុង១ភ្លែតនោះ។ ហើយទូលថា ខ្ញុំនឹងឱ្យ អំណាច និងសិរីលំអនៃនគរទាំងនេះដល់អ្នក ដ្បិតបានប្រគល់មកខ្ញុំហើយ ខ្ញុំនឹងឱ្យ ដល់អ្នកណាស្រេចនឹងចិត្តខ្ញុំ។ ដូច្នេះ បើអ្នកក្រាបថ្វាយបង្គំខ្ញុំ នោះទាំងអស់នឹងបានជារបស់អ្នក" លូកា 4:5-7

ដូច្នេះជំនួញនេះជាការពីបុរាណ ដែលជាប់ជាយូរអង្វែងហើយជាជំនួញមួយយ៉ាងធំ។

ពេលនេះអ្នកធ្វើធម្មយាត្រាទាំងនេះ ដូចដែលខ្ញុំបាននិយាយហើយ ថាត្រូវតែឆ្លងកាត់តាមជំនួញនេះ ដូច្នេះពួកគេបានឆ្លងកាត់មែន។ តែមើលទៅ បើទោះជាពួកគេបានចូលទៅក្នុងជំនួញនោះ មានមនុស្សជាច្រើនដែលនៅក្នុង

ជំនួញនោះមានការភ្ញាក់ផ្អើល ហើយទីក្រុងផ្ទាល់ប្រៀបដូចជានៅក្នុង
ចលាចលមកក្បែរពួកគេ នោះដោយសារហេតុផលមួយចំនួន។ ដោយសារ

ទីមួយ អ្នកធ្វើធម្មយាត្រាស្លៀកពាក់សំលៀកបំពាក់មួយប្រភេទដែលខុសពីសំលៀកបំពាក់របស់អ្នកផ្សេងទៀតដែលធ្វើជំនួញនោះ។ ដូច្នេះមនុស្សដែលធ្វើជំនួញនោះធ្វើការសម្លឹងមើលពួកគេយ៉ាងខ្លាំង។ អ្នកខ្លះនិយាយថាពួកគេជាមនុស្សល្ងង់ អ្នកខ្លះថាពួកគេជាមនុស្សឆ្កួត ហើយអ្នកខ្លះទៀតថាជាពួកដែលចម្លែក។

ទីពីរ ហើយនៅពេលដែលពួកគេកំពុងតែគិតឆ្ងល់ពីសំលៀកបំពាក់របស់ពួកគេ ដូច្នេះពួកគេក៏គិតដូចគ្នាទៅលើពាក្យសម្ដីរបស់ពួកគេផងដែរ។ ដោយសារមានមនុស្សតិចទេដែលអាចយល់នូវអ្វីដែលពួកគេនិយាយ។ ជាធម្មតាពួកគេនិយាយភាសារបស់ពួកកាណាន តែពួកគេនៅរក្សាជំនួញនោះជាមនុស្សនៅក្នុងលោកិយនេះ ដូច្នេះចាប់ពីចុងម្ខាងនៃជំនួញទៅម្ខាងទៀតពួកគេហាក់ដូចជាពួកមនុស្សព្រៃពីមនុស្សម្នាក់ទៅម្នាក់ទៀត។

**"គឺនិយាយតាមតែប្រាជ្ញានៃព្រះវិញ ជាសេចក្ដីអាថ៌កំបាំងដ៏លាក់ទុក ដែលព្រះបានគិតគូ តាំងពីមុនអស់ទាំងកល្ប សម្រាប់ជាសិរីល្អដល់យើងរាល់គ្នា។ គ្មានចៅហ្វាយណាក្នុងលោកីយ៍នេះបានស្គាល់សេចក្ដីអាថ៌កំបាំងនោះឡើយ បើបានស្គាល់ នោះគេមិនបានឆ្កាងព្រះអម្ចាស់ដ៏មានសិរីទេ" កូរិនថូស ទី១ 2:7, 8**

ទីបី តែការដែលធ្វើឱ្យពួកអ្នកធ្វើជំនួញភ្ញាក់ផ្អើលខ្លាំងនោះគឺ អ្នកធ្វើធម្មយាត្រាទាំងនេះមិនសូវមានទំនេញរបស់ពួកគេសោះ ពួកគេមិនចង់នឹងមើលទៅកាន់របស់ទាំងអស់នោះផង ហើយប្រសិនបើស្រែកហៅឱ្យទិញ ពួកគេនឹងយកដៃបិតត្រចៀក ហើយស្រែកថា "សូមបង្វែរភ្នែករបស់ខ្ញុំកុំឱ្យមើលការដែលឥតប្រយោជន៍ទាំងនេះ។" ហើយបានសម្លឹងមើលទៅខាងលើ ដែលជាសញ្ញាថាជំនួញរបស់ពួកគេនិងការធ្វើដំណើររបស់ពួកគេគឺនៅស្ថានសួគ៌។

"សូមបង្វែរភ្នែកទូលបង្គំមិនឱ្យ មើលការឥតប្រយោជន៍ ហើយប្រោសឱ្យ ទូលបង្គំមានកម្លាំងឡើងក្នុងផ្លូវទ្រង់" **ទំនុកដំកើង 119:37**

"ចុងបំផុតរបស់គេជាសេចក្តីហិនវិនាស គេយកពោះគេទុកជាព្រះ ហើយយកសេចក្ដីគួរខ្មាសរបស់គេ ទុកជាសិរីល្អ វិញ គេនឹកតែពីរបស់នៅផែនដីនេះ។ ឯយើងរាល់គ្នា យើងជាសាសន៍ស្ថានសួគ៌វិញ ក៏នៅចាំព្រះអម្ចាស់យេស៊ូវគ្រីស្ទ ជាព្រះអង្គសង្គ្រោះ ទ្រង់យាងមកពីស្ថាននោះឯង" **ភីលីព 3:19, 20**

មានម្នាក់និយាយដោយចំអក សម្លឹងមើលរទេះរបស់មនុស្ស ហើយនិយាយទៅកាន់ពួកគេ ដើម្បីនឹងនិយាយទៅកាន់ពួកគេថា "តើអ្នកនឹងទិញអ្វី?" ប៉ុន្តែពួកគេបានមើលទៅកាន់គាត់យ៉ាងម៉ឺងម៉ាត់ ហើយនិយាយថា "យើងទិញសេចក្តីពិត។"

**“ចូរទិញសេចក្ដីពិតចុះ កុំឱ្យ លក់ចេញឡើយ អើទាំងប្រាជ្ញា សេចក្ដីដំបូន្មាន និងយោបល់ផង។” សុភាសិត 23:23**

ដោយការនោះមានឱកាសដែលត្រូវមើលងាយដល់បុរសទាំងនោះថែមទៀត អ្នកខ្លះចំអក អ្នកខ្លះធ្វើទុក្ខបុកម្នេញ ខ្លះនិយាយខិតមកជិត ហើយខ្លះទៀតហៅរកអ្នកផ្សេងទៀតមកវាយពួកគេ។ ជាចុងក្រោយ រឿងក៏ត្រូវជាអ៊ូអរហើយមានការច្របូកច្របល់ជាខ្លាំងនៅទីជំនួញនោះ ខ្លាំងពេលរហូតដល់គ្មានរបៀបរៀបរយសោះ។ ឥឡូវមានពាក្យដែលនាំមកដល់អ្នកធំបំផុតនៅទីជំនួញនោះ ដែលគាត់បានចេញមកយ៉ាងរហ័ស ហើយឈ្លោះប្រកែកជាមួយនឹងមិត្តដែលគាត់ទុកចិត្តបំផុត ឱ្យយកបុរសទាំងនេះទៅធ្វើការស៊ើបសួរ អំពីអ្នកដែលជំនួញស្ទើរតែត្រូវក្រឡាប់ចាក់។ ដូច្នេះពួកគេក៏ត្រូវយកទៅស៊ើបសួរ ហើយអ្នកដែលអង្គុយនៅខាងលើបានសួរពួកគេថា ពួកគេមកពីពេលណា តើពួកគេទៅណា ហើយតើពួកគេធ្វើអ្វីនៅទីនោះនៅក្នុងសំលៀកបំពាក់ដែលខុសប្លែកពីគេនេះ?
បន្ទាប់មកបុរសទាំងពីរប្រាប់ពួកគេថា ពួកគេជាអ្នកធ្វើធម្មយាត្រា និងជាអ្នកបរទេសនៅក្នុងផែនដីនេះ ហើយពួកគេកំពុងទៅកាន់ប្រទេសរបស់ពួកគេដែលជាប្រទេសយេរូសាឡិមស្ថានសួគ៌។

**“ពួកអ្នកទាំងនោះបានស្លាប់ក្នុងសេចក្ដីជំនឿ ឥតទទួលសេចក្ដីដែលបានសន្យាទាំងប៉ុន្មានទេ តែគេបានឃើញពីចម្ងាយ ហើយក៏ទទួលគំនាប់ដែរ ទាំងយល់ព្រមថា ខ្លួនគេជាអ្នកដទៃ ដែលគ្រាន់តែសំណាក់ នៅផែនដីប៉ុណ្ណោះ។ ពួកអ្នកដែលនិយាយដូច្នោះ នោះសម្ដែងថា គេជាអ្នករកស្រុកសម្រាប់ខ្លួនគេ**

ពិត។ ហើយបើសិនជាគេរឭកស្រុក ដែលគេទើបនឹងចេញមកនោះ នោះគេនឹងមានឱកាសត្រឡប់ទៅវិញបាន។ តែឥឡូវនេះ គេសង្វាតចង់បានស្រុក១ដ៏ប្រសើរជាង គឺខាងស្ថានសួគ៌វិញ បានជាព្រះទ្រង់គ្មានសេចក្ដីខ្មាស ដោយគេហៅទ្រង់ជាព្រះនៃគេនោះឡើយ ដ្បិតទ្រង់បានរៀបចំទីក្រុង១ឱ្យ គេហើយ។" ហេព្រើរ 11:13-16

ហើយពួកគេមិនទុកឱកាសអោយអ្នកក្រុងនិងអ្នកលក់ដូរធ្វើបាបពួកគេឡើយ ហើយទុកអោយពួកគេធ្វើដំណើរទៅ។ លើកលែងតែ ព្រោះនៅពេលដែលមនុស្សម្នាក់សួរពួកគេពីអ្វីដែលពួកគេនឹងទិញ ពួកគេបាននិយាយថាពួកគេនឹងទិញសេចក្ដីពិត។ ប៉ុន្តែអ្នកដែលត្រូវបានតែងតាំងឱ្យពិនិត្យមើលពួកគេមិនជឿថា ពួកគេជាអ្នកចេះដឹងតែឆ្កួត ឬក៏អ្វីមួយផ្សេងទៀត ដូចជាបានមកធ្វើឱ្យមានភាពច្របូកច្របល់នៅក្នុងពិព័រណ៍នោះទេ។ ពួកគេចាប់ពួកគេវាយធ្វើបាប ហើយលាបធូលីដីដាក់ពួកគេ រួចដាក់ពួកគេចូលក្នុងទ្រុងឱ្យពួកគេបានសម្ដែងការចាប់អារម្មណ៍ចំពោះមនុស្សទាំងអស់ដែលនៅក្នុងពិព័រណ៍។ ដូច្នេះនៅទីនោះ ពួកគេបាននៅទីនោះអស់ពេលមួយរយៈ ហើយត្រូវបានគេធ្វើឱ្យទៅដូចជាវត្ថុនៃកីឡារបស់មនុស្ស ឬការស្អប់ខ្ពើមឬការសងសឹកវិញ។ ហើយម្នាក់ដែលធំអស្ចារ្យជាងគេនៅពិព័រណ៍បានសើចរហូតនូវអ្វីដែលបានកើតឡើងដល់ពួកគេ។

ប៉ុន្តែមនុស្សទាំងពីរមានភាពអត់ធ្មត់និងមិនបង្ហាញការតក់ស្លុតអ្វីទេ តែផ្ទុយទៅវិញប្រទានពរ និងនិយាយពាក្យល្អៗសម្រាប់អំពើអាក្រក់ និងមានចិត្តល្អចំពោះការដែលធ្វើឱ្យគេរងរបួសវិញ ដែលបានធ្វើមនុស្សខ្លះនៅក្នុងពិព័រណ៍

ដែលបានសង្កេតនិងមិនសូវប្រកាន់ដូចអ្នកដទៃទៀត បានចាប់ផ្តើមត្រួតពិនិត្យ ស៊ីបន្ទោសប្រភេទមូលដ្ឋាននៃការធ្វើបាបជាបន្តទៅកាន់បុរសទាំងពីរ។ ហេតុដូច្នេះ ក្នុងសភាពដែលខឹងសម្បារពួកគេមករកបុរសទាំងពីរម្តងទៀត ដោយរាប់ពួកគេជាមនុស្សអាក្រក់ដូចដូចបុរសនៅក្នុងទ្រុងដែរ ហើយប្រាប់ពួកគេថាពួកគេហាក់ដូចជាច្របូកច្របល់ ហើយគួរតែធ្វើជាអ្នកចូលរួមនៃសំណាងអាក្រក់របស់ពួកគេ។ ម្នាក់ទៀតឆ្លើយថា ទាល់តែពួកគេអាចមមើលឃើញបាន ពួកគេក៏នៅស្ងៀមហើយដឹងខ្លួន ហើយមិនបង្កគ្រោះថ្នាក់ដល់អ្នកណាឡើយ។ ហើយថាមានមនុស្សជាច្រើនដែលបានជួញដូរនៅក្នុងពិព័រណ៍របស់ពួកគេ ដែលសក្តិសមនឹងត្រូវគេដាក់ចូលក្នុងទ្រុង ហើយមានការចំអកឡកឡឺយឱ្យផងដែរ ច្រើនជាងបុរសដែលពួកគេបានធ្វើបាបទៅទៀត។ ដូច្នេះបន្ទាប់ពីពាក្យផ្សេងៗគ្នាបានកន្លងផុតទៅទាំងសងខាង បុរសទាំងនោះបានប្រព្រឹត្តខ្លួនជាមនុស្សឆ្លាតតាំងពីពេលនោះហើយដឹងខ្លួនឡើងវិញនៅចំពោះពួកគេ។ ពួកគេបានឈ្លោះប្រកែកគ្នានិងធ្វើបាបគ្នាទៅវិញទៅមក។

បន្ទាប់មកបុរសកំសត់ទាំងពីរនេះត្រូវបាននាំយកមកនៅចំពោះអ្នកត្រួតពិនិត្យម្តងទៀត និងមានការចោទប្រកាន់ថាមានទោសដែលបង្កការចលាចលមុននេះនៅក្នុងពិព័រណ៍។ ដូច្នេះគេបានវាយដំពួកគេដោយគ្មានអាណិត ហើយព្យួរដែកនៅលើពួកគេ ហើយដឹកពួកគេដោយច្រវ៉ាក់លើក្រោមនៅកន្លែងពិព័រណ៍ធ្វើជាគម្រូ និងជាការភ័យខ្លាចដល់អ្នកផ្សេងទៀត ដើម្បីកុំឱ្យអ្នកផ្សេងទៀតនិយាយអ្វីសម្រាប់ពួកគេទៀត ឬចូលរួមបក្សពួកជាមួយពួកគេទៀត។ ប៉ុន្តែគ្រីស្ទាននិងស្មោះត្រង់ប្រព្រឹត្តខ្លួនកាន់តែមានប្រាជ្ញាថែម

ទៀត ហើយបានទទួលសេចក្តីអាម៉ាស់ដែលដាក់មកលើពួកគេដោយសេចក្តីស្លូតបូតនិងការអត់ធ្មត់ ដែលពួកគេបានឈ្នះ បើប្រៀបធៀបទៅនឹងអ្នកផ្សេងទៀត មនុស្សមួយចំនួននៅក្នុងពិព័រណ៍។ ការនេះបានធ្វើឱ្យមនុស្សមួយបក្សទៀតខឹងសម្បារយ៉ាងខ្លាំង ខ្លាំងរហូតដល់ពួកគេចង់បញ្ចប់ជីវិតរបស់បុរសទាំងពីរ។ ដូច្នេះពួកគេបានធ្វើការគម្រាមថា ទ្រុងឬដែលត្រូវប្តូរវេនគ្នា តែពួកគេនឹងត្រូវស្លាប់ដោយសារការធ្វើបាបដែលពួកគេបានធ្វើ និងដោយសារការបញ្ឆោតដល់មនុស្សដែលនៅពិព័រណ៍។

បន្ទាប់មកពួកគេត្រូវយកទៅដាក់ក្នុងទ្រុងម្តងទៀត រហូតដល់បានធ្វើបន្ថែមទៀតដាក់ពួកគេ។ ដូច្នេះពួកគេបានដាក់ពួកគាត់ចូលទៅក្នុង ហើយធ្វើឱ្យជើងរបស់ពួកគេជាប់ទៅនឹងរនាំង។

ដូច្នេះនៅទីនេះពួកគេបាននឹងឃើញម្តងទៀត នូវអ្វីដែលពួកគេបានឮចេញពីសំឡាញ់ស្មោះត្រង់របស់ពួកគេឈ្មោះអ្នកផ្សាយដំណឹងល្អ ហើយពួកគេបានបញ្ជាក់ច្បាស់លាស់នៅក្នុងផ្លូវរបស់ពួកគេនិងការរងទុក្ខរបស់ពួកគេដោយសារការដែលបានប្រាប់មកដល់ពួកគេថានឹងត្រូវកើតឡើង។ ពេលនេះពួកគេក៏ត្រូវបានកំសាន្តចិត្តរៀងៗខ្លួន ដែលចំណែករបស់ពួកគេគឺត្រូវតែរងទុក្ខ ហើយដែលគេត្រូវតែទទួលបានការដែលល្អបំផុត។ ដូច្នេះម្នាក់ៗបានប្រាថ្នាដោយសម្ងាត់រៀងៗខ្លួនថា ពួកគេនឹងមានចិត្តប្រាថ្នាចង់បានការល្អនោះជាង តែបានតាំងខ្លួនរបស់ពួកគេទៅរកព្រះអង្គដែលគ្រប់គ្រងលើការទាំងអស់វិញ ដោយមានសេចក្តីស្កប់ស្កល់នៅក្នុងសភាពដែលពួកគេបានជួបនេះ រហូតដល់ពួកគេអាចយកឈ្នះបាន។

## ការលំបាកវេទនា

បន្ទាប់ម ពេលវេលាដ៏សាកសមមួយត្រូវបានកំណាត់ទុក ពួកគេបាននាំមកពួកគេទៅកាន់សេចក្ដីលំបាកវេទនារបស់ពួកគេ ដើម្បីជាសេចក្ដីជំនុំជំរះរបស់ពួកគេ។ នៅដែលពេលមកដល់ ពួកគេត្រូវបាននាំមកនៅចំពោះខ្មាំងសត្រូវរបស់ពួកគេ និងត្រូវចោទប្រកាន់។ ឈ្មោះរបស់ចៅក្រមនោះគឺ ព្រះអម្ចាស់ដែលស្អប់ការល្អ។ សេចក្ដីចោទប្រកាន់របស់ពួកគេមានធាតុតែមួយទេ បើទោះជាវាមានទ្រង់ទ្រាយខុសគ្នាក៏ដោយ តែខ្លឹមសារគឺដូចគ្នា។

ដែលថាពួកគេជាសត្រូវ និងជាអ្នករំខាននៃជំនួញរបស់ពួកគេ ដែលពួកគេបានបង្ករចលាចលនិងការបែកបាក់គ្នានៅក្នុងទីក្រុង ហើយបានដណ្ដើមយកមួយបក្សធ្វើជារបស់គេជាគំនិតមួយដ៏គ្រោះថ្នាក់បំផុត ដែលមានការប៉ុនប៉ងនៃច្បាប់ក្រឹតក្រមរបស់ស្ដេចរបស់ពួកគេ។

បន្ទាប់មកស្មោះត្រង់ចាប់ឆ្លើយថា អ្នកដែលតាំងខ្លួនទាស់នឹងមួយអង្គដែលខ្ពស់ជាងអ្នកដែលខ្ពស់បំផុតនោះ "ហើយ" គាត់បាននិយាយថា "សម្រាប់ការរំខាននោះ ខ្ញុំមិនបានបង្ករឡើងទេ ដោយសារខ្ញុំជាមនុស្សខាងសេចក្ដីសុខសាន្តវិញ។ បក្សពួកដែលមកតាមយើងវិញ មកតាមដោយសារបានសម្លឹងមើលទៅកាន់សេចក្ដីពិតនិងភាពស្អាតស្អំរបស់យើង ហើយពួកគេគ្រាន់តែប្រែចេញពីការអាក្រក់ជាងមកគ្រាន់បើបន្តិចប៉ុណ្ណោះ។ ចំណែកស្ដេចដែលអ្នកនិយាយនោះ ក្នុងកាលដែលគេជាប៊ីលសេប៊ុល ជាសត្រូវរបស់ព្រះអម្ចាស់របស់យើង ខ្ញុំទាស់នឹងគេ ហើយនិងទេវតារបស់គេទាំងអស់។"

សេចក្តីប្រកាសត្រូវបានចេញមកថា ពួកគេត្រូវនិយាយសម្រាប់ព្រះអម្ចាស់របស់ពួកគេទាស់នឹងអ្នកទោសដែលនៅក្នុងគុក ត្រូវតែបង្ហាញមកនូវភស្តុតាងរបស់ពួកគេ។ ដូច្នេះក៏មានសាក្សីចូលមកចំនួនបីនាក់គឺ ច្រណែន លោកជឿលើអាភិនិហារ និង អរគុណដោយរើស។ ពួកគេត្រូវបានសួរថា តើពួកគេបានស្គាល់អ្នកទោសដែលនៅក្នុងគុកទេ? និងអ្វីដែលពួកគេបាននិយាយសម្រាប់ព្រះអម្ចាស់ជាស្តេចរបស់ពួកគេទាស់នឹងគេ?

ច្រណែន៖ បន្ទាប់មកច្រណែនក៏ឈរចេញមក ហើយនិយាយបែបនេះ "លោកម្ចាស់ខ្ញុំអើយ ខ្ញុំបានស្គាល់បុរសម្នាក់នេះពីយូរណាស់មកហើយ ហើយនឹងអះអាងសេចក្តីសម្បថរបស់ខ្ញុំនៅចំពោះតុដ៏មានកិត្តិយសនេះដែលថាគាត់"

ព្រះអម្ចាស់ស្អប់ការល្អ ជាចៅក្រម៖ ចាំសិន ចូរផ្តល់សេចក្តីសម្បថរបស់គាត់ដល់គាត់ទៅ!

ដូច្នេះពួកគេបានស្បថជាមួយទ្រង់។ បន្ទាប់មកគាត់និយាយថា "លោកម្ចាស់ខ្ញុំអើយ បុរសនេះមិនដូចនឹងឈ្មោះដែលសាកសមនឹងគាត់ទេ ជាមនុស្សម្នាក់ក្នុងចំណោមមនុស្សដែលចម្លែកបំផុតនៅក្នុងប្រទេសរបស់យើង។ គាត់មិនខ្វល់ពីស្តេចឬពីប្រជាជននោះឡើយ ឬច្បាប់ ឬទំនៀមទម្លាប់ឡើយ តែធ្វើគ្រប់យ៉ាងដែលគាត់អាចធ្វើបានដើម្បីកាន់កាប់មនុស្សទាំងអស់ដោយភាពច្បាស់លាស់នៃការមិនគោរពដល់ជាតិសាសន៍ ដែលជាទូទៅគាត់ហៅគោលការណ៍នេះថា ជាសេចក្តីជំនឿនិងភាពបរិសុទ្ធ។ ហើយជាទូទៅ ខ្ញុំបានឮគាត់ផ្ទាល់ម្តងអះអាងថាសាសនាគ្រីស្ទាននិងទំនៀមទម្លាប់របស់ទី

ក្រុងរបស់យើងនៃសេចក្តីឥតប្រយោជន៍ ផ្ទុយគ្នាស្រឡះ ហើយមិនត្រូវផ្សារភ្ជាប់គ្នាបានឡើយ។ ដោយនិយាយថា ព្រះអម្ចាស់របស់ខ្ញុំ គាត់បានធ្វើភ្លាមមិនត្រឹមតែដាក់ទោសដល់គ្រប់ទាំងការដែលយើងធ្វើគួរឱ្យសរសើរនោះទេ តែពួកគេនៅក្នុងការដែលធ្វើការទាំងនោះទៀត។"

ចៅក្រមៈ បន្ទាប់មកចៅក្រមបាននិយាយទៅកាន់គាត់ថា "តើមានអ្នកណាមានអ្វីដែលត្រូវនិយាយទៀតទេ?"

ច្រណែនៈ "លោកម្ចាស់ខ្ញុំអើយ ខ្ញុំអាចនិយាយបានច្រើនទៀត កុំឱ្យតែខ្ញុំបានគួរឱ្យធុញនៅក្នុងសាលក្រមនេះចុះ។ តែយ៉ាងណាបើត្រូវការ នៅពេលដែលសុភាពបុរសម្នាក់ទៀតផ្តល់ភស្តុតាងរបស់គាត់មក ជាជាងការអ្វីដែលត្រូវការដែលនឹងរៀបរាប់ពីគាត់ នោះខ្ញុំនឹងពង្រីកទីបន្ទាល់របស់ខ្ញុំថែមទៀតទាស់នឹងគាត់។" ដូច្នេះគាត់ត្រូវបានប្រាប់ឱ្យឈរនៅក្បែរនោះ។

បន្ទាប់មកពួកគេបានហៅ លោកជឿលើអាភិនីហារមក ហើយប្រាប់គាត់ឱ្យមើលទៅកាន់អ្នកទោស ពួកគេក៏បានសួរទៅកាន់គាត់ពីអ្វីដែលគាត់អាចនិយាយសម្រាប់លោកម្ចាស់ដែលជាស្តេចរបស់ពួកគេទាស់នឹងគាត់? បន្ទាប់មកពួកគេសួរគាត់ ដូច្នេះគាត់ចាប់និយាយថា
លោកជឿលើអាភិនីហារៈ លោកម្ចាស់ខ្ញុំអើយ ខ្ញុំមិនមានទំនាក់ទំនងអ្វីអស្ចារ្យជាមួយបុរសនេះនោះទេ ខ្ញុំក៏មិនប្រាថ្នាចង់មានចំណេះដឹងអ្វីច្រើនទៀតពីគាត់នោះដែរ។ យ៉ាងណាក៏ដោយ ខ្ញុំដឹងថា គាត់ជាមនុស្សម្នាក់ដែលអាចធ្វើឱ្យស្លាប់បាន ដោយមានការពិភាក្សាគ្នាខ្លះនៅថ្ងៃមួយនោះដែលខ្ញុំបាននិយាយជាមួយគាត់នៅក្នុងទីក្រុងនេះ កាលនោះ បាននិយាយជាមួយគាត់

ខ្ញុំបានឮគាត់និយាយថាសាសនារបស់យើងជាការទទេរ ហើយមិនអាចនឹងផ្គាប់ព្រះហឫទ័យដល់ព្រះបានឡើយ។ ការនិយាយរបស់គាត់ លោកម្ចាស់អើយ ភាពជាម្ចាស់របស់ទ្រង់បានស្គាល់អ្វីដែលចាំបាច់ដែលនឹងត្រូវតាមមកហើយគឺ ថាយើងនៅតែថ្វាយបង្គំដោយឥតប្រយោជន៍ នៅតែរស់នៅក្នុងអំពើបាប ហើយជាចុងក្រោយនឹងត្រូវជំនុំជំរះ ហើយនេះជាអ្វីដែលខ្ញុំត្រូវនិយាយហើយ។

បន្ទាប់មកអរគុណដោយរើសត្រូវបានសាកសួរ ហើយត្រូវប្រាប់ឱ្យ និយាយអ្វីដែលគាត់បានដឹងជំនួសមុខឱ្យម្ចាស់របស់គេដែលជាស្តេចទាស់នឹងអ្នកទោសនៅក្នុងគុក។

អរគុណរើស៖ លោកម្ចាស់ខ្ញុំអើយ និងសុភាពបុរសទាំងអស់គ្នា ខ្ញុំបានស្គាល់បុរសនេះជាយូរណាស់មកហើយ ហើយបានឮគាត់និយាយការដែលគាត់មិនត្រូវនិយាយ។ ដោយសារគាត់បានបះបោរទាស់នឹងស្តេចដ៏ថ្លៃថ្នូរបីលសេប៊ុលរបស់យើង ហើយបាននិយាយដោយស្អប់ខ្ពើមដល់មិត្តសំឡាញ់ដែលមានកេរ្តិ៍ឈ្មោះរបស់យើង ដែលមានឈ្មោះដូចជា លោកម្ចាស់បុរសចំណាស់ លោកម្ចាស់នៃសេចក្តីអំណរខាងសាច់ឈាម លោកម្ចាស់ដែលឡូយឆាយ លោកម្ចាស់បំណងប្រាថ្នាការឥតប្រយោជន៍ លោកម្ចាស់ចាស់របស់ខ្ញុំលោកមិនល្មោភកាម លោកមានសេចក្តីលោភលន់ ជាមួយនឹងអ្នកខ្ពង់ខ្ពស់ផ្សេងៗទៀត ហើយគាត់បាននិយាយថែមទៀតថា ប្រសិនបើមនុស្សទាំងអស់មានគំនិតដូចគាត់ បើអាចទៅរួច នឹងមិនមានអ្នកធំណាមួយនឹងបន្តរស់នៅក្នុងទីក្រុងនេះទៀតឡើយ។ ក្រៅពីនោះ គាត់មិនខ្លាចនឹងបះបោរទាស់នឹងលោកម្ចាស់ឡើយ ដែលទ្រង់ត្រូវបានតែងតាំងធ្វើជា

ចៅក្រមនេះ ដោយហៅទ្រង់ថាអ្នកទាស់ដែលមិនកោតខ្លាចព្រះ ដោយប្រើពាក្យសម្ដីផ្សេងទៀតដែលអង្អាប់ដល់ឈ្មោះ សម្រាប់នឹងនិយាយប៉ះពាល់យ៉ាងខ្លាំងបំផុតដល់អ្នកមានមុខមាត់នៅទីក្រុងរបស់យើង។

នៅពេលអរគុណដោយរើសនេះបានប្រាប់ពីរឿងរបស់គាត់មក ចៅក្រមបានបង្វែរការអធិប្បាយរបស់គាត់ទៅកាន់អ្នកទោសដែលនៅក្នុងគុក ដោយពោលថា "ឯងជាអ្នកបះបោរ ខុសឆ្គង និងជនក្បត់! តើឯងបានឮអ្វីដែលសុភាពបុរសស្មោះត្រង់ទាំងនេះបាននិយាយទាស់នឹងឯងទេ?"

ស្មោះត្រង់៖ តើខ្ញុំអាចនិយាយការពារខ្លួនបន្តិចបានទេ?

ចៅក្រម៖ ស៊ីរ៉ា ស៊ីរ៉ា! ឯងមិនសមនឹងរស់បន្តទៀតឡើយ តែបើសម្លាប់ភ្លាមៗនៅទីនេះ ដែលមនុស្សទាំងអស់នឹងឃើញភាពទន់ភ្លន់របស់យើងទៅកាន់ឯង ចូរឱ្យយើងបានស្ដាប់ឯងដែលជាជនបះបោរចម្លែកនេះនឹងមានអ្វីនឹងត្រូវនិយាយសិនចុះ។

ស្មោះត្រង់៖ 1. ខ្ញុំនិយាយដោយឆ្លើយនូវអ្វីដែលលោកច្រណៃនបាននិយាយថា ខ្ញុំមិនដែលនិយាយអ្វីក្រៅពីនេះឡើយគឺថា អ្វីដែលជាច្បាប់ ឬក្រឹត្យវិន័យ ឬទំនៀមទម្លាប់ ឬមនុស្ស ដែលទាស់នឹងព្រះបន្ទូលរបស់ព្រះ គឺផ្ទុយស្រលះទៅនឹងសាសនាគ្រីស្ទ។ ប្រសិនបើខ្ញុំបាននិយាយអ្វីក្រៅពីនេះ សូមប្រាប់នូវកំហុសរបស់ខ្ញុំផង ហើយខ្ញុំនៅទីនេះរួចរាល់នឹងធ្វើការបដិសេធវិញនៅចំពោះអ្នក។

2. សម្រាប់ទីពីរវិញគឺ លោកជឿលើអភិនីហារ និងការចោទប្រកាន់របស់គាត់ទាស់នឹងខ្ញុំ។ ខ្ញុំនិយាយតែប៉ុណ្ណោះទេ ថាការថ្វាយបង្គំព្រះត្រូវការសេចក្ដីជំនឿមកពីព្រះ តែមិនមានសេចក្ដីជំនឿមកពីព្រះណាក្រៅពីការបើកសម្ដែងរបស់ព្រះពីបំណងព្រះហឫទ័យរបស់ព្រះឡើយ។ ដូច្នេះ អ្វីដែលជាចាក់ចូលមកនៅក្នុងការថ្វាយបង្គំព្រះ ដែលមិនស្របតាមការបើកសម្ដែងរបស់ព្រះមិនអាចនឹងធ្វើឡើងបានឡើយ តែដោយសេចក្ដីជំនឿរបស់មនុស្ស ដែលជាសេចក្ដីជំនឿដែលមិនផ្ដល់នូវជីវិតអស់កល្បជានិច្ចឡើយ។

3. ទៅកាន់លោក អរគុណដោយរើសវិញ ដែលបាននិយាយ ខ្ញុំនិយាយថាការវាងពីពាក្យសម្ដី ដែលថាខ្ញុំបាននិយាយទាស់បែបអីចឹង ថាស្ដេចរបស់ក្រុងនេះ ជាមួយនឹងមនុស្សមួយហ្វូងទៀត ជាបរិវាររបស់គាត់ ដោយនូវឈ្មោះសុភាពបុរសម្នាក់នេះ គឺសុទ្ធតែសាកសមនឹងនៅក្នុងស្ថាននរកជាជាងនៅក្នុងទីក្រុងនិងប្រទេសនេះ ហើយដូច្នេះសូមព្រះអម្ចាស់ផ្ដល់សេចក្ដីមេត្តាដល់ខ្ញុំផង!

បន្ទាប់មកចៅក្រមបានហៅទៅកាន់គណៈវិនិច្ឆ័យ--ជាអ្នកដែលកំពុងឈរនៅទីនោះ ដើម្បីនិងស្ដាប់និងសង្កេតមើល "សុភាពបុរសម្នាក់ក្នុងចំណោមគណៈវិនិច្ឆ័យ អ្នកឃើញហើយថាបុរសនេះដែលបង្កនូវការច្របូលច្របល់នៅក្នុងទីក្រុងនេះ អ្នកក៏បានឮដែរថាសុភាពបុរសដែលថ្លៃថ្នូទាំងនេះបានធ្វើបន្ទាល់ទាស់នឹងគាត់ អ្នកក៏បានឮចម្លើយនិងការសារភាពរបស់គាត់ដែរ ពេលនេះវាស្ថិតនៅលើទ្រូងរបស់អ្នកហើយថានឹងឆ្កាងគាត់ ឬសង្គ្រោះជីវិតរបស់គាត់នោះ តែខ្ញុំគិតថានឹងណែនាំអ្នកនៅក្នុងក្រឹត្យវិន័យ។

"មានទង្វើមួយដែលបានធ្វើឡើងនៅក្នុងសម័យរបស់ស្តេចផារ៉ោនឱប្រេគ្គត ជាអ្នកបម្រើរបស់ស្តេចយើង ដើម្បីកុំឱ្យអ្នកដែលមានសាសនាខុសគ្នាត្រូវ បានលូតលាស់ធំធាត់ខ្លាំងពេកសម្រាប់ទ្រង់នោះឡើយ នោះពួកប្រុសៗ របស់គេនឹងត្រូវបោះចោលទៅក្នុងទន្លេទៅ។"

"តែសាសន៍អ៊ីស្រាអែលគេបង្កើតកូនដុះដាលចម្រើនជាច្រើនឡើង ក៏បានទៅ ជាស្តុកស្តម្ភឡើងសន្ធឹក ទាំងនៅកុះករពេញក្នុងស្រុកនោះ។នៅគ្រានោះ មាន ស្តេចថ្មី១អង្គសោយរាជ្យឡើងនៅស្រុកអេស៊ីព្ទ ស្តេចនោះមិនបានស្គាល់យ៉ូ សែបទេ។ ទ្រង់មានព្រះបន្ទូលទៅបណ្តារាស្ត្ររបស់ទ្រង់ថា មើល ពួកសាសន៍ អ៊ីស្រាអែលគេមានគ្នាច្រើន ក៏ស្តុកស្តម្ភជាងពួកយើងហើយ។ ចូរយើងប្រព្រឹត្ត នឹងគេដោយប្រាជ្ញា ក្រែងគេចម្រើនជាច្រើនឡើង ហើយបើកាលណាកើត មានចម្បាំង នោះគេនឹងចូលទៅខាងពួកខ្មាំងសត្រូវ ដើម្បីច្បាំងនឹងយើងវិញ រួចចេញពីស្រុកបាត់ទៅ។ ដូច្នេះ គេក៏ដាក់ឱ្យ មាននាយតម្រួត សម្រាប់នឹង ធ្វើទុក្ខដល់ពួកអ៊ីស្រាអែលដោយការនឿយលំបាកជាច្រើន ពួកអ៊ីស្រាអែល បានកសាងក្រុងពីថំ និងរ៉ាមសេស សម្រាប់ជាឃ្លាំងថ្វាយផារ៉ោន។ ប៉ុន្តែ ដែលធ្វើទុក្ខគេប៉ុណ្ណា នោះគេក៏ចម្រើនជាច្រើន ទាំងសាយពេញពាសឡើង ប៉ុណ្ណោះដែរ ហើយសាសន៍អេស៊ីព្ទមានសេចក្តីធុញទ្រាន់ ដោយព្រោះ សាសន៍អ៊ីស្រាអែល។ក៏ចាប់ប្រើគេឱ្យ ធ្វើការយ៉ាងតឹងរ៉ឹង។ ព្រមទាំងធ្វើឱ្យ ជីវិតគេ មានសេចក្តីជូរល្វីង ដោយការលំបាកវេទនា គឺប្រើឱ្យ ធ្វើបាយអ និង ឥដ្ឋ ព្រមទាំងការនៅចម្ការគ្រប់មុខផង ឯការដែលគេចាប់ប្រើឱ្យ ធ្វើទាំង ប៉ុន្មាននោះសុទ្ធតែការយ៉ាងតឹងរ៉ឹងទាំងអស់។ រួចស្តេចស្រុកអេស៊ីព្ទទ្រង់ក៏ បង្គាប់ដល់ពួកឆ្មបសាសន៍ហេព្រើរ ដែល១ឈ្មោះនាងស៊ីប្រា ហើយ១ទៀត

ឈ្មោះនាងពូអា ថាកាលណានាងទៅកាន់ពោះនៃពួកស្រីសាសន៍ហេព្រើរ ដែលសម្រាលកូន នោះក្នុងកាលដែលគេកំពុងតែសម្រាល បើជាកូននោះ ប្រុស ចូរសម្លាប់វាទៅ តែបើសិនជាស្រី នោះត្រូវទុកឱ្យ រស់នៅចុះ។ ប៉ុន្តែ ឆ្មប ទាំងនោះជាអ្នកកោតខ្លាចដល់ព្រះ គេមិនបានធ្វើតាមបង្គាប់នៃស្តេចស្រុកអេ ស៊ីព្ទនោះឡើយ គឺបានទុកកូនប្រុសៗឱ្យ រស់នៅវិញ។ ឯស្តេចស្រុកអេស៊ីព្ទក៏ ហៅឆ្មបទាំងនោះមកសួរថា ហេតុអ្វីបានជាធ្វើយ៉ាងដូច្នេះ គឺដែលទុកកូនប្រុ សៗឱ្យ រស់នៅនេះ។ ឆ្មបទូលឆ្លើយទៅផារ៉ោនថា គឺពីព្រោះពួកស្រីសាសន៍ ហេព្រើរមិនមែនដូចជាស្រីសាសន៍អេស៊ីព្ទទេ គេរហ័សណាស់ ដ្បិតឆ្មបមិន ទាន់ទាំងមកដល់ផង នោះគេបានសម្រាលរួចជាមុនទៅហើយ។ដូច្នេះ ព្រះ ទ្រង់ក៏ប្រទានពរដល់ឆ្មបទាំងនោះ ឯពួកសាសន៍អ៊ីស្រាអែលគេកាន់តែ ចម្រើនជាច្រើនឡើង ត្រឡប់ទៅជាមានកម្លាំងគ្រប់ជំពូក។ ហើយដោយព្រោះ ពួកឆ្មបនោះមានសេចក្តីកោតខ្លាចដល់ព្រះ បានជាទ្រង់ចម្រើនពូជឱ្យ គេ។”

**និក្ខមនំ 1:7-22**

ក៏មានទង្វើមួយកើតឡើងនៅក្នុងសម័យរបស់ស្តេចនេកាប៊ូនេសាឌិប្រេត្គ ជាអ្នកបម្រើរបស់ស្តេចយើងមួយទៀត ដែលថាអ្នកណាដែលមិនក្រាបចុះ និងថ្វាយបង្គំរូបមាស នឹងត្រូវបោះចូលទៅក្នុងគុកភ្លើងដ៏ក្តៅសន្ធោសន្ធៅ។

“រីឯស្តេចនេប៊ូក្នេសាទ្រង់ធ្វើរូបមាស១ មានកំពស់៦០ហត្ថ ទទឹង៦ហត្ថ ទ្រង់ បញ្ឈររូបនោះនៅវាលឌូរ៉ាក្នុងខេត្តបាប៊ីឡូន។ រួចស្តេចនេប៊ូក្នេសាទ្រង់ចាត់ឱ្យ ទៅប្រមូលពួកចៅហ្វាយខេត្ត ពួកភូឈួយ ពួកចៅហ្វាយស្រុក ពួកចៅក្រម ពួកមេឃ្លាំង ពួកបាឡាត់ ពួកនាយកនគរបាល និងអស់ទាំងពួកមន្ត្រីខេត្តទាំង

ប៉ុន្មាន ឱ្យ គេប្រមូលគ្នាមកឯបុណ្យឆ្លងរូប ដែលស្ដេចនេប៊ូក្នេសាតាំងឡើង នោះ។ ដូច្នេះ ពួកចៅហ្វាយខេត្ត ពួកភូឈ្មួយ ពួកចៅហ្វាយស្រុក ពួកចៅក្រម ពួកមេឃ្លាំង ពួកបាឡាត់ ពួកនាយកនគរបាល និងអស់ទាំងពួកមន្ត្រីខេត្ត ក៏មូលគ្នាមកឯបុណ្យឆ្លងរូបនោះ ដែលស្ដេចនេប៊ូក្នេសាតាំងឡើង គេក៏ឈរនៅចំពោះរូបដែលទ្រង់តាំងទុកនោះ។ រួចមានអ្នក១ស្រែកប៉ាវប្រកាស ជាសំឡេងយ៉ាងខ្លាំងថា ម្នាលជនទាំងឡាយ ព្រមទាំងសាសន៍ដទៃ និងមនុស្សគ្រប់ភាសាអើយ មានសេចក្ដីបង្គាប់ដល់អ្នករាល់គ្នាដូច្នេះថា។ វេលាណាដែលអ្នករាល់គ្នាឮស្នូរត្រែ ខ្លុយ ស៊ុង ចាប៉ី ពិណ និងប៉ី ហើយដន្ត្រីគ្រប់យ៉ាង នោះត្រូវក្រាបថ្វាយបង្គំដល់រូបមាស ដែលព្រះករុណាទ្រង់បានតាំងឡើងទៅ។ បើអ្នកណាមិនក្រាបថ្វាយបង្គំទេ នោះនឹងត្រូវបោះទៅកណ្ដាលគុកភ្លើង ដែលកំពុងឆេះយ៉ាងសន្ធៅនៅវេលានោះឯង។ ដូច្នេះ នៅវេលានោះ កាលជនទាំងឡាយបានឮស្នូរត្រែ ខ្លុយ ស៊ុង ចាប៉ី ពិណ និងដន្ត្រីគ្រប់យ៉ាងហើយ នោះជនទាំងឡាយព្រមទាំងសាសន៍ដទៃ និងមនុស្សគ្រប់ភាសាផង ក៏ក្រាបថ្វាយបង្គំដល់រូបមាស ដែលស្ដេចនេប៊ូក្នេសាបានតាំងទុកនោះ។នៅគ្រានោះ មានពួកខាល់ដេខ្លះចូលទៅជិតប្ដឹងពីពួកសាសន៍យូដា។ គេទូលដល់ស្ដេចនេប៊ូក្នេសាថា បពិត្រព្រះករុណា សូមឱ្យ ទ្រង់មានព្រះជន្មតរៀងទៅ។ បពិត្រព្រះករុណាទ្រង់បានចេញព្រះរាជបង្គាប់ថា អស់មនុស្សណាដែលឮស្នូរត្រែ ខ្លុយ ស៊ុង ចាប៉ី ពិណ ប៉ី និងដន្ត្រីគ្រប់យ៉ាង នោះត្រូវតែក្រាបថ្វាយបង្គំដល់រូបមាសនេះ។ ហើយថា បើអ្នកណាមិនក្រាបថ្វាយបង្គំទេ នោះត្រូវបោះទៅក្នុងគុកភ្លើងដែលឆេះយ៉ាងសន្ធៅ។ រីឯក្នុងពួកអ្នកដែលទ្រង់បានតាំងឡើង លើក្រសួងការខេត្តបាប៊ីឡូន នោះមានពួកសាសន៍យូដាខ្លះ គឺសាដ្រាក់ មែសាក់ និងអ័បេឌ-នេកោ ទាំង៣នាក់នោះ បពិត្រព្រះករុណា គេមិនបានស្ដាប់បង្គាប់ទ្រង់ទេ គេក៏

មិនទាំងគោរពប្រតិបត្តិដល់ព្រះនៃទ្រង់ ឬថ្វាយបង្គំដល់រូបមាស ដែលទ្រង់បានតាំងឡើងនោះដែរ។ហេតុនោះ នេប៊ូក្នេសាទ្រង់មានសេចក្តីក្រោធ និងសេចក្ដីឃោរឃៅយ៉ាងក្រៃលែង ក៏បង្គាប់ឱ្យ គេនាំសាដ្រាក់ មែសាក់ និងអ័បេឌ-នេកោមក ដូច្នេះ គេក៏នាំអ្នកទាំង៣នោះចូលមកនៅចំពោះស្ដេច។នេប៊ូក្នេសាទ្រង់មានព្រះបន្ទូលសួរគេថា ម្នាលសាដ្រាក់ មែសាក់ និងអ័បេឌ-នេកោ តើដោយបំណងចិត្តឬ ដែលឯងរាល់គ្នាមិនគោរពដល់ព្រះនៃយើង ឬថ្វាយបង្គំដល់រូបមាសដែលយើងបានតាំងឡើងហើយនោះ។ ឥឡូវនេះ បើឯងរាល់គ្នាប្រុងប្រៀបក្នុងវេលាណាដែលឮសូរត្រែ ខ្លុយ ស៊ុង ចាប៉ី ពិណ ប៉ី និងជន្រ្តីគ្រប់យ៉ាង ឱ្យ បានក្រាបថ្វាយបង្គំដល់រូបមាសដែលយើងបានធ្វើនេះ នោះបានហើយ តែបើមិនថ្វាយបង្គំទេ នោះនឹងត្រូវបោះឯងទៅក្នុងគុកភ្លើង ដែលឆេះយ៉ាងសន្ធៅ នៅវេលានោះឯង តើមានព្រះឯណាដែលអាចនឹងដោះឯងរាល់គ្នា ឱ្យ រួចពីកណ្តាប់ដៃយើងបាន។ តែសាដ្រាក់ មែសាក់ និងអ័បេឌ-នេកោទូលឆ្លើយដល់ស្ដេចថា បពិត្រព្រះរាជានេប៊ូក្នេសា យើងខ្ញុំមិនចាំបាច់ទូលឆ្លើយដល់ទ្រង់ពីដំណើរនេះទេ។ បើជាយ៉ាងនោះមែន នោះព្រះនៃយើងខ្ញុំដែលយើងខ្ញុំគោរពប្រតិបត្តិតាម ទ្រង់អាចនឹងជួយឱ្យ ខ្ញុំរួចពីគុកភ្លើង ដែលឆេះយ៉ាងសន្ធៅបានហើយ បពិត្រព្រះករុណា ព្រះអង្គនោះក៏នឹងជួយឱ្យ យើងរួចពីព្រះហស្តទ្រង់ដែរ។ តែបើមិនជួយទេ នោះសូមឱ្យ ទ្រង់ព្រះករុណាជ្រាបថា យើងខ្ញុំមិនព្រមគោរពតាមព្រះរបស់ទ្រង់ឡើយ ក៏មិនព្រមថ្វាយបង្គំដល់រូបមាស ដែលទ្រង់បានតាំងឡើងនោះដែរ។” **ដានីយ៉ែល 3:1-18**

ក៏មានទង្វើដែលកើតឡើងនៅក្នុងសម័យរបស់ស្ដេចដារៀសដែរ ដែលគាត់

ក៏បានធ្វើដូច្នេះដែរ ពេលណាដែលអ្នកណាបានស្រែកហៅទៅកាន់ព្រះ អម្ចាស់ណាក្រៅពីព្រះរបស់គាត់ នឹងត្រូវបោះចូលទៅក្នុងរូងសត្វតោហើយ។

"ឯដារីយុសទ្រង់សព្វព្រះទ័យនឹងតាំងចៅហ្វាយខេត្ត១២០នាក់ឡើង ឱ្យ ត្រួតត្រាលើនគរ ជាពួកអ្នកដែលត្រូវផ្សាយចេញទៅនៅពេញក្នុងនគរទាំងមូល។ ហើយឱ្យ មានអធិបតី៣នាក់ត្រួតលើចៅហ្វាយទាំងនោះ ដើម្បីឱ្យ គេរាប់រៀបប្រាប់ដល់ពួក៣នាក់នោះ ប្រយោជន៍មិនឱ្យ ស្តេចត្រូវខូចខាតឡើយ ឯដានីយ៉ែលលោកក៏នៅក្នុងពួកអធិបតីនោះដែរ។ រួចមកដានីយ៉ែលបានត្រឡប់ជាកំពូលលើពួកអធិបតី និងពួកចៅហ្វាយទាំងប៉ុន្មាន ដ្បិតលោកមានវិញ្ញាណយ៉ាងស្រួចស្រាល់ ហើយស្តេចទ្រង់គិតនឹងតាំងលោកឱ្យ ត្រួតលើនគរទាំងមូល។ ដូច្នេះ ពួកអធិបតី និងពួកចៅហ្វាយក៏ស្វែងរកហេតុពីដំណើររាជការផែនដី ឱ្យ ទាស់នឹងដានីយ៉ែល តែគេរកឱកាស ឬកំហុសអ្វីមិនបានឡើយ ក៏មិនឃើញមានថ្លស់ធ្លោយ ឬទោសទាស់អ្វីដែរ ពីព្រោះលោកជាមនុស្សស្មោះត្រង់។ ដូច្នេះ ពួកអ្នកទាំងនោះប្រឹក្សាគ្នាថា យើងនឹងរកឱកាសទាស់នឹងឈ្មោះដានីយ៉ែលនេះមិនបានឡើយ វៀរតែរកបានខាងឯក្រឹត្យវិន័យរបស់ព្រះនៃវាប៉ុណ្ណោះ។ ពួកអធិបតី និងពួកចៅហ្វាយទាំងនោះ ក៏នាំគ្នាចូលទៅគាល់ស្តេចទូលដូច្នេះថា បពិត្រព្រះរាជាដារីយុស សូមឱ្យ ទ្រង់បានប្រកបដោយព្រះជន្មចម្រើនជាយឺនយូរតទៅ។ ពួកអធិបតីក្នុងនគរ ពួកចៅហ្វាយខេត្ត ពួកភូឈ្មួយពួកបាឡាត់ និងពួកចៅហ្វាយស្រុក បានជំនុំព្រមគ្នា ចង់តាំងព្រះរាជឱង្ការ១ច្បាប់ គឺជាសេចក្តីបំរាមយ៉ាងតឹងរ៉ឹងថា បើអ្នកណានឹងសូមអ្វីពីព្រះណា ឬពីមនុស្សណាក៏ដោយ វៀរតែសូមពីព្រះរាជាក្នុងរវាង៣០ថ្ងៃ នោះនឹងត្រូវបោះចោលទៅក្នុងរូងសិង្ហ។ បពិត្រព្រះរាជា ដូច្នេះ សូមទ្រង់តាំងច្បាប់ ហើយចុះ

ហត្ថលេខានៅច្បាប់នោះ ប្រយោជន៍មិនឱ្យ ផ្លាស់ប្រែបាន តាមរបៀបច្បាប់នៃសាសន៍មេឌី និងសាសន៍ពើស៊ី ដែលនឹងផ្លាស់ប្តូរមិនបានឡើយ។ ដូច្នេះ ស្តេចដារីយុសទ្រង់ក៏ចុះហត្ថលេខា នៅសំបុត្រជាសេចក្តីបំរាមនោះ។" **ដានីយ៉ែល 6:1-9**

ពេលនេះធាតុនៃច្បាប់ក្រឹត្យក្រមទាំងនេះ អ្នកបះបោរនេះធ្វើល្មើសហើយ មិនត្រឹមតែនៅក្នុងគំនិត (ដែលមិនត្រូវមានផង) តែក៏នៅក្នុងពាក្យសម្តីនិងទង្វើផង ដែលមិនត្រូវបន្ធូរបន្ថយទោសឱ្យឡើយ។

"ដោយសារផារ៉ោន ច្បាប់របស់ទ្រង់បានបង្កើតមកនៅលើសេចក្តីសង្ស័យ ដើម្បីការពារការបង្ករគ្រោះថ្នាក់ មិនមានទោសពេលណាដែលលេចមកទេ តែនៅទីនេះមានទោសមួយលេចឡើង។ ដោយសារទីពីរ ទីបី អ្នកបានឃើញការឈ្លោះប្រកែកទាស់នឹងសាសនារបស់យើង និងដោយសារការឃុបឃិតដែលកាត់បានសារភាព គាត់សាកសមនឹងស្លាប់។"

បន្ទាប់មកអ្នកjury បានចេញក្រៅ ដែលមានឈ្មោះថា លោកមនុស្សខ្វាក់ លោកមិនល្អសោះ លោកឃោឃៅ លោកស្រឡាញ់កាមតណ្ហា លោករស់ដោយធូររលុង លោកជាមេ លោកគំនិតខ្ពស់ លោកភាពជាសត្រូវ លោកកុហក លោកសាហាវ លោកស្អប់ពន្លឺ និងលោកគ្មានក្តីអាណិតអាសូរ ដែលជាអ្នកបានផ្តល់ការសម្រេចរៀងៗខ្លួនទាស់នឹងគាត់នៅក្នុងចំណោមពួកគេ ហើយបន្ទាប់មកបានសរុបដោយមិនច្បាស់លាស់ នាំឱ្យគាត់មានទោសនៅចំពោះចៅក្រម។ ជាដំបូងនៅក្នុងចំណោមពួកគេ លោកមនុស្សខ្វាក់ជា

មនុស្សដំបូងបាននិយាយថា "ខ្ញុំឃើញច្បាស់ថាមនុស្សនេះជាអ្នកមានជំនឿខុសឆ្គង។ បន្ទាប់មកលោកមិនមានការល្អសោះថា "សូមឱ្យមនុស្សបែបនេះចេញបាត់ពីផែនដីនេះទៅ" "អេហ៍" លោកឃោឃៅនិយាយថា "ដោយខ្ញុំស្អប់រូបរាងគ្រប់យ៉ាងរបស់គាត់ណាស់" បន្ទាប់មកលោកស្រឡាញ់កាមតណ្ហានិយាយថា "ខ្ញុំមិនអាចទ្រាំនឹងគាត់បានឡើយ" "ខ្ញុំក៏ទ្រាំមិនបានដែរ" លោកធូររលុងនិយាយបែបនេះ "ដោយសារគាត់តែងតែកាត់ទោសដល់ផ្លូវរបស់ខ្ញុំ" "ចូរឆ្កាងវាទៅ ឆ្កាងទៅ!" លោកជាមេបាននិយាយថា "ជាច្រាស់ដ៏អាក្រក់" លោកគំនិតខ្ពស់និយាយដូច្នេះ។ "ចិត្តរបស់ខ្ញុំឡើងទាស់នឹងគេ" លោកភាពជាសត្រូវនិយាយមក។ "គេជាមនុស្សចង្រៃ លោកកុហកបាននិយាយមក។ "ការឆ្កាងជាការល្អពន់ពេលសម្រាប់វាហើយ" លោកគ្មានសេចក្ដីមេត្តានិយាយដូច្នេះ "ខ្ញុំនឹងមានគ្រប់យ៉ាងដែលលោកិយនឹងផ្ដល់មកខ្ញុំ ខ្ញុំនឹងមិនត្រូវរួវជាមួយនឹងវាឡើយ ដូច្នេះចូរយើងយកកំហុសវាចេញមកឱ្យមានទោសដល់ស្លាប់ចុះ" ហើយគេក៏ធ្វើដូច្នោះ ដូច្នេះពេលនេះគាត់ត្រូវគេធ្វើទោសពីទីដែលគាត់កំពុងនៅទៅទីដែលគាត់បានមក ហើយនៅទីនោះគាត់ត្រូវបានគេសម្លាប់ដោយសេចក្ដីស្លាប់ដ៏ឃោឃៅបំផុតដែលធ្លាប់មាន។

ដូច្នេះពួកគេបាននាំគាត់ចេញ ដើម្បីនឹងធ្វើដាក់គាត់ទៅច្បាប់របស់ពួកគេ ហើយដំបូងពួកគេបានធ្វើទុក្ខបុកម្នេញគាត់ ហើយបន្ទាប់មកពួកគេវាយដំគាត់ បន្ទាប់មកពួកគេភ្លាស់សាច់របស់គាត់ដោយកាំបិត បន្ទាប់មកពួកគេបានចោលគាត់នឹងដុំថ្ម ហើយបានចាក់គាត់នឹងដាវរបស់ពួកគេ ហើយជាចុងក្រោយបង្អស់ពួកគេបានដុតគាត់ទៅជាផេះនៅគំនរនោះ។ ដូច្នេះស្មោះត្រង់ក៏មកដល់ទីបញ្ចប់របស់គាត់។ ពេលនេះខ្ញុំបានឃើញថា មានរទេះជា

ច្រើននិងសេះមួយចំនួនដែលរងចាំស្មោះត្រង់នៅខាងក្រោយ ដែលជាអ្នកភ្លាមៗដែលពួកសត្រូវបានផ្តាច់ជីវិតគាត់នោះ បានយកទៅក្នុងរទេះ ហើយត្រូវបានយកឡើងឆ្ពោះទៅលើពពកតែម្តង ជាមួយនឹងសម្លេងត្រែ ជាផ្លូវដ៏លឿនបំផុតទៅកាន់ឃ្លោងទ្វារស្ថានសួគ៌។ តែសម្រាប់គ្រីស្ទានវិញ គាត់មានភាពធូរស្បើយបន្តិច ហើយត្រូវបានយកទៅដាក់នៅក្នុងគុកវិញ ដូច្នេះគាត់បន្តនៅទីនោះមួយកន្លែង។ ប៉ុន្តែមួយអង្គដែលគ្រប់គ្រងលើការទាំងអស់ មានអំណាចដោយសារកំហឹងរបស់ទ្រង់នៅក្នុងព្រះហស្តរបស់ទ្រង់ ក៏បានហ៊ុមព័ទ្ធជុំវិញគ្រីស្ទាន ដោយសារពេលនេះ គាត់ក៏បានគេចរួចខ្លួនហើយទៅតាមផ្លូវរបស់គាត់ទៅ។

ហើយគាត់បានដើរទៅទាំងច្រៀងថា

"ពិតណាស់ស្មោះត្រង់អើយ អ្នកបានសារភាពដោយស្មោះត្រង់ទៅកាន់ព្រះអម្ចាស់របស់អ្នកហើយ ជាទ្រង់នឹងប្រទានពរដល់អ្នក នៅពេលដែលអ្នកដែលគ្មានជំនឿ នឹងទទួលបានសេចក្តីអំណរដោយអសារឥតការទទេ ដែលកំពុងតែស្រែកនៅក្នុងបញ្ហាដែលមកពីស្ថាននរក ចូរច្រៀងឡើងស្មោះត្រង់អើយច្រៀងឡើង! ហើយសូមឱ្យឈ្មោះរបស់អ្នកនៅជានិច្ច បើទោះជាពួកគេសម្លាប់អ្នកក៏ដោយ តែអ្នកនៅតែនៅរស់នៅឡើយ។"

ពេលនេះខ្ញុំបានឃើញនៅក្នុងសុបិនរបស់ខ្ញុំថា គ្រីស្ទានមិនមែនទៅមុខតែម្នាក់ឯងទេ ដោយសារមានម្នាក់ឈ្មោះពេញដោយក្តីសង្ឃឹម (ដោយបង្កើតបានមកដោយការសង្កេតមើលទៅគ្រីស្ទាននិងស្មោះត្រង់ នៅក្នុងពាក្យសម្តីនិងការប្រព្រឹត្តរបស់ពួកគេ នៅក្នុងសេចក្តីរងទុក្ខរបស់ពួកគេនៅទីតាំង

ពិព័រណ៍នោះ) ដែលបានដាក់ខ្លួនមកតាមគាត់ ហើយបានតាំងសញ្ញាធ្វើជាបងប្អូននឹងគ្នា ដែលបានប្រាប់គាត់ថានឹងធ្វើជាគ្នារបស់គាត់។ ដូច្នេះម្នាក់បានស្លាប់ដើម្បីនឹងធ្វើបន្ទាល់ពីសេចក្ដីពិត និងអ្នកផ្សេងទៀតបានលេចឡើងពីផេះរបស់គាត់ដើម្បីធ្វើជាគ្នាជាមួយនឹងគ្រីស្ទាននៅក្នុងការធ្វើធម្មយាត្រារបស់គាត់។ ពេញដោយសង្ឃឹមម្នាក់នេះក៏បានប្រាប់គ្រីស្ទានថា មានមនុស្សជាច្រើនទៀតនៅឯពិព័រណ៍ចង់ចំណាយពេលរបស់ពួកគេនិងមកតាម។

## លោកដល់ទីបញ្ចប់

ដូច្នេះខ្ញុំឃើញថា ភ្លាមនោះបន្ទាប់ពីពួកគេបានចេញផុតពីកន្លែងជំនួញនោះ ពួកគេតាមទាន់ម្នាក់ដែលកំពុងដើរនៅខាងមុខពួកគេ គាត់មានឈ្មោះថា ដល់ទីបញ្ចប់។ ដូច្នេះពួកគេនិយាយទៅគាត់ថា "តើលោកជាមនុស្សមកពីប្រទេសណាដែរ?" គាត់បានប្រាប់ពួកគេថា គាត់មកពីក្រុង សម្ដីត្រឹមត្រូវ ហើយគាត់កំពុងទៅកាន់ទីក្រុងស្ថានសួគ៌ (តែមិនបានប្រាប់ឈ្មោះគាត់ដល់ពួកគេទេ)។

គ្រីស្ទាន៖ "មកពីក្រុងសម្ដីត្រឹមត្រូវ" គ្រីស្ទានបានពោលថា "តើមានមនុស្សល្អណារស់នៅទីនោះទេ?"

**"កាលណាអ្នកនោះពោលពាក្យល្អ នោះកុំឱ្យជឿឱ្យសោះ ដ្បិតនៅក្នុងចិត្តគេមានសេចក្ដីគួរស្អប់ខ្ពើម៧មុខ។" សុភាសិត 26:25**

ដល់ទីបញ្ចប់៖ "បាទ" ដល់ទីបញ្ចប់បាននិយាយថា "ខ្ញុំសង្ឃឹម។"

គ្រីស្ទាន៖ "សូមលោក ប្រាប់មកថា ខ្ញុំនឹងហៅលោកថាយ៉ាងម៉េច?" គ្រីស្ទានបាននិយាយ។

ដល់ទីបញ្ចប់៖ ខ្ញុំជាជនប្លែកមុខសម្រាប់អ្នក ហើយអ្នកក៏ជាមនុស្សប្លែកមុខសម្រាប់ខ្ញុំដែរ។ ប្រសិនបើអ្នកនឹងដើរតាមផ្លូវនេះ ខ្ញុំរីករាយនឹងមានអ្នកជាគ្នា។ បើអត់ទេនោះ ខ្ញុំនឹងត្រូវស្កប់ចិត្តដែរ។

គ្រីស្ទានៈ "ទីក្រុងនៃសម្ដីត្រឹមត្រូវ" គ្រីស្ទាននិយាយថា "ខ្ញុំធ្លាប់ឮដែរ ហើយខ្ញុំចាំថា គេនិយាយថាជាទីដែលមានស្ដឹមស្ដែ។"

ដល់ទីបញ្ចប់ៈ បាទ ខ្ញុំអាចអះអាងការនេះដល់អ្នកបាន ហើយខ្ញុំមានបងប្អូនអ្នកមានជាច្រើននៅទីនោះ។

គ្រីស្ទានៈ សូមប្រាប់មកថាអ្នកណាជាសាច់ញាតិរបស់អ្នកនៅទីនោះ ប្រសិនបើបុរសម្នាក់នឹងមានភាពក្លាហាន?

ដល់ទីបញ្ចប់ៈ ស្ទើរតែពេញទីក្រុងទាំងមូល ហើយជាទូទៅ លោកម្ចាស់របស់ខ្ញុំឈ្មោះ រង្វង់មូល លោកម្ចាស់ពេលលំបាកវេទនា លោកម្ចាស់សម្ដីត្រឹមត្រូវ (ចេញពីបុព្វបុរសរបស់ពួកគេដែលទីក្រុងដាក់ឈ្មោះជាលើកដំបូង) ហើយលោកមនុស្សនិយាយរអិល លោកបែរមុខដាក់ផ្លូវសងខាង លោកគ្រប់យ៉ាង និងបុរសនៅភូមិរបស់យើងលោកអណ្ដាតពីរ ជាប្អូនប្រុសរបស់ម្ដាយខ្ញុំផ្ទាល់ខាងឪពុករបស់ខ្ញុំ។ ហើយបើប្រាប់អ្នកការពិតទៅ ខ្ញុំបានក្លាយជាសុភាពបុរសម្នាក់ដែលមានគុណតម្លៃល្អ តែតាទួតរបស់ខ្ញុំជាបុរសនៅទឹកម្នាក់ គាត់មើលទៅម្ខាង តែបែរជាអុំទៅម្ខាងផ្សេងទៀត ហើយខ្ញុំទទួលបានទឹកដីរបស់ខ្ញុំដោយមុខរបរដូចគ្នានោះ។

គ្រីស្ទានៈ តើអ្នករៀបការហើយឬនៅ?

ដល់ទីបញ្ចប់ៈ បាទ។ ប្រពន្ធរបស់ខ្ញុំជាស្ត្រីគ្រប់លក្ខណ៍ម្នាក់ ជាកូនស្រីរបស់ស្ត្រីគ្រប់លក្ខណ៍ម្នាក់។ នាងជាកូនស្រីរបស់អ្នកនាង ធ្វើសម្ដែងម្នាក់។ ដូច្នេះនាងបានមកពីគ្រួសារមួយដ៏មានកេរ្តិ៍ឈ្មោះ ហើយបានមកដល់ការបង្កាត់

មួយដូចនេះ ដែលនាងដឹងពីរបៀបយកវាទៅដល់គ្រប់គ្នា ទាំងទៅដល់ស្តេច និងកសិករផង។ "ពិតណាស់ដែលយើងខុសគ្នាខាងសាសនាពីអ្នកដែលមានប្រភពដែលតឹងរឹងជាង។ តែនៅក្នុងចំនុចតូចពីរ ទីមួយ យើងមិនដែលជំនះទាស់នឹងខ្យល់ឬរលកឡើយ។ ទីពីរ យើងតែងតែស្វាហាប់បំផុតនៅពេលសាសនានៅក្នុងស្បែកជើងប្រាក់នេះ យើងចូលចិត្តដើរជាមួយគាត់នៅតាមផ្លូវប្រសិនបើព្រះអាទិត្យរះ ហើយមនុស្សអបអរសោរទរវា។"

បន្ទាប់មកគ្រីស្ទានបានឈានទៅខាងបន្តិចដើម្បីដើរតាមពេញដោយសង្ឃឹមពោលថា "វារត់នៅក្នុងគំនិតរបស់ខ្ញុំថា ម្នាក់នេះជាដល់ទីបញ្ចប់ មកពីសម្តីត្រឹមត្រូវ ហើយប្រសិនបើជាវាមែននោះ យើងពិតជាមានមនុស្សដែលមិនស្មោះត្រង់នៅក្នុងក្រុមដែលនៅមកដល់ផ្នែកទាំងនេះហើយ។" បន្ទាប់មកពេញដោយសង្ឃឹមនិយាយថា "ចូរសួរគាត់ទៅ ខ្ញុំគិតថាគាត់មិនខ្មាសនឹងឈ្មោះរបស់គេទេ។" ដូច្នេះគ្រីស្ទានដើរមករកគាត់ម្តងទៀត ហើយនិយាយថា "លោក អ្នកនិយាយហាក់ដូចជាអ្នកដឹងអ្វីមួយច្រើនជាងអ្នកនៅលោកិយទាំងអស់ដឹង ហើយប្រសិនបើខ្ញុំមិនបានចំណាំខុសទេនោះ ខ្ញុំគិតថាខ្ញុំបានទាយបានខ្លះពីអ្នកហើយ។ តើមិនមែនឈ្មោះរបស់អ្នកហៅថា លោកដល់ទីបញ្ចប់ មកពីសម្តីត្រឹមត្រូវទេឬ?"

ដល់ទីបញ្ចប់៖ ហ្នឹងមិនមែនជាឈ្មោះរបស់ខ្ញុំទេ តែពិតទៅវាគ្រាន់តែជាឈ្មោះហៅក្រៅមួយដែលអ្នកខ្លះហៅ ដែលមិនត្រូវនៅជាប់នឹងខ្ញុំឡើយ។ ហើយខ្ញុំត្រូវតែស្កប់ចិត្តដែលទទួលវាមកដូចជាការរិះគន់ ដូចជាមនុស្សល្អផ្សេងទៀតបានទទួលឈ្មោះរបស់គេមុនខ្ញុំនោះដែរ។

គ្រីស្ទាន៖ តែតើអ្នកមិនដែលផ្តល់ឱកាលដល់មនុស្សហៅអ្នកនូវឈ្មោះនេះទេឬ?

ដល់ទីបញ្ចប់៖ ទេ មិនធ្លាប់ទេ! ឱកាសដ៏អាក្រក់បំផុតដែលខ្ញុំបានបានឱ្យគេហៅឈ្មោះខ្ញុំដូចនេះ ដែលខ្ញុំតែងតែឈានទៅដល់ការសន្មត់របស់ខ្ញុំដោយផ្លូវបច្ចុប្បន្ននេះថា អ្វីដែលកើតឡើងហើយ និងឱកាសរបស់ខ្ញុំដែលនឹងទទួលបាននោះ តែប្រសិនបើការនោះត្រូវទម្លាក់មកលើខ្ញុំ សូមឱ្យខ្ញុំបានរាប់ការទាំងនោះថាជាពរវិញ តែសូមកុំឱ្យមនុស្សស្អប់ខ្ពើមផ្តល់នូវការរិះគន់ដល់ខ្ញុំនោះឡើយ។

គ្រីស្ទាន៖ ខ្ញុំបានគិតថាថាអ្នកពិតជាបុរសម្នាក់ដែលខ្ញុំបានឮ ហើយបានប្រាប់អ្នកនូវអ្វីដែលខ្ញុំគិត ខ្ញុំខ្លាចថាឈ្មោះនេះជាឈ្មោះរបស់អ្នកយ៉ាងសមរម្យជាង អ្នកចង់ឱ្យយើងគិតបែបនោះ។

ដល់ទីបញ្ចប់៖ ពិតណាស់ ប្រសិនបើអ្នកស្រម៉ៃបែបនេះ ខ្ញុំមិនជួយអ្វីមិនបានឡើយ។ អ្នកត្រូវតែរកឃើញខ្ញុំថាជាគ្នាដែលល្អ ប្រសិនបើអ្នកនៅតែទទួលស្គាល់ថាខ្ញុំជាគ្នារបស់អ្នក។

គ្រីស្ទាន៖ប្រសិនអ្នកទៅជាមួយយើង អ្នកត្រូវតែទៅប្រឆាំងនឹងខ្យល់និងរលក ដែលខ្ញុំយល់ថានឹងទាស់ជាមួយនឹងគំនិតរបស់អ្នក។ អ្នកត្រូវតែមានសាសនាទាំងនៅក្នុងកាលគាត់មានសំលៀកបំពាក់រហែក ក៏ដូចជាពេលដែលគាត់មានស្បែកជើងប្រាក់ផង។ ហើយឈរនៅក្បែរគាត់ផងនៅពេល

ដែលគាត់ត្រូវដាក់ច្រវាក់ដែក ក៏ដូចជាពេលដែលគាត់ដើរនៅផ្លូវដោយមានការសាទរផង។

ដល់ទីបញ្ចប់៖ អ្នកមិនត្រូវបង្ខំឬធ្វើម្ចាស់លើសេចក្ដីជំនឿរបស់ខ្ញុំឡើយ។ ចូរចេញពីខ្ញុំឱ្យមានសេរីភាពរបស់ខ្ញុំវិញ ហើយឱ្យខ្ញុំបានទៅជាមួយអ្នកផង។

គ្រីស្ទាន៖ មិនទៅមុខសូម្បីតែមួយជំហានទៀតឡើយ លើកលែងតែអ្នកនឹងធ្វើតាមអ្វីដែលខ្ញុំបានពន្យល់នេះ។

ដល់ទីបញ្ចប់៖ បន្ទាប់មកដល់ទីបញ្ចប់និយាយថា "ខ្ញុំនឹងមិនចោលគោលការណ៍ចាស់របស់ខ្ញុំឡើយ ក្នុងកាលដែលវាមិនមានគ្រោះថ្នាក់ និងមានប្រយោជន៍ផង។ ប្រសិនបើខ្ញុំមិនទៅជាមួយអ្នក ខ្ញុំត្រូវធ្វើអ្វីដែលខ្ញុំបានធ្វើពីមុនពេលអ្នកមកទាន់ខ្ញុំ ទោះទៅតែម្នាក់ឯង រហូតដល់មានអ្នកខ្លះមកទាន់ខ្ញុំនឹងបានធ្វើជាគ្នាខ្ញុំដោយរីករាយ។"

ពេលនេះខ្ញុំបានឃើញនៅក្នុងសុបិនរបស់ខ្ញុំថាគ្រីស្ទាននិងពេញដោយសង្ឃឹមបានបដិសេធគាត់ ហើយបានរក្សាគម្លាតពីគាត់។ តែម្នាក់ក្នុងពួកគេបានបែរក្រោយ ហើយបានឃើញបុរសបីនាក់ដើរតាមលោកដល់ទីបញ្ចប់។ ហើយមើលទៅនៅពេលដែលពួកគេមកទាន់គាត់ គាត់បានធ្វើឱ្យពួកគេឱនចុះទាបបំផុត ហើយពួកគេក៏បានផ្ដល់ការសរសើរដល់គាត់។ ឈ្មោះរបស់ពួកគេគឺ លោកកាន់តាមលោកិយ លោកស្រឡាញ់លុយ និងលោកសង្គ្រោះទាំងអស់ ជាមនុស្សដែលលោកដល់ទីបញ្ចប់បានស្គាល់ពីមុនមក ដោយសារក្នុងភាគតិចរបស់ពួកគេ ពួកគេជាអ្នករៀនជាមួយគ្នា ហើយបាន

រៀនជាមួយនឹងលោករអ៊ូរទាំ ជាចាងហ្វាងសាលានៅក្នុងស្រឡាញ់ផល ប្រយោជន៍ ដែលជាផ្សារនៅក្រុងមួយនៅប្រទេសនៃសេចក្តីលោភលន់ នៅភាគខាងជើង។ ចាងហ្វាងសាលានេះបានបង្រៀនដល់ពួកគេពីសិល្បៈនៃការទទួលបានទាំងដោយកំលាំងបាយ ការបោកបញ្ឆោត ដោយការបញ្ចូរការកុហក់ ឬដោយការបន្លំជាសាសនា ហើយមនុស្សបួននាក់នេះរៀនបានពូកែយ៉ាងខ្លាំងនៅក្នុងសិល្បៈនៃចៅហ្វាយរបស់គេ ដូច្នេះពួកគេម្នាក់ៗបានរក្សាសាលារៀនបែបនេះដោយផ្ទាល់។

ពិតណាស់ នៅពេលដែលពួកគេបានរាក់ទាក់គ្នាទៅវិញទៅមករួចហើយ លោកស្រឡាញ់លុយ និងលោកដល់ទីបញ្ចប់និយាយថា "តើពួកគេជាអ្នកណាដែលនៅខាងមុខយើងនោះ?" ដោយសារគ្រីស្ទាននិងពេញដោយសង្ឃឹមត្រូវបានពួកគេមើលឃើញនៅឡើយ។

ដល់ទីបញ្ចប់៖ ពួកគេជាមនុស្សពីរនាក់ដែលមកពីប្រទេសឆ្ងាយដែល កំពុងទៅធ្វើធម្មយាត្រា។

ស្រឡាញ់លុយ៖ ព្រះអើយ! ហេតុអ្វីបានជាពួកគេមិនចាំសិន នោះយើងនឹងបានគ្នាយ៉ាងល្អ។ ដោយសារពួកគេហើយនឹងយើង និងអ្នកលោកអើយ ខ្ញុំសង្ឃឹមថាយើងទាំងអស់គ្នានឹងបានធ្វើធម្មយាត្រាជាមួយគ្នា?

ដល់ទីបញ្ចប់៖ យើងកំពុងធ្វើធម្មយាត្រាពិតមែន។ តែបុរសដែលនៅខាងមុខយើងពិតជារឹងរុសណាស់ ហើយពួកគេស្រឡាញ់ទំនោររបស់របស់ពួកគេខ្លាំងណាស់ ហើយមិនសូវឱ្យតម្លៃដល់ភាពជាគូរកនរបស់អ្នកផ្សេងឡើយ

ដែលទោះបីជាមនុស្សម្នាក់ក៏មិនដែលបានកោតខ្លាចព្រះខ្លាំងអីចឹងដែរ តែប្រសិនបើគេមិនទៅតាមពួកគេគ្រប់យ៉ាងទេ ពួកគេនឹងបោះគាត់ចោលចេញពីក្រុមរបស់ពួកគេ។

លោកសង្គ្រោះទាំងអស់៖ អាក្រក់ណាស់។ តែយើងបានអានពីអ្នកខ្លះដែលសុចរិតខ្លាំង និងសេចក្តីសុចរិតរបស់មនុស្សដែលយកឈ្នះជាមួយនឹងពួកគេដែលកាត់ទោសនិងដាក់ទោសតែខ្លួនពួកគេ។ តែសូមប្រាប់ខ្ញុំមកថា ការអ្វីហើយរបៀបណាខ្លះដែលជាការខុសគ្នាជាមួយអ្នកទៅ?

ដល់ទីបញ្ចប់៖ ដោយសារបន្ទាប់ពីបែបបទរឹងរុសរបស់ពួកគេមក បានសន្មត់ថាវាជាតួនាទីរបស់ពួកគេដែលត្រូវរុសរាន់ទៅធ្វើដំណើររបស់ពួកគេនៅក្នុងគ្រប់អាកាសធាតុទាំងអស់។ ហើយខ្ញុំវិញត្រូវរងចាំខ្យល់និងរលក។ ពួកគេប្រាថ្នាគ្រប់យ៉ាងសម្រាប់ព្រះ ហើយខ្ញុំវិញប្រមូលផលប្រយោជន៍ទាំងអស់មកដើម្បីនឹងទំនុកបម្រុងជីវិតនិងសម្បត្តិរបស់ខ្ញុំ។ ពួកគេសម្រាប់នឹងកាន់តាមគំនិតទោរទន់របស់ពួកគេ បើទោះជាមនុស្សទាំងអស់ទាស់នឹងពួកគេក៏ដោយ តែខ្ញុំវិញសម្រាប់សាសនារហូតទាល់តែដល់ពេលណាដែលខ្ញុំនៅមានសុវត្ថិភាពខ្ញុំនឹងទ្រាំទ្រ។ ពួកគេសម្រាប់សាសនាទាំងនៅសំលៀកបំពាក់កន្ទបនិងក្នុងការមើលងាយ តែខ្ញុំសម្រាប់មួយអង្គដែលទ្រង់ដើរនៅក្នុងស្បែកជើងមាសរបស់ទ្រង់នៅក្នុងពន្លឺព្រះអាទិត្យ និងមានទាំងសារអបអរសាទរផង។

លោកកាន់តាមលោកិយ៖ អេ សុំឈប់នៅទីនោះសិនហើយ លោកដល់ទីបញ្ចប់អើយ ដោយសារ សម្រាប់ខ្ញុំវិញ ខ្ញុំមានតែរាប់គាត់ថាជាមនុស្សល្ងង់

ដែល មានសេរីភាពរក្សាអ្វីដែលគាត់មានហើយ ដែលល្ងង់ឱ្យត្រូវបាត់បង់បាន។ ចូរយើងឆ្លាតដូចជាសត្វពស់ នេះជាការល្អដែលត្រូវធ្វើចំបើងទាន់មានព្រះអាទិត្យចែងចាំង អ្នកឃើញហើយថាសត្វឃ្មុំនៅតែដេកនៅពេលរដូវរងាហើយចាប់ធ្វើការនៅពេលដែលនាងអាចទទួលបានផលដោយអំណរប៉ុណ្ណោះ។ ជួនកានព្រះបញ្ជូនភ្លៀងមក ហើយជួនកាលថ្ងៃក្តៅមក ប្រសិនបើគេល្ងង់ទៅឆ្លងកាត់ទីមួយហើយ តែចូរយើងបានស្កប់ចិត្តដែលដើរនៅពេលអាកាសធាតុល្អជានិច្ចជាមួយយើង។ ចំណែកខ្ញុំវិញ ខ្ញុំចូលចិត្តសាសនានោះខ្លាំងដោយឈតជាមួយនឹងសុវត្ថិភាពនៃព្រះពររបស់ព្រះមកដល់យើង។ តើអ្នកនឹងស្រម៉ៃបានថា ការនោះត្រូវបានគ្រប់គ្រងដោយហេតុផលរបស់ទ្រង់នៅក្នុងកាលដែលព្រះបានផ្តល់ដល់យើងនូវការល្អនៅក្នុងជីវិតនេះ តែទ្រង់ចង់ឱ្យយើងរក្សាការទាំងនោះដោយយល់ដល់ព្រះនាមទ្រង់នោះ? លោកអ័ប្រាហាំនិងស្តេចសាឡូម៉ូនក្លាយជាអ្នកមាននៅក្នុងសាសនា។ ហើយយ៉ូបនិយាយថា "ថាមនុស្សល្អនឹងរក្សាទុកមានដូចជាធូលីដី។" តែគាត់មិនបានដូចជាមនុស្សទាំងពីរនាក់ខាងមុខយើងទេ ប្រសិនបើពួកគេដូចជាអ្វីដែលអ្នកបានរៀបរាប់នោះ។

លោកសង្គ្រោះទាំងអស់៖ ខ្ញុំគិតថាយើងទាំងអស់គ្នាសុទ្ធតែយល់ស្របនៅក្នុងបញ្ហានេះ។ ដូច្នេះមិនត្រូវការនិយាយអ្វីទៀតឡើយ។

លោកស្រឡាញ់លុយ៖ ទេ ពិតជាមិនត្រូវការនិយាយពីរឿងនេះទៀតឡើយដោយសារអ្នកដែលមិនជឿព្រះគម្ពីរឬហេតុផលនោះ (ហើយអ្នកឃើញហើយថាយើងមានទាំងពីរនៅខាងយើង) ក៏មិនទាំងស្គាល់ពីសេរីភាពរបស់ខ្លួនឯង ឬមិនស្វែងរកសុវត្ថិភាពរបស់ខ្លួនផងនោះ។

លោកដល់ទីបញ្ចប់៖ បងប្អូនអើយ យើងទាំងអស់គ្នាដូចដែលអ្នកឃើញហើយ កំពុងតែនៅក្នុងធម្មយាត្រា ហើយសម្រាប់ការផ្លាស់ប្តូរដ៏ប្រសើររបស់យើងពីការអាក្រក់ៗវិញ សូមឱ្យខ្ញុំបានបកស្រាយដល់អ្នកនូវសំណួរនេះសិន។

ប្រសិនបើបុរសម្នាក់ ជាអ្នកអធិប្បាយ ឬជាអ្នកធ្វើជំនួញ គួរតែមានផលប្រយោជន៍ក្រាលនៅចំពោះគាត់ ឱ្យទទួលបានព្រះពរល្អនៅក្នុងជីវិតរបស់គាត់ តែបើទៅរួច តែគាត់មិនអាចមកដល់ព្រះពរទាំងនោះបានលើកលែងតែនៅក្នុងការលេចមកខាងក្រៅរបស់គាត់យ៉ាងហោចណាស់ គាត់ក្លាយជាខ្លាំងខ្លាឡើងមិនធម្មតានៅក្នុងចំណុចខ្លះដែលគាត់មិនដែលជួបសោះពីមុនមក តើគាត់នឹងមិនប្រើវិធីនេះដើម្បីទៅដល់ទីបញ្ចប់របស់គាត់  ហើយនៅតែជាមនុស្សស្មោះត្រង់ទៀតទេឬយ៉ាងណា?

លោកស្រឡាញ់លុយ៖ ខ្ញុំមើលឃើញមូលដ្ឋាននៃសំណួររបស់អ្នក ហើយជាមួយនឹងសេចក្តីល្អរបស់សុភាពបុរសនេះ ខ្ញុំនឹងស្រវ៉ាទាញយកចម្លើយមួយដល់អ្នក។ ហើយដំបូង ដើម្បីនឹងនិយាយទៅកាន់សំណួររបស់អ្នកដែលទាក់ទងនឹងអ្នកអធិប្បាយផ្ទាល់នោះ ឧបមាថាអ្នកអធិប្បាយ ជាមនុស្សម្នាក់ដែលមានគុណតម្លៃ តែមានផលប្រយោជន៍តែបន្តិចបន្តួច តែនៅក្នុងភ្នែករបស់គាត់ពេញដោយខ្លាញ់និងបំណងប្រថ្នាដ៏ធំនោះ ពេលនេះគាត់ក៏មានឱកាសនិងទទួលបានការនោះដែរ តែដោយច្បាស់លាស់ថែមទៀតដោយការអធិប្បាយជាញឹកញាប់ថែមទៀតនិងខ្លាំងខ្លាថែមទៀត ហើយដោយសារបំណងប្រាថ្នារបស់មនុស្សទាមទារការនោះ ដោយការផ្លាស់ប្តូរគោលការណ៍មួយចំនួនរបស់គាត់។ ចំណែកខ្ញុំវិញ ខ្ញុំមិនឃើញមានហេតុផល ដែល

មនុស្សម្នាក់នឹងធ្វើវាឡើយ ដែលធ្វើឱ្យគាត់ទទួលបានការត្រាស់ហៅឡើយ ។ អេ ហើយបញ្ហាដែលសំខាន់ថែមទៀតនោះ គឺគាត់នៅតែជាមនុស្សស្មោះត្រង់ដដែល។ តើហេតុអ្វីទៅ?

1. សេចក្តីប៉ងប្រាថ្នារបស់គាត់ចង់បានផលប្រយោជន៍ធំថែមទៀតគឺវាស្របច្បាប់ហើយ (វាមិនអាចនឹងប្រឆាំងគ្នាឡើយ) ក្នុងកាលដែល ការនេះបានដាក់នៅចំពោះគាត់ដោយផែនការរបស់ព្រះ ដូច្នេះ គាត់អាចទទួលយកវាបានបើគាត់អាចយកបាន ដោយមិនបាច់សួរ ដោយយល់ដល់សតិប្រាជ្ញា។

2. ក្រៅពីនោះ បំណងប្រាថ្នារបស់គាត់ដែលចង់បានដំណែងដោយទិញ ធ្វើឱ្យគាត់កាន់តែច្បាស់លាស់ថែមទៀត កាន់តែក្លាយជាអ្នកអធិប្បាយយ៉ាងក្លៀវក្លាថែមទៀត ហើយអ្វីផ្សេងៗទៀត ដូច្នេះនឹងធ្វើឱ្យគាត់ក្លាយជាមនុស្សប្រសើរជាងមុន។ ពិតណាស់ ធ្វើឱ្យគាត់កាន់តែអភិវឌ្ឍខាងផ្នែករបស់គាត់ដែលស្របតាមគំនិតរបស់ព្រះផង។

3. ពេលនេះដើម្បីសម្រេចតាមបំណងរបស់មនុស្សរបស់គាត់ដោយបង្ហាញគំនិតខុសគ្នានោះ ដើម្បីនឹងបម្រើពួកគេ គោលការណ៍មួយចំនួនរបស់គាត់ការវែកញែកនេះ ទីមួយ ថាគាត់មានបំណងនៅក្នុងការបដិសេធខ្លួនឯង ទីពីរ ក្នុងបែបបទមួយដែលពេញចិត្ត ទីបី ដែលកាន់តែសាកសមនឹងតួនាទីជាអ្នកអធិប្បាយថែមទៀត។

4. ខ្ញុំសន្មត់ថា អ្នកអធិប្បាយនោះដែលផ្លាស់ប្តូរការតូចមួយសម្រាប់ការធំមិនគួរត្រូវបានគេកាត់ទោសថាជាអ្នកលោភលន់ទេ តែ ក្នុងកាលដែលគាត់មានការរីកចម្រើននៅក្នុងផ្នែករបស់គាត់និងការបង្កើតរបស់គាត់វិញ គាត់គួរតែត្រូវបានរាប់ថាជាមនុស្សម្នាក់ដែលដេញតាមការត្រាស់ហៅរបស់គាត់និងឱកាសដែលដាក់នៅក្នុងដៃដើម្បីនឹងធ្វើការល្អ។

ហើយពេលនេះចំពោះផ្នែកទីពីរនៃសំណួរវិញ ដែលទាក់ទងនឹងអ្នកធ្វើជំនួញ ដែលអ្នកនិយាយនោះ ឧបមារថាមនុស្សម្នាក់ក្រីក្រនៅក្នុងលោកិយនេះ តែដោយក្លាយជាអ្នកជឿសាសនាវិញ គាត់អាចនឹងបត់បែនទីផ្សាររបស់គាត់ អាចជានឹងយកប្រពន្ធអ្នកមាន ឬយកអតិថិជនច្រើននិងប្រសើរថែមទៀត មកកាន់ហាងរបស់គាត់ ចំពោះខ្ញុំវិញ ខ្ញុំមិនឃើញហេតុផលអ្វី ក្រៅពីថាការនេះបានធ្វើឡើងដោយស្របច្បាប់ហើយ។ ដោយសារហេតុអ្វីទៅ?

1. ការដែលក្លាយជាអ្នកកាន់សាសនាជាសីលធម៌មួយ ដោយវិធីនោះមនុស្សការបានក្លាយទៅជាបែបនោះទៅ។

2. វាមិនមែនខុសច្បាប់ដែលយកប្រពន្ធអ្នកមាននោះដែរ ឬដែលរកអតិថិជនច្រើនមកកាន់ហាងរបស់ខ្ញុំឡើយ.

3. ក្រៅពីនោះ អ្នកដែលទទួលបានការទាំងនេះដោយក្លាយខ្លួនជាអ្នកកាន់សាសនា គាត់ទទួលបានអ្វីដែលល្អពីអ្នកដែលល្អ ដោយបានក្លាយជាល្អខ្លួនឯងផ្ទាល់។ ដូច្នេះនេះជាប្រពន្ធល្អម្នាក់ ហើយអតិថិជនល្អ និងបានចំណេញល្អ ហើយការទាំងបានដោយក្លាយជាអ្នកកាន់សាសនា ដែលជាការល្អ។ ដូច្នេះ ការដែលក្លាយជាអ្នកកាន់សាសនា ដើម្បីទទួលបានការទាំងនេះ ជាបែបបទដែលល្អនិងមានផលប្រយោជន៍មួយ។

ចម្លើយនេះដែលលោកស្រឡាញ់លុយនិយាយទៅកាន់លោកដល់ទីបញ្ចប់នោះ ត្រូវបានគេទាំងអស់គ្នាសារទរឱ្យយ៉ាងខ្លាំង។ ដូច្នេះពួកគេសន្មត់ការមូលថា ជាការដែលល្អនិងមានផលប្រយោជន៍។ ហើយដោយសារ ក្នុងកាល

ដែលពួកគេគិតថា គ្មានអ្នកណាអាចទាស់នឹងការនោះបានឡើយ ហើយដោយសារគ្រីស្ទាននិងពេញដោយសង្ឃឹមនៅអាចហៅពួនៅឡើយ ពួកគេយល់ព្រមគ្នាដោយរីករាយនឹងធ្វើបាបដល់ពួកគេដោយសំណួររំពេចណាណាដែលពួកគេទៅទាន់ពួកគេ ក្រៅពីនោះទៀតគឺដោយសារពួកគេបានប្រឆាំងនឹងលោកដល់ទីបញ្ចប់ពីមុនមក។ ដូច្នេះពួកគេបានស្រែកហៅពួកគេ ហើយពួកគេក៏ឈប់ ហើយឈរនៅស្ងៀមរហូតដល់ពួកគេតាមមកទាន់។ តែពួកគេសន្មត់ពេលដែលពួកគេដើរទៅថា មិនមែនលោកដល់ទីបញ្ចប់ តែជាលោកកាន់តាមលោកិយចំណាស់វិញដែលនឹងត្រូវសួរសំណួរទៅកាន់ពួកគេ ដោយសារពួកគេគិតថា ចម្លើយរបស់ពួកគេទៅកាន់គាត់នឹងមិនមានអ្វីសេសសល់ដែលនឹងបង្កាត់ភ្លើងរវាងលោកដល់ទីបញ្ចប់ និងពួកគេដែលនៅដាច់គ្នាខាងមុខបន្តិចនេះនោះឡើយ។

ដូច្នេះពួកគេបានមកទាន់គ្នា ហើយបន្ទាប់ពីបានរាក់ទាក់គ្នាបន្តិចមក លោកកាន់តាមលោកិយបានសួរសំណួរទៅកាន់គ្រីស្ទាននិងគ្នារបស់គាត់ ហើយប្រាប់ឱ្យពួកគេឆ្លើយមកប្រសិនបើពួកគេអាចឆ្លើយបាន។

គ្រីស្ទាន៖ បន្ទាប់មកគ្រីស្ទាននិយាយថា "សូម្បីតែកូនក្មេងនៅក្នុងសាសនាក៏អាចឆ្លើយសំណួររាប់ម៉ឺនដូចនេះបានដែរ។ ប្រសិនបើវាមិនស្របច្បាប់នៅក្នុងការដើរតាមព្រះគ្រីស្ទដើម្បីបាននំបុ័ងដូច្នេះទេ ដូចជាការនេះ

> "ក្រោយមក ព្រះយេស៊ូវទ្រង់ឆ្លងសមុទ្រកាលីឡេ គឺជាសមុទ្រទីបេរាស។ ហើយមានហ្វូងមនុស្សជាធំតាមទ្រង់ទៅ ដោយបានឃើញទីសម្គាល់ទាំងប៉ុន្មាន ដែលទ្រង់ប្រោសដល់ពួកជំងឺ។ នោះព្រះយេស៊ូវទ្រង់យាងឡើង

ទៅលើភ្នំ គង់ជាមួយនឹងពួកសិស្សនៅទីនោះ។ រីឯបុណ្យរំលង ជាបុណ្យរបស់សាសន៍យូដា ក៏ជិតដល់ហើយ។ ឯព្រះយេស៊ូវទ្រង់ងើបព្រះនេត្រឡើង ឃើញមនុស្សកកកុញមកឯទ្រង់ នោះទ្រង់មានព្រះបន្ទូលទៅភីលីពថា យើងនឹងទិញនំបុ័ងពីណាមក ឱ្យមនុស្សទាំងអស់នេះបានបរិភោគ។ ទ្រង់មានព្រះបន្ទូលសួរដូច្នេះ ដើម្បីនឹងល្បងលគាត់ទេ ព្រោះទ្រង់ជ្រាបការ ដែលទ្រង់គិតធ្វើហើយ។ ភីលីពទូលឆ្លើយថា ទោះបើទិញនំបុ័ងអស់៩០រៀល ក៏មិនគ្រាន់ឱ្យគ្រប់គ្នា សូម្បីតែបន្តិចបន្តួចផង។ មានសិស្សទ្រង់ម្នាក់ ឈ្មោះអនទ្រេ ជាប្អូនស៊ីម៉ូន-ពេត្រុស គាត់ទូលទ្រង់ថា។ នៅទីនេះមានក្មេងម្នាក់ មាននំបុ័ងម្សៅឱក ៥ និងត្រីតូច២ ប៉ុន្តែ ដែលមានប៉ុណ្ណោះ តើមានប្រយោជន៍អ្វី ដល់មនុស្សច្រើនទាំងម៉្លេះ។ ព្រះយេស៊ូវមានព្រះបន្ទូលថា ចូរឱ្យមនុស្សទាំងអស់អង្គុយទៅ រីឯនៅទីនោះ មានស្មៅច្រើន ដូច្នេះ គេក៏នាំគ្នាអង្គុយ មានចំនួនប្រហែលជា៥ពាន់នាក់។ រួចព្រះយេស៊ូវទ្រង់យកនំបុ័ងនោះអរព្រះគុណ រួចចែកទៅឱ្យពួកសិស្ស គេក៏ចែកដល់ពួកអ្នកដែលអង្គុយ បានចែកទាំងត្រីតូចនោះបែបដូច្នោះដែរ តាមតែគេចង់បាន។ លុះគេបានឆ្អែតគ្រប់គ្នាហើយ នោះទ្រង់មានព្រះបន្ទូលទៅពួកសិស្សថា ចូរប្រមូលចំណិតដែលសល់នៅ ដើម្បីកុំឱ្យបាត់អ្វីឡើយ។ ក្រោយដែលបរិភោគរួចហើយ នោះគេប្រមូលចំណិតនំបុ័ងម្សៅឱកដែលសល់ពី៥ដុំនោះ ដាក់ពេញបាន១២កន្ត្រក។ កាលមនុស្សទាំងប៉ុន្មានបានឃើញទីសម្គាល់ ដែលព្រះយេស៊ូវធ្វើនោះ គេក៏និយាយថា លោកនេះប្រាកដជាហោរានោះ ដែលត្រូវមកក្នុងលោកីយ៍មែន។ ដូច្នេះ ព្រះយេស៊ូវក៏ថយឡើងទៅលើភ្នំ តែ១អង្គទ្រង់វិញទៀត ពីព្រោះទ្រង់ជ្រាបថា គេគិតមកចាប់ទ្រង់ដោយកម្លាំង ដើម្បីនឹងតាំងឡើងជាស្តេច។ លុះព្រលប់ហើយ ពួកសិស្សទ្រង់ចុះទៅឯសមុទ្រ។ ក៏ចុះទូកឆ្លងទៅកាពើណិម ពេលនោះងងឹតហើយ តែព្រះ

យេស៊ូវមិនទាន់មកដល់នៅឡើយ។ សមុទ្រក៏មានរលក បោកដោយខ្យល់បក់ជាខ្លាំង។ កាលគេបានចែវទៅប្រហែលជា៥ ឬ៦គីឡូម៉ែត្រហើយ នោះស្រាប់តែគេឃើញព្រះយេស៊ូវ ទ្រង់យាងលើសមុទ្រមកជិតទូក ហើយគេមានសេចក្តីភ័យខ្លាច។ តែទ្រង់មានព្រះបន្ទូលថា កុំភ័យអី គឺខ្ញុំទេតើ។ នោះគេក៏ព្រមទទួលទ្រង់មកក្នុងទូក ស្រាប់តែទូកបានដល់ស្រុកដែលគេប៉ងនឹងទៅ។ស្អែកឡើង កាលហ្វូងមនុស្ស ដែលនៅត្រើយសមុទ្រម្ខាង បានឃើញថា នៅទីនោះគ្មានទូកណាទៀត ក្រៅពីទូក១ ដែលពួកសិស្សទ្រង់បានជិះ ហើយថា ព្រះយេស៊ូវមិនបានជិះទូកនោះ ទៅជាមួយនឹងពួកសិស្សទេ គឺពួកសិស្សបានចេញទៅតែគ្នាគេ។ (ប៉ុន្តែ មានទូកខ្លះទៀត មកពីស្រុកទីបេរាស ជិតកន្លែងដែលគេបានបរិភោគនំបុ័ង ក្រោយដែលព្រះអម្ចាស់បានអរព្រះគុណរួចហើយ)។ ដូច្នេះ កាលហ្វូងមនុស្សមិនឃើញព្រះយេស៊ូវ ឬពួកសិស្សទ្រង់នៅទីនោះ គេក៏ជិះទូកទៅឯកាពើណិម ដើម្បីនឹងរកទ្រង់។ កាលឃើញទ្រង់នៅឯត្រើយម្ខាងហើយ នោះគេទូលសួរថា លោកគ្រូ លោកមកដល់ទីនេះពីកាលណា។ ព្រះយេស៊ូវមានព្រះបន្ទូលឆ្លើយទៅគេថា ប្រាកដមែន ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា អ្នករាល់គ្នារកខ្ញុំ មិនមែនដោយព្រោះបានឃើញទីសម្គាល់ទេ គឺដោយព្រោះតែបានបរិភោគនំបុ័ងឆ្អែតប៉ុណ្ណោះ។ កុំឱ្យខំប្រឹងឱ្យបានតែអាហារ ដែលតែងតែពុករលួយនោះឡើយ ចូរខំឱ្យបានអាហារ ដែលនៅស្ថិតស្ថេរ ដរាបដល់ជីវិតអស់កល្បជានិច្ចវិញ ជាអាហារដែលកូនមនុស្សនឹងឱ្យមកអ្នករាល់គ្នា ដ្បិតគឺកូនមនុស្សនេះហើយ ដែលព្រះវរបិតាដ៏ជាព្រះ ទ្រង់បានដៅចំណាំទុក។ ដូច្នេះ គេទូលសួរទ្រង់ថា ដែលនឹងធ្វើការរបស់ព្រះ តើត្រូវធ្វើដូចម្តេចខ្លះ។ ព្រះយេស៊ូវមានព្រះបន្ទូលឆ្លើយថា ឯការរបស់ព្រះ គឺឱ្យអ្នករាល់គ្នាបានជឿដល់អ្នកដែលព្រះបានចាត់ឱ្យមក។ នោះគេទូលសួរទ្រង់ថា បើ

ដូច្នេះ តើលោកនឹងធ្វើទីសម្គាល់ណាឱ្យយើងខ្ញុំឃើញផង ដើម្បីឱ្យបានជឿដល់លោក តើលោកធ្វើការអ្វីខ្លះ។ ពួកអយ្យកោយើងខ្ញុំបានបរិភោគនំម៉ាន៉ានៅទីរហោស្ថាន ដូចជាមានសេចក្តីចែងទុកមកថា លោកបានឱ្យនំប៉័ងពីស្ថានសួគ៌ មកឱ្យគេបរិភោគ។ ឯព្រះយេស៊ូវទ្រង់មានព្រះបន្ទូលតបថា ប្រាកដមែន ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា មិនមែនលោកម៉ូសេ ដែលឱ្យនំប៉័ង ពីស្ថានសួគ៌នោះមកអ្នករាល់គ្នាទេ តែឯនំប៉័ងដ៏ពិត ដែលមកពីស្ថានសួគ៌ នោះគឺព្រះវរបិតាខ្ញុំ ដែលប្រទានមកអ្នករាល់គ្នាវិញ។ ដ្បិតនំប៉័ងរបស់ព្រះ គឺជាព្រះអង្គដែលយាងចុះពីស្ថានសួគ៌មក ព្រមទាំងប្រទានឱ្យមនុស្សលោកបានជីវិតផង។ ដូច្នេះ គេទូលទ្រង់ថា លោកម្ចាស់អើយ សូមឱ្យនំប៉័ងនោះមកយើងខ្ញុំជានិច្ច។ ព្រះយេស៊ូវមានព្រះបន្ទូលថា ខ្ញុំជានំប៉័ងជីវិត អ្នកណាដែលមកឯខ្ញុំ នោះនឹងមិនឃ្លានទៀតឡើយ ហើយអ្នកណាដែលជឿដល់ខ្ញុំ ក៏មិនត្រូវស្រេកដែរ។ ប៉ុន្តែ ខ្ញុំបានប្រាប់អ្នករាល់គ្នារួចហើយថា អ្នករាល់គ្នាបានឃើញខ្ញុំ តែមិនជឿទេ។ អស់អ្នកណាដែលព្រះវរបិតាប្រទានមកខ្ញុំ នោះនឹងមកឯខ្ញុំ ហើយអ្នកណាដែលមកឯខ្ញុំ ខ្ញុំក៏មិនដែលចោលទៅក្រៅឡើយ។ ពីព្រោះខ្ញុំបានចុះពីស្ថានសួគ៌មក មិនមែននឹងធ្វើតាមចិត្តខ្ញុំទេ គឺតាមបំណងព្រះហឫទ័យនៃព្រះវិញ ដែលទ្រង់ចាត់ឱ្យខ្ញុំមក។ ឯបំណងព្រះហឫទ័យនៃព្រះវរបិតា ដែលចាត់ឱ្យខ្ញុំមក នោះគឺមិនចង់ឱ្យខ្ញុំបាត់អ្នកណា ក្នុងគ្រប់អស់ទាំងមនុស្ស ដែលទ្រង់ប្រទានមកខ្ញុំនោះឡើយ គឺទ្រង់ចង់ឱ្យខ្ញុំប្រោសទាំងអស់ឱ្យរស់ឡើង នៅថ្ងៃចុងបំផុតវិញ។ នេះហើយជាបំណងព្រះហឫទ័យនៃព្រះវរបិតាខ្ញុំ គឺឱ្យអស់អ្នកណាដែលឃើញព្រះរាជបុត្រា ហើយក៏ជឿដល់ទ្រង់ បានជីវិតដ៏នៅអស់កល្បជានិច្ច ហើយខ្ញុំនឹងឱ្យអ្នកនោះរស់ឡើងវិញ នៅថ្ងៃចុងបំផុត។ នោះពួកសាសន៍យូដា គេឧកដាន់ទ្រង់ ពីព្រោះទ្រង់មានព្រះបន្ទូលថា ខ្ញុំជានំប៉័ង ដែល

ចុះពីស្ថានសួគ៌មក។ គេនិយាយថា អ្នកនេះ តើមិនមែនឈ្មោះយេស៊ូវ ជាកូនយ៉ូសែប ដែលយើងស្គាល់ឪពុកម្ដាយគាត់ទេឬអី ចុះដូចម្ដេចឡើយបានជាគាត់និយាយថា គាត់ចុះពីស្ថានសួគ៌មកដូច្នេះ។ នោះព្រះយេស៊ូវមានព្រះបន្ទូលទៅគេថា កុំឱ្យរទូរទាំក្នុងពួកអ្នករាល់គ្នាឡើយ។ គ្មានអ្នកណាអាចនឹងមកឯខ្ញុំបានទេ លើកតែព្រះវរបិតា ដែលចាត់ខ្ញុំឱ្យមក ទ្រង់ទាញនាំគេប៉ុណ្ណោះ ហើយខ្ញុំនឹងឱ្យអ្នកនោះរស់ឡើងវិញ នៅថ្ងៃចុងបំផុតដែរ។ នៅក្នុងគម្ពីរពួកហោរាមានសេចក្ដីចែងទុកមកថា ព្រះទ្រង់នឹងបង្រៀនគេទាំងអស់គ្នា ដូច្នេះអស់អ្នកណាដែលឮព្រះវរបិតា ហើយបានរៀនពីទ្រង់ នោះក៏មកឯខ្ញុំ។ នេះមិនមែនថា មានអ្នកណាដែលឃើញព្រះវរបិតានោះឡើយ មានតែព្រះអង្គដែលយាងមកពីព្រះប៉ុណ្ណោះ ព្រះអង្គនោះទើបទ្រង់បានឃើញព្រះវរបិតាមែន។ ប្រាកដមែន ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា អ្នកណាដែលជឿដល់ខ្ញុំនោះមានជីវិតអស់កល្បជានិច្ច។ ខ្ញុំជានំប៉័ងជីវិត។ពួកអយ្យកោអ្នករាល់គ្នាបានបរិភោគនំម៉ាន៉ា នៅទីរហោស្ថាន ហើយក៏ស្លាប់អស់ទៅ។ ឯនំប៉័ងដែលខ្ញុំនិយាយនេះ គឺជានំប៉័ងដែលចុះពីស្ថានសួគ៌មក ដើម្បីឱ្យអ្នកណា ដែលបរិភោគមិនត្រូវស្លាប់ឡើយ។ ខ្ញុំជានំប៉័ងដ៏រស់ ដែលចុះពីស្ថានសួគ៌មក បើអ្នកណាបរិភោគនំប៉័ងនេះ នោះនឹងរស់នៅអស់កល្បជានិច្ច ឯនំប៉័ងដែលខ្ញុំឱ្យ គឺជារូបសាច់ខ្ញុំ ដែលខ្ញុំនឹងឱ្យជំនួសជីវិតមនុស្សលោក។ ដូច្នេះ ពួកសាសន៍យូដាគេជជែកគ្នាថា ធ្វើដូចម្ដេចឱ្យអ្នកនេះអាចនឹងឱ្យសាច់ខ្លួន មកយើងបរិភោគបាន។ នោះព្រះយេស៊ូវមានព្រះបន្ទូលទៅគេថា ប្រាកដមែនខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា បើអ្នករាល់គ្នាមិនពិសាសាច់ ហើយមិនផឹកឈាមរបស់កូនមនុស្ស នោះអ្នករាល់គ្នាគ្មានជីវិតនៅក្នុងខ្លួនទេ។ អ្នកណាដែលបរិភោគសាច់និងឈាមរបស់ខ្ញុំ នោះមានជីវិតដ៏នៅអស់កល្បជានិច្ច ហើយខ្ញុំនឹងឱ្យអ្នក

នោះរស់ឡើងវិញ នៅថ្ងៃចុងបំផុត។ ពីព្រោះសាច់ខ្ញុំជាអាហារពិត ហើយឈាមខ្ញុំក៏ជាគ្រឿងផឹកពិតប្រាកដ។ អ្នកណាដែលបរិភោគសាច់ និងឈាមរបស់ខ្ញុំ នោះនៅក្នុងខ្ញុំ ហើយខ្ញុំក៏នៅក្នុងអ្នកនោះដែរ។ អ្នកណាដែលបរិភោគខ្ញុំ អ្នកនោះនឹងរស់ដោយសារខ្ញុំ ដូចជាព្រះវរបិតាដ៏មានព្រះជន្មរស់ ទ្រង់បានចាត់ឱ្យខ្ញុំមក ហើយខ្ញុំក៏រស់នៅដោយសារទ្រង់ដែរ។ នំប៉័ងនេះជានំប៉័ង ដែលចុះពីស្ថានសួគ៌មកជាពិត មិនមែនដូចជាពួកអយ្យកោអ្នករាល់គ្នា បានបរិភោគនំម៉ាន៉ា ហើយក៏ស្លាប់ទៅនោះទេ គឺអ្នកណាដែលបរិភោគនំប៉័ងនេះ នឹងរស់នៅអស់កល្បជានិច្ចវិញ។ ទ្រង់មានព្រះបន្ទូលសេចក្តីទាំងនេះក្នុងសាលាប្រជុំនៅកាពើណិម កំពុងដែលទ្រង់បង្រៀនគេ។ ពួកសិស្សទ្រង់ជាច្រើន ដែលឮសេចក្តីនោះ ក៏និយាយថា ពាក្យនេះពិបាកស្តាប់ណាស់ តើអ្នកណាយល់បាន។″ យ៉ូហាន 6:1-60

តើគួរឱ្យកាន់តែស្អប់ខ្ពើមថែមទៀតដែលគេ ធ្វើឱ្យព្រះអង្គនិងសាសនាជាខែលបិទបាំង ដើម្បីទទួលបាននិងរីករាយជាមួយនឹងលោកិយនេះ! យើងក៏មិនបានរកឃើញអ្នកផ្សេងណាដែលក្លែងខ្លួន ជាមនុស្សកំពុត អារក្ស និងមេធ្មប់ ដែលមានគំនិតបែបនេះសោះឡើយ។

"1. អ្នកក្លែងបន្លំ ដោយសារនៅពេលដែលលោក ហាម៉័រនិងលោកសេខេមមានគំនិតទៅកាន់កូនស្រីនិងសត្វរបស់លោកយ៉ាងកុបនោះ ហើយឃើញថាគ្មានផ្លូវណាដែលគេអាចចូរទៅកាន់ពួកគេបាននោះ តែដោយផ្លូវតែមួយគត់គឺការទទួលការកាត់ស្បែក នោះពួកគេនិយាយទៅកាន់គ្នារបស់ពួកគេថា

ប្រសិនបើពួកប្រុសៗរបស់យើងនឹងទទួលការកាត់ស្បែក ដូចជាពួកគេដែរ តើមិនត្រូវឱ្យហ្វូងសត្វរបស់ពួកគេនិងរបស់របររបស់ពួកគេ និងគ្រប់សត្វទាំងអស់របស់ពួកគេក្លាយជារបស់យើងទេឬអី? កូនស្រីៗរបស់ពួកគេនិងហ្វូងសត្វជាអ្វីដែលពួកគេចង់បាន ហើយសាសនារបស់ពួកគេជាកំបាំងមុខដែលគេប្រើដើម្បីចូលមករកពួកគេនោះ។ សូមអានសាច់រឿងទាំងមូលទៅ។

"នោះហាម៉ោរ និងស៊ីគែមជាបុត្រក៏ទៅឯទ្វារក្រុង មានព្រះបន្ទូលនឹងពួកមនុស្សនៅទីក្រុងទ្រង់ថា មនុស្សទាំងនោះគេមានសេចក្តីមេត្រីនឹងយើងទេ ដូច្នេះ ចូរឱ្យគេអាស្រ័យនៅក្នុងស្រុក និងធ្វើជំនួញជួញប្រែចុះ ដ្បិតមើលស្រុកនេះធំល្មមឱ្យគេនៅបាន ចូរយើងយកកូនស្រីរបស់គេមកធ្វើជាប្រពន្ធ ហើយឱ្យកូនស្រីរបស់ពួកយើងទៅគេដែរ។ តែដែលគេនឹងព្រមនៅជាមួយនឹងយើង ហើយត្រឡប់ជាសាសន៍តែ១ នោះលុះត្រាតែកាលណាពួកប្រុសៗទាំងអស់ខាងយើងបានកាត់ស្បែកដូចជាគេដែរ។ ដូច្នេះ តើហ្វូងគោ ទ្រព្យសម្បត្តិ និងសត្វរបស់គេទាំងអស់មិនត្រឡប់មកជារបស់ផងយើងទេឬអី ចូរយើងគ្រាន់តែព្រមតាមគេប៉ុណ្ណោះ នោះគេនឹងនៅជាមួយនឹងយើងហើយ" **លោកុប្បត្តិ 34:20-23**

"2. ពួកកំពុតផារីស៊ីក៏នៅក្នុងសាសនាបែបនេះដែរ មានការអធិស្ឋានវែងៗដែលជាការសម្តែងរបស់ពួកគេ តែដើម្បីនឹងចង់បានផ្ទះរបស់ស្ត្រីមេម៉ាយដែលជាគោលបំណងរបស់ពួកគេ ហើយការដាក់ទោសខ្លាំងជាងនេះមកពីព្រះនោះជាសេចក្តីជំនុំជំរះមកដល់ពួកគេ។

"ចូរប្រុងប្រយ័តនឹងពួកអាចារ្យ ដែលគេចូលចិត្តពាក់អាវវែងដើរចុះឡើង ក៏គាប់ចិត្តឱ្យមនុស្សគំនាប់គេនៅទីផ្សារ ហើយចង់អង្គុយកន្លែងមុខគេ ក្នុងសាលាប្រជុំ និងកន្លែងដ៏ប្រសើរបំផុត ក្នុងការស៊ីលៀង។ តែគេឆស៊ីផ្ទះស្រីមេម៉ាយ ទាំងដោះសាខ្លួន ដោយសូត្រធម៌ឱ្យច្រើន អ្នកទាំងនោះឯងនឹងត្រូវទោសធ្ងន់ជាងទៅទៀត។" លូកា 20:46, 47

"3.យ៉ូដាសជាអារក្សក៏នៅក្នុងសាសនានេះដែរ។ គាត់ជាអ្នកកាន់សាសនាសម្រាប់ថង់ប្រាក់ ដែលគាត់នឹងអាចកាន់កាប់នូវអ្វីដែលនៅក្នុងថង់នោះ។ តែគាត់ត្រូវបានវង្វេង ត្រូវបោះបង់ចោល ហើយជាកូនរបស់ស្ថាននរកវិញ។

"4. ស៊ីម៉ូនដែលជាគ្រូអាគមន៍ក៏នៅក្នុងសាសនានេះដែរ។ ដោយសារគាត់ចង់បានព្រះវិញ្ញាណបរិសុទ្ធ ដោយប្រើលុយដែលគាត់មាន ហើយគាត់ទទួលបានការដាក់ទោសពីលោកពេត្រុសដូចតទៅនេះ។

"សូមឱ្យខ្ញុំមានអំណាចនេះផង ដើម្បីឱ្យខ្ញុំដាក់ដៃលើអ្នកណា ឱ្យអ្នកនោះបានទទួលព្រះវិញ្ញាណបរិសុទ្ធដែរ។ តែពេត្រុសឆ្លើយតបថា ចូរឱ្យប្រាក់អ្នកវិនាសទៅជាមួយនឹងអ្នកចុះ ព្រោះអ្នកស្មានថា នឹងយកប្រាក់មកទិញអំណោយទានរបស់ព្រះបានដូច្នេះ។ អ្នកគ្មានភាគគ្មានចំណែកក្នុងការនេះឡើយ ព្រោះចិត្តអ្នកមិនស្មោះត្រង់ចំពោះព្រះទេ។ ដូច្នេះ ចូរប្រែចិត្តចេញពីសេចក្ដីអាក្រក់នេះចុះ ហើយសូមអង្វរដល់ព្រះអម្ចាស់វិញ ក្រែងទ្រង់នឹងអត់ទោសដល់គំនិតក្នុងចិត្តអ្នកបាន" កិច្ចការ 8:19-22

"5. ក៏វាមិនចេញពីក្នុងគំនិតខ្ញុំដែរ តែបុរសនោះបានយកសាសនាសម្រាប់លោកិយ ហើយនឹងបោះបង់សាសនាសម្រាប់លោកិយដែរ។ គឺដូចជាយ៉ូដាសបានកែច្នៃលោកិយដោយធ្វើជាអ្នកកាន់សាសនា ពិតណាស់គាត់ក៏បានលក់សាសនានិងព្រះអម្ចាស់របស់គាត់សម្រាប់ការនោះដូចគ្នា។ ដើម្បីនឹងឆ្លើយនឹងសំណួរកាន់តែច្បាស់លាស់ទៀត ដូចដែលខ្ញុំបានឃើញអ្នកឆ្លើយរួចហើយនោះ ហើយដើម្បីនឹងទទួលបានអំណាចដូចចម្លើយនេះ ការទាំងពីរនេះសុទ្ធតែជាការក្លែងបន្លំ បែបពុតត្បុត និងអាក្រក់ ហើយរង្វាន់របស់អ្នកនឹងបានមកតាមទង្វើរបស់អ្នក។"

បន្ទាប់មកពួកគេឈរសម្លឹងមើលគ្នាទៅវិញទៅមក តែមិនអាចនឹងឆ្លើយតបនឹងគ្រីស្ទានបានឡើយ។ ពេញដោយសង្ឃឹមក៏បានយល់ស្របនឹងភាពត្រឹមត្រូវនៃចម្លើយរបស់គ្រីស្ទានផងដែរ។ ដូច្នេះក៏មានភាពស្ងប់ស្ងាត់យ៉ាងខ្លាំងនៅចំណោមពួកគេ។ លោកដល់ទីបញ្ចប់និងគ្នីគ្នាមានការភ្ញាក់ផ្អើលហើយក៏នៅខាងក្រោយ ដើម្បីឱ្យគ្រីស្ទាននិងពេញដោយសង្ឃឹមបានដើរទៅមុខហួសទៅ។ បន្ទាប់មកគ្រីស្ទាននិយាយទៅកាន់សំឡាញ់របស់គាត់ថា "ប្រសិនបើមនុស្សទាំងនេះមិនអាចឈរនៅចំពោះការកាត់ក្តីរបស់មនុស្សផង តែពួកគេនឹងធ្វើអ្វីបាននៅចំពោះការកាត់ទោសរបស់ព្រះនោះ? ហើយប្រសិនបើពួកគេគ នៅពេលដោះស្រាយជាមួយនឹងភាជនៈដីឥដ្ឋទៅហើយ តើពួកគេនឹងធ្វើអ្វីបានពេលដែលត្រូវស្តីបន្ទោសដោយអណ្តាតភ្លើងដែលត្របាក់លេបវិញនោះ?"

**ដេម៉ាស់**

បន្ទាប់មកគ្រីស្ទាននិងពេញដោយសង្ឃឹមចេញពីពួកគេម្តងទៀត ហើយបានទៅរហូតទាល់តែមកដល់ទីវាលមួយដែលងាយខូចខាតដែលហៅថា ងាយស្រួល ជាកន្លែងដែលពួកគេដើរទៅដោយស្កប់ចិត្តណាស់។ តែទីវាលនោះចង្អៀតពេក ដូច្នេះពួកគេចេញពីនោះយ៉ាងរហ័ស។ ពេលនេះ នៅចំហៀងពីចម្ងាយនៃទីវាលនេះមានមានភ្នំតូចមួយហៅថា លុយ ហើយនៅលើភ្នំនោះមានរណ្តៅប្រាក់ ដែលពីដើមមានពួកគេខ្លះបានទៅតាមផ្លូវនោះ ដោយសារភាពកម្ររបស់វា នោះគេបានត្រឡប់ទៅមើលវា តែទៅជិតមាត់រណ្តៅពេកក៏មានដីដែលបញ្ឆោតនៅខាងក្រោមនោះ ក៏បាក់ ហើយពួកគេក៏ត្រូវបានសម្លាប់ទៅ។ អ្នកខ្លះក៏ត្រូវមានគ្រោះថ្នាក់នៅទីនោះ ហើយរហូតដល់ថ្ងៃស្លាប់ពួកគេមិនអាចខ្លួនរបស់ពួកគេម្តងទៀតឡើយ។

បន្ទាប់មកខ្ញុំបានឃើញនៅក្នុងសុបិនរបស់ខ្ញុំថា ចេញពីផ្លូវបន្តិច នៅទល់នឹងរណ្តៅប្រាក់ មាន ដេម៉ាស់ ឈរនៅទីនោះ (ដូចជាសុភាពបុរស) ដើម្បីនឹងហៅអ្នកធ្វើដំណើរមកមើល គាត់បាននិយាយទៅកាន់គ្រីស្ទាននិងគ្នាគាត់ថា "ហូ បែរមកក្បែរនេះ ខ្ញុំនឹងបង្ហាញការមួយដល់អ្នក។"

គ្រីស្ទាន៖ តើរបស់អ្វីទៅដែលពិតជាសាកសមឱ្យយើងបែរចេញពីផ្លូវទៅមើលនោះ?
ដេម៉ាស់៖ នេះជារណ្តៅប្រាក់ ហើយអ្នកខ្លះបានជីករកកំណាប់ក្នុងនេះ។ ប្រសិនបើអ្នកមក ដោយឈឺចាប់តិចតួចទេអ្នកនឹងទទួលបានជាបរិបូរណ៍សម្រាប់ខ្លួនអ្នកវិញ។

ពេញដោយសង្ឃឹមៈ បន្ទាប់មកពេញដោយសង្ឃឹមនិយាយថា "តោះយើងទៅមើលទៅ។"

គ្រីស្ទានៈ "ខ្ញុំមិនទៅទេ" គ្រីស្ទាននិយាយថា "ខ្ញុំបានឮពីទីនេះពីមុខមក ហើយឮថាមនុស្សជាច្រើនត្រូវបានគេសម្លាប់ ហើយក្រៅពីនោះ កំណាប់នោះគឺជាអន្ទាក់ដល់អ្នកដែលស្វែងរកវា ដោយវាពាំងពួកគេនៅក្នុងការធ្វើធម្មយាត្រារបស់ពួកគេ។" បន្ទាប់មកគ្រីស្ទានបានហៅទៅកាន់ ដេម៉ាស់ ដោយនិយាយថា "តើកន្លែងនោះមិនគ្រោះថ្នាក់ទេឬ? តើវាមិនបានរាំងមនុស្សជាច្រើននៅក្នុងដំណើរធម្មយាត្រារបស់ពួកគេទេឬ?"

**"ដ្បិតអ៊ីស្រាអែលបានប្រព្រឹត្តដោយរឹងចចេស ដូចជាគោក្រមុំក្រាញ ឥឡូវនេះ តើព្រះយេហូវ៉ាទ្រង់ត្រូវឃ្វាលគេ ដូចកូនចៀម នៅទីវាលធំទូលាយឬអី។ ឯអេប្រាអ៊ីមវាភ្ជាប់ខ្លួនតាមរូបព្រះហើយ តាមតែវាចុះ។ គ្រឿងផឹករបស់គេបានទៅជាជូរហើយ គេប្រព្រឹត្តសេចក្តីកំផិតជានិច្ច ឯពួកគ្រប់គ្រងលើគេក៏គាប់ចិត្តចំពោះតែអំពើគួរខ្មាស។ ខ្យល់បានក្តោបគេដោយស្លាប គេនឹងត្រូវមានសេចក្តីខ្មាស ដោយព្រោះយញ្ញបូជាទាំងប៉ុន្មានរបស់ខ្លួន។" ហូសេ 4:16-19**

ដេម៉ាស់ៈ"មិនគ្រោះថ្នាក់ប៉ុន្មានទេ លើកលែងតែអស់អ្នកណាដែលមិនប្រយ័ត្នប៉ុណ្ណោះ" តែគាត់និយាយ ទាំងទឹកមុខខ្មាសអៀន

គ្រីស្ទានៈ បន្ទាប់មកគ្រីស្ទាននិយាយទៅកាន់ពេញដោយសង្ឃឹមថា "តោះ យើងកុំឈានសូម្បីតែមួយជំហានទៅឡើយ តែនៅតែដើរតាមផ្លូវរបស់យើងវិញ។"

សង្ឃឹមៈ ខ្ញុំធានាថា នៅពេលដែលលោកដល់ទីបញ្ចប់មកដល់ ប្រសិនបើគាត់ទទួលបានការអញ្ជើញដូចពួកយើង គាត់នឹងបែរចូលទៅមើលនៅទីនោះមិនខានឡើយ។

គ្រីស្ទានៈ ការនោះគ្មានអ្វីត្រូវសង្ស័យឡើយ ដោយសារគោលការណ៍របស់គាត់នាំទៅរកផ្លូវនោះហើយ ហើយពីមួយរយទល់នឹងមួយថា គាត់នឹងស្លាប់នៅទីនោះ។

ដេម៉ាស់ៈ បន្ទាប់លោក ដេម៉ាស់ បានហៅម្តងទៀតនិយាយថា "តើអ្នកមិនគិតចូលមកមើលទេឬអី?"

គ្រីស្ទានៈ បន្ទាប់មកគ្រីស្ទានឆ្លើយដដែលថា "លោក ដេម៉ាស់អើយ អ្នកជាសត្រូវនឹងផ្លូវត្រឹមត្រូវរបស់ព្រះជាម្ចាស់នៃផ្លូវនេះ ហើយអ្នកត្រូវបានដាក់ទោសរួចហើយដោយចៅក្រមរបស់ព្រះដែលមានគ្រប់អំណាចចេស្តាដែលអ្នកបានបែរចេញ ហេតុអ្វីបានជាអ្នកចង់ឱ្យពួកយើងធ្លាក់ចូលការកាត់ទោសដូចនោះដែរ?

**“ដ្បិតអ្នកដេម៉ាសបានលះចោលខ្ញុំហើយ ដោយគាត់ស្រឡាញ់លោកិយនេះ គាត់បានទៅឯក្រុងថែស្សាឡូនិចហើយ អ្នកក្រេសេនបានទៅឯស្រុកកាឡាទី ហើយអ្នកទីតុសក៏បានទៅកាន់ស្រុកដាល់ម៉ាទា។” ធីម៉ូថេទី២ 4:10**

ក្រៅពីនោះ ប្រសិនបើយើងបែរចេញវិញ ព្រះអម្ចាស់របស់យើងដែលជាស្ដេចនឹងស្អាប់ពួផង ហើយនឹងធ្វើឱ្យយើងត្រូវអាម៉ាស់ នៅកន្លែងដែលយើងគួរតែឈរដោយក្លាហាននៅចំពោះទ្រង់។”

ដេម៉ាស់ស្រែកឡើងម្ដងទៀត ដែលថាគាត់ជាម្នាក់នៅក្នុងក្រុមរបស់ពួកគេ ហើយប្រសិនបើពួកគេនឹងបន្តនៅបន្តិចទៀតនោះ គាត់ផ្ទាល់នឹងដើរទៅជាមួយពួកគេដែរ។

គ្រីស្ទាន៖ បន្ទាប់មកគ្រីស្ទាននិយាយថា "តើអ្នកឈ្មោះអ្វី? តើមិនមែនជាឈ្មោះដូចដែលខ្ញុំបានហៅអ្នកទេឬអី?"

ដេម៉ាស់៖ បាទ ឈ្មោះរបស់ខ្ញុំគឺដេម៉ាស់។ ខ្ញុំជាកូនប្រុសរបស់លោកអ័ប្រាហាំ។

គ្រីស្ទាន៖ ខ្ញុំស្គាល់អ្នកដែរ។ គេហាស៊ីជាតាទួតរបស់អ្នក ហើយយូដាសជាឪពុករបស់អ្នក ហើយអ្នកបានដើរតាមជំហានរបស់ពួកគេ។ វាគ្រាន់តែជាការបញ្ឆោតរបស់អារក្សដែលអ្នកប្រើតែប៉ុណ្ណោះ។ ឪពុករបស់អ្នកត្រូវបានព្យួរកដោយសារតែបានក្បត់ ហើយអ្នកមិនសាកសមនឹងរង្វាន់ណាដែលប្រសើរឡើយ។

“ឯកេហាស៊ី ជាអ្នកបម្រើរបស់អេលីសេ ជាអ្នកសំណប់របស់ព្រះ គាត់នឹកថា មើល ចៅហ្វាយអញបានយល់ដល់ណាម៉ាន់ជាសាសន៍ស៊ីរីនោះ ដោយមិនបានទទួលរបស់ស្នងពីដៃលោក ដែលនាំមកជូននោះសោះ អញស្បថដោយនូវព្រះយេហូវ៉ា ដ៏មានព្រះជន្មរស់នៅថា អញនឹងរត់ទៅតាម ហើយទទួលយករបស់ខ្លះពីលោកវិញ។” ពង្សាវតារក្សត្រទី២ 5:20

“នៅគ្រានោះ មានម្នាក់ក្នុងពួក១២នាក់ ឈ្មោះ យូដាស អ៊ីស្ការីយ៉ុត វាទៅឯពួកសង្គ្រាជសួរថា បើបញ្ជូនអ្នកនោះមកលោក តើលោកនឹងឱ្យអ្វីដល់ខ្ញុំ រួចគេសម្រេចនឹងឱ្យប្រាក់៣០រៀលដល់វា។” ម៉ាថាយ 26:14, 15

“ដល់ព្រឹកឡើង ពួកសង្គ្រាជ និងពួកចាស់ទុំនៃបណ្តាជន គេពិគ្រោះគ្នាទាស់នឹងព្រះយេស៊ូវ ដើម្បីនឹងសម្លាប់ទ្រង់។ ក៏ចងទ្រង់ដឹកជញ្ជូនទៅឯចៅហ្វាយស្រុកឈ្មោះ ប៉ុនទាស–ពីឡាត់។ កាលយូដាស ជាអ្នកបញ្ជូនទ្រង់បានឃើញថាទ្រង់ជាប់ទោសដូច្នោះ នោះវានឹកស្តាយ ក៏យកប្រាក់៣០ទៅឱ្យដល់ពួកសង្គ្រាជ និងពួកចាស់ទុំវិញ ដោយពាក្យថា ខ្ញុំបានជាធ្វើបាប ដោយបញ្ជូនឈាមឥតមានទោសហួសទៅហើយ តែគេឆ្លើយថា តើនោះអំពល់អ្វីដល់យើង ការនោះស្រេចនៅឯងទេតើ។ វាក៏បោះប្រាក់ចោលទៅក្នុងព្រះវិហារ រួចចេញទៅក្រៅអួលស្មះស្លាប់ទៅ។” ម៉ាថាយ 27:1-5

ចូរអ្នកដឹលប្រាកដថា ពេលដែលយើងទៅដល់ស្តេច យើងនឹងប្រាប់ទ្រង់ពីទង្វើរបស់អ្នក។

ដូច្នេះពួកគេក៏ទៅតាមផ្លូវរបស់ពួកគេទៅ។

មកដល់ពេលនេះលោកដល់ទីបញ្ចប់និងគ្នីគ្នាបានមកដល់ទីនេះម្តង។ ដំបូងឡើយពួកគេសូមទៅកាន់លោកដេម៉ាស់។ ឥឡូវនេះ មិនថាពួកគេនឹងធ្លាក់ចូលទៅក្នុងរណ្តៅដោយមើលពីម៉ាត់រណ្តៅ ឬពួកគេចុះទៅដើម្បីជីកនោះទេ ឬពួកគេត្រូវរុំព័ទ្ធដោយដីស្អិតនៅបាតរណ្តៅដែលធម្មតាតែងតែឡើងមកនោះទេ ពីការនោះខ្ញុំមិនប្រាកដនោះទេ តែខ្ញុំសង្កេតឃើញថា ពួកគេមិនលេចមកឱ្យឃើញម្តងទៀតនៅតាមផ្លូវឡើយ។ បន្ទាប់មកគ្រីស្ទានច្រៀងថា

‶ដល់ទីបញ្ចប់និងដេម៉ាស់ជាប្រាក់ពិតជាយល់ស្របគ្នា។ ម្នាក់ស្រែកហៅ ហើយម្នាក់ទៀតរត់ ថាគេនឹងបានចែករំលែកលុយរបស់គាត់។ ដូច្នេះអ្នកទាំងពីរនេះមានតែនៅក្នុងលោកិយនេះទេ និងមិនអាចទៅបានលើសនេះឡើយ។"

## ចូរចងចាំពីប្រពន្ធឡុត

ពេលនេះខ្ញុំឃើញថា នៅម្ខាងទៀតនៃវាលនោះ មានអ្នកធ្វើធម្មយាត្រាម្នាក់មកដល់កន្លែងមួយដែលមានបូជនីយដ្ឋានចាស់មួយនៅឈរទីនោះយ៉ាងមាំនៅផ្លូវធំ ពួកគេទាំងពីរមានភាពខ្វល់ខ្វាយដោយរូបភាពនោះ ដោយសារតែភាពចម្លែកនៃរូបរាងនោះ ព្រោះចំពោះពួកគេវាហាក់ដូចជារូបមនុស្សស្រីម្នាក់ដែលបានផ្លាស់ប្រែទៅជារូបរាងនៃសសរមួយ។ ដូច្នេះនៅទីនេះ ពួកគេបានឈរមើលហើយមើលទៀត តែអស់មួយរយៈមកពួកគេមិនអាចប្រាប់បានថាវាជាអ្វី។ ចុងក្រោយ ពេញដោយសង្ឃឹមបានក្រលេកឃើញអក្សរដែលបានសរសេរនៅលើក្បាលនោះដោយអក្សរសរសេរដៃមិនធម្មតាមួយ។ ដោយគាត់មិនមែនជាអ្នកប្រាជ្ញអ្វីក៏ហៅគ្រីស្ទាន (ដោយសារគាត់បានរៀនសូត្រ) ឱ្យមកមើល ក្រែងគាត់អាចទាញយកន័យរបស់វាបាន។ ដូច្នេះគាត់ក៏មកហើយបន្ទាប់ពីបានរៀបអក្សរចូលគ្នាមក គាត់បានរកឃើញការដូច្នេះ "ចូរចង់ចាំប្រពន្ធឡុត!" ដូច្នេះគាត់បានអាចវាប្រាប់ដល់គ្នាគាត់។ បន្តិចមកពួកគេក៏សន្មត់ថា វាជាសសរអំបិលដែលប្រពន្ធឡុតបានប្រែក្លាយទៅដោយសារគាត់បានបែរត្រឡប់មើលក្រោយដោយចិត្តដែលលោភលន់ នៅពេលគាត់កំពុងគេចចេញពីក្រុងសូដុំមរកទីសុវត្ថិភាព។

**"ឯប្រពន្ធឡុតក៏ងាកបែរមើលទៅក្រោយវិញ នោះស្រាប់តែទៅជាបង្គោលអំបិលទៅ។" លោកុប្បត្តិ 19:26**

រូបភាពបន្ទាន់និងគួរឱ្យភ្ញាក់ផ្អើលនោះបានធ្វើឱ្យពួកគេយកឱកាសដើម្បីនឹងជជែកគ្នា។

គ្រីស្ទាន៖ អា បងប្អូនខ្ញុំអើយ នេះជារូបភាពមួយដែលសមហេតុផលណាស់។ វាបានមកស្របពេលបន្ទាប់ពីយើងបានទទួលការអញ្ជើញពីលោកដេម៉ាស់ទៅមើលភ្នំលុយនោះ ដែលចង់ឱ្យយើងឈៀងចូលទៅតាមគាត់ចង់បាន ហើយដែលអ្នកមានទំនោរចង់ទៅដែរនោះបងប្អូនខ្ញុំអើយ។ តាមដែលខ្ញុំដឹងយើងអាចនឹងធ្វើខ្លួនដូចជាស្ត្រីម្នាក់នេះដែរ ធ្វើជារូបតំណាងសម្រាប់ឱ្យអ្នកមកក្រោយមើល។

សង្ឃឹម៖ ខ្ញុំសូមទោសដែលខ្ញុំល្ងីល្ងើ ហើយត្រូវធ្វើឱ្យវង្វេងថាពេលនេះខ្ញុំដូចជាប្រពន្ធឡុត ដោយសារ តើមានអ្វីខុសគ្នារវាងអំពើបាបរបស់នាងនិងអំពើបាបរបស់ខ្ញុំនោះ? នាងគ្រាន់តែមើលទៅក្រោយប៉ុណ្ណោះ ហើយខ្ញុំមានបំណងចង់ទៅមើលផង។ ចូរកាន់ខ្ជាប់នូវព្រះគុណវិញ ហើយសូមឱ្យខ្ញុំត្រូវអាម៉ាស់ ដែលការដូច្នេះមាននៅក្នុងចិត្តរបស់ខ្ញុំ!

គ្រីស្ទាន៖ ចូរយើងកត់ចំណាំនូវអ្វីដែលយើងឃើញនៅទីនេះ សម្រាប់ជាជំនួយដល់យើងនូវវេលាណាវាមកដល់។ ស្ត្រីនេះបានគេចផុតពីការកាត់ទោសមួយ ដោយសារនាងមិនបានដួលចុះដោយការបំផ្លាញក្រុងសូដុំមទេ តែនាងត្រូវបំផ្លាញដោយការមួយផ្សេងទៀត ដូចដែលយើងឃើញហើយនាងបានក្លាយទៅជាសសរអំបិល។

សង្ឃឹមះ ពិតណាស់ ហើយនាងនឹងក្លាយជាបម្រាមនិងឧទាហរណ៍ដល់យើង បំរាមដែលថាយើងគួរតែជៀសចេញពីអំពើបាបរបស់នាង ឬជាសញ្ញាមួយពីអ្វីដែលជាការកាត់ទោសដែលនឹងត្រូវមកដោយខានមិនបានដោយការប្រយ័ត្ននេះ។ ដូច្នេះ កូរ៉ា ដាថាន់ និងអាប៊ីរ៉ាម ជាមួយនឹងមនុស្ស២៥០នាក់ទៀតត្រូវវិនាសនៅក្នុងអំពើបាបរបស់ពួកគេ ក៏បានក្លាយជាសញ្ញានិងគម្រូដល់អ្នកដទៃទៀតឱ្យប្រយ័ត្នផងដែរ។

**"ហើយកូនរបស់អេលាប  គឺនេមូល១ ដាថាន១ អ័ប៊ីរ៉ាម១ គឺដាថាន និងអ័ប៊ីរ៉ាមនេះហើយដែលគេបានហៅមកឯពួកជំនុំ ជាបានលើកគ្នាទាស់នឹងម៉ូសេ ហើយនិងអើរ៉ុន ជាមួយនឹងពួកកូរេ ក្នុងកាលដែលពួកកូរេ បានលើកគ្នាទាស់ទទឹងនឹងព្រះយេហូវ៉ា។ តែដីបានហាឡើង ទទួលស្រូបយកគេជាមួយនឹងកូរេទៅ ក្នុងកាលដែលពួកកូរេនោះត្រូវស្លាប់ ហើយក៏មានភ្លើងឆេះមនុស្ស២៥០នាក់ដែរ ពួកនោះឯងបានត្រឡប់ជាគំរូដល់បណ្តាជន។" ជនគណនា 26:9, 10**

បន្ថែលើសពីនោះទៅទៀត ខ្ញុំនឹងសើចដោយការមួយគឺ របៀបដែលដេម៉ាស់និងគ្នារបស់គាត់អាចឈរដោយទំនុកចិត្តសម្លឹងមើលទ្រព្យសម្បត្តិនោះដែលស្ត្រីម្នាក់នេះបានបែរមើលក្រោយនាងបន្ទាប់មក (ដោយយើងបានអានថានាងមិនបានឈានមួយជំហានចេញពីផ្លូវឡើយ) បានប្រែក្លាយទៅជាបង្គោលអំបិលទៅ ជាពិសេសក្នុងកាលដែលការជំនុំជំរះបានធ្លាក់មកលើនាង បានធ្វើឱ្យនាងក្លាយជាឧទាហរណ៍ជារូបរាងដែលឈរនៅនោះ

ដោយសារពួកគេត្រូវតែមើលឃើញនាង នៅពេលដែលពួកគេងើយភ្នែកឡើង។

គ្រឹស្ថានៈ វាជារឿងមួយដែលយើងគួរតែពិចារណា ហើយវាបានវែកញែកថាចិត្តរបស់ពួកគេកាន់តែចង់បាននៅក្នុងកាលនោះ ហើយខ្ញុំមិនអាននឹងប្រាប់បានថានឹងត្រូវប្រៀបធៀបពួកគេទៅអ្នកណាឱ្យសមទេ ដែលពួកគេបានលួចឆក់លុយនៅក្នុងវត្តមានរបស់ចៅក្រម ឬដែលនឹងកាត់កាបូបលុយនៅក្រោមសសរព្យួរក។ មានគេនិយាយពីមនុស្សនៅក្រុងសូដុំមថា ពួកគេជាមនុស្សមានបាបខ្លាំងណាស់។

**"ឡុតក៏ងើបភ្នែកទៅឃើញវាលទន្លេយ័រដាន់ទាំងអស់ ថាជាស្រុកមានទឹកស្រួលល្អនៅគ្រប់ទីកន្លែង មុនដែលព្រះយេហូវ៉ាបានបំផ្លាញសូដុំម និងកូម៉ូរ៉ាក៏ដូចជាសួនច្បារផងព្រះយេហូវ៉ា ហើយដូចជាស្រុកអេស៊ីព ដែលនៅសូអារផង។" លោកុប្បត្តិ 13:10**

**"រីឯពួកក្រុងសូដុំម គេជាមនុស្សអាក្រក់ ធ្វើបាបនឹងព្រះយេហូវ៉ាសន្ធឹក។" លោកុប្បត្តិ 13:13**

ដោយសារពួកគេជាមនុស្សមានបាប "នៅចំពោះព្រះ" ដែលនៅចំពោះព្រះនេត្ររបស់ទ្រង់ ហើយក្រៅពីសេចក្តីសប្បុរសដែលទ្រង់បានបង្ហាញដល់ពួកគេ ដោយសារទឹកដីសូដុំមពេលនោះដូចជាសួនច្បារអេដែនផង។ ដូច្នេះការនោះធ្វើឱ្យទ្រង់មានសេចក្តីប្រច័ណ្ឌផង ធ្វើឱ្យមានគ្រោះដែលក្តៅដូចជាភ្លើ

ងរបស់ព្រះអម្ចាស់ចេញមកពីលើមេឃមក។ ហើយវាសមហេតុផលដែលសរុបមកថា ការដូចនេះដែលបានធ្វើបាបនៅចំពោះព្រះនេត្ររបស់ព្រះ ហើយការនោះផងដែរដែលបានធ្វើជាគំរូជាបន្តមកដល់ពួកគេ ហាមពួកគេឱ្យគេចពីវា នឹងត្រូវចូលរួមនៅក្នុងការជំនុំជំរះដ៏សាហាវបំផុត។

សង្ឃឹម៖ គ្មានសង្ស័យឡើយអ្នកបាននិយាយសេចក្តីពិត តែតើវាជាសេចក្តីមេត្តាយ៉ាងណាហ្ន៎ដែលអ្នក ជាពិសេសរូបខ្ញុំមិនបានធ្វើឱ្យខ្លួនទៅជាគំរូដូចនេះនោះ! ការនេះធ្វើឱ្យយើងបានអរព្រះគុណព្រះអម្ចាស់ ឱ្យបានកោតខ្លាចនៅចំពោះទ្រង់ និងឱ្យតែងតែ "ចង់ចាំប្រពន្ធឡុត" ជានិច្ច។

## ពេលសម្រាក

ខ្ញុំបានឃើញទៀតថា ពួកគេបានដើរតាមផ្លូវរបស់ពួកគេដល់ទន្លេដែលគួរគាត់ដល់ចិត្តមួយ ដែលស្តេចដាវីឌហៅថា "ទន្លេរបស់ព្រះ" តែយ៉ូហានហៅថា "ទន្លេនៃទឹកជីវិត។"

**"ទ្រង់ក៏ថែរក្សា ហើយស្រោចស្រប់ផែនដី ព្រមទាំងធ្វើឲ្យមានផលកាន់តែច្រើនឡើង ដោយទន្លេនៃព្រះមានទឹកពេញ រួចទ្រង់ផ្គត់ផ្គង់ឲ្យមានស្រូវ ដោយរៀបចំផែនដីយ៉ាងនោះ" ទំនុកដំកើង 65:9**

“ទេវតាក៏បង្ហាញ ឲ្យខ្ញុំឃើញទន្លេទឹកជីវិតថ្លាដូចជាកែវចរណៃ ដែលហូរចេញពីបល្ល័ង្កនៃព្រះ និងកូនចៀម។ ឯនៅកណ្តាលផ្លូវក្រុងនោះ ហើយនៅមាត់ទន្លេទាំងសងខាង នោះមានដើមជីវិត ដែលបង្កើតផ្លែ១២ដង គឺ១ខែម្តងៗ ហើយស្លឹកឈើនោះ ក៏សម្រាប់នឹងមើលអស់ទាំងសាសន៍ឲ្យជា” វិវរណៈ 22:1, 2

“រួចលោកនាំខ្ញុំវិលទៅឯទ្វារនៃព្រះវិហារវិញ នោះឃើញមានទឹកចេញពីក្រោមមាត់ទ្វារនៃព្រះវិហារខាងកើត ដ្បិតមុខព្រះវិហារបែរទៅទិសខាងកើត ហើយទឹកនោះហូរមកពីខាងក្រោម ពីខាងស្តាំនៃព្រះវិហារ គឺពីខាងត្បូងអាសនៈ។ រួចលោកនាំខ្ញុំចេញទៅតាមផ្លូវនៃទ្វារកំផែងខាងជើង ហើយនាំវាងទៅតាមផ្លូវខាងក្រៅ រហូតដល់ទ្វារកំផែងខាងក្រៅដែលបើកទៅខាងកើត នោះឃើញមានទឹកហូរចេញមកខាងស្តាំ។ លុះបានចេញទៅខាងកើត មនុស្សនោះក៏វាស់១ពាន់ហត្ថ ដោយខ្សែដែលកាន់នៅដៃ នោះលោកឲ្យខ្ញុំលុយកាត់ទឹក ឯទឹកនោះបានត្រឹមភ្នែកគោ។ លោកក៏វាស់១ពាន់ហត្ថទៀត រួចឲ្យខ្ញុំលុយកាត់ទៅ ទឹកត្រង់នោះបានត្រឹមក្បាលជង្គង់ រួចលោកវាស់១ពាន់ហត្ថទៀត ក៏ឲ្យខ្ញុំលុយកាត់ទៅ ត្រង់នោះទឹកបានដល់ត្រឹមចង្កេះ។ ក្រោយនោះ លោកវាស់១ពាន់ហត្ថទៀត នោះមានទន្លេដែលខ្ញុំលុយកាត់មិនបាន ដ្បិតទឹកបានខ្ពស់ឡើង ជាទឹកដែលល្មមហែលបាន គឺជាទន្លេដែលលុយពុំបានទេ។ នោះលោកសួរមកខ្ញុំថា កូនមនុស្សអើយ តើបានឃើញហើយឬ រួចលោកនាំខ្ញុំឲ្យត្រឡប់ទៅឯមាត់ទន្លេនោះវិញ។ កាលខ្ញុំបានត្រឡប់ទៅដល់ហើយ នោះឃើញតាមមាត់ទន្លេ មានដើមឈើជាច្រើន ទាំងខាងនេះ និងខាងនោះផង។ លោកក៏ប្រាប់ខ្ញុំថា ទឹកនេះហូរចេញទៅទិសខាងកើតធ្លាក់ចុះទៅដល់ស្រុកវាល រួចនឹងហូរធ្លាក់ទៅឯសមុទ្រ លុះហូរធ្លាក់ទៅក្នុងសមុទ្រហើយ នោះទឹក

សមុទ្រនឹងទៅជាល្អវិញ។ ហើយគ្រប់ទាំងសត្វមានជីវិត ដែលរវើកនៅគ្រប់កន្លែងណាដែលទន្លេនោះហូរ នឹងបានរស់នៅ ក៏នឹងមានត្រីយ៉ាងសន្ធឹកដោយព្រោះទឹកទាំងនេះបានហូរទៅដល់ទីនោះ ហើយទឹកសមុទ្រនោះនឹងបានល្អ ឯកន្លែងណាដែលទឹកទន្លេនេះហូរទៅដល់ នោះគ្រប់ទាំងអស់នឹងរស់នៅ។ ពួកនេសាទត្រីនឹងឈរនៅមាត់ទឹកនោះ ចាប់តាំងពីអេន-កេឌី រហូតដល់អេន-អេកលែម ទីនោះនឹងបានជាទីសម្រាប់បង់សំណាញ់ ឯត្រីនៅក្នុងទឹកនោះ នឹងមានយ៉ាងសន្ធឹកគ្រប់បែបតាមពូជ ដូចជាត្រីនៅក្នុងសមុទ្រធំដែរ។ តែទីល្បាប់ និងបឹងនៅទីនោះ នឹងមិនបានសាបល្អវិញទេ កន្លែងទាំងនោះនឹងបានទុកសម្រាប់ធ្វើអំបិលវិញ។ ឯតាមមាត់ច្រាំងទាំងសងខាងទន្លេនោះនឹងមានដុះដើមឈើគ្រប់យ៉ាង សម្រាប់ជាអាហារ ជាដើមដែលស្លឹកមិនស្រពោនឡើយ ហើយមិនដែលខានមានផ្លែដែរ គឺនឹងកើតផ្លែថ្មីរាល់តែខែ ពីព្រោះទឹកនោះចេញពីទីបរិសុទ្ធមក ហើយផ្លែឈើទាំងនោះ នឹងបានសម្រាប់ជាអាហារ ឯស្លឹកក៏សម្រាប់នឹងកែរោគឲ្យជាដែរ។" **អេសេគាល 47:1-12**

ពេលនេះផ្លូវរបស់ពួកគេស្ថិតនៅលើមាត់ទន្លេនោះ។ ដូច្នេះនៅទីនេះ គ្រីស្ទាននិងគ្នាគាត់បានដើរដោយមានអំណរយ៉ាងខ្លាំង។ ពួកគេបានផឹកទឹកពីទន្លេនោះ ដែលធ្វើឱ្យមានអំណរនិងធ្វើវិញ្ញាណដែលនឿយណាយបានសប្បាយឡើងវិញ។ ក្រៅពីនោះ នៅលើមាត់ទន្លេ នៅត្រើយម្ខាងទៀត មានដើមឈើខៀវខ្ចី ដែលមានផលផ្លែគ្រប់ប្រភេទ ហើយស្លឹកឈើនោះល្អធ្វើជាថ្នាំព្យាបាល ពួកគេមានសេចក្តីអំណរយ៉ាងខ្លាំងដោយផលផ្លែនៃដើមឈើនោះ ហើយពួកគេចាកចេញដោយញាំរបស់ទាំងនោះការពារជ្រុលហួសកម្រិតនិងជំងឺផ្សេងៗ ដែលគ្រោះថ្នាក់ដល់អស់អ្នកដែលឈាមឡើងក្តៅយ៉ាងខ្លាំង

ដោយសារការធ្វើដំណើរ។ ទាំងសងខាងរបស់ទន្លេមានវាលស្មៅស្រស់ស្អាតខ្លាំងដោយមានផ្កា ហើយវាមានពណ៌បៃតងពេញមួយឆ្នាំ។ នៅវាលស្មៅនេះពួកគេបានផ្តេកខ្លួនហើយដេកលក់ទៅ ដោយសារនៅទីនេះពួកគេអាចដេកបានដោយមានសុវត្ថិភាព។

"ព្រះយេហូវ៉ាទ្រង់ជាអ្នកគង្វាលខ្ញុំ ខ្ញុំនឹងមិនខ្វះអ្វីសោះ ទ្រង់ឲ្យខ្ញុំដេកសម្រាកនៅទីមានស្មៅខៀវខ្ចី ទ្រង់នាំខ្ញុំទៅក្បែរមាត់ទឹកដែលហូរគ្រឿនៗ. ទ្រង់កែព្រលឹងខ្ញុំឡើងវិញ ទ្រង់នាំខ្ញុំទៅតាមផ្លូវសុចរិត ដោយយល់ដល់ព្រះនាមទ្រង់។" **ទំនុកដំកើង 23:1-3**

"នោះកូនច្បងរបស់ពួកមនុស្សទាល់ក្រនឹងមានអាហារបរិភោគ ហើយមនុស្សកំសត់ទុគ៌តនឹងដេកទៅដោយសុខសាន្ត តែអញនឹងធ្វើឲ្យពូជពង្សឯងស្លាប់ទៅដោយអំណាត់អត់វិញ ហើយសំណល់នៃឯងនឹងត្រូវគេសម្លាប់បង់" **អេសាយ 14:30**

នៅពេលដែលពួកគេភ្ញាក់ឡើង ពួកគេបានប្រមូលផ្លែពីដើមឈើមក ហើយផឹកទឹកទន្លេម្តងទៀត ហើយបន្ទាប់មកផ្តេកខ្លួនដើម្បីដេកម្តងទៀត។ ដូច្នេះពួកគេធ្វើដូច្នោះអស់ប៉ុន្មានថ្ងៃប៉ុន្មានយប់។ បន្ទាប់មកពួកគេច្រៀងថា

"ចូរអ្នកមើលទៅថាប្រភពទឹកនេះចែងចាំងយ៉ាងណា ដែលបានកំសាន្តចិត្តដល់អ្នកធ្វើធម្មយាត្រា ដែលនៅក្បែរផ្លូវធំ។ វាស្មៅបៃតង ក្រៅពីនោះមានខ្លឹនក្រអូបទៀត បង្កើតរស់ជាតិឆ្ងាញ់ដល់ពួកគេ ហើយអ្នកដែលអាចប្រាប់

ថាផ្លែនេះល្អប៉ុណ្ណានោះ នឹងទុកដើមនេះឱ្យបង្កើតផលផ្លែឡើង ហើយនឹងបានលក់ទ្រព្យទាំងអស់ ដើម្បីនឹងមកទិញដីនៅទីនេះ។″

ដូច្នេះនៅពេលដែលពួកគេត្រូវទៅបន្តទៀត ដោយសារតែការធ្វើដំណើររបស់ពួកគេមិនទាន់ចង់នៅឡើយ ពួកគេក៏ញ៉ាំ ហើយផឹក រួចក៏ចាកចេញទៅ។

## ផ្លូវក្បែរវាលស្មៅ

ពេលនេះខ្ញុំមើលនៅក្នុងសុបិនរបស់ខ្ញុំថា ពួកគេមិនទាន់បានទៅឆ្ងាយនៅឡើយ តែទន្លេនិងផ្លូវនោះក៏ត្រូវបែកផ្លូវគ្នា។ ដែលធ្វើឱ្យពួកគេសោកស្ដាយមិនតិចឡើយ តែពួកគេមិនបានដើរចេញពីផ្លូវឡើយ។ ពេលនេះផ្លូវចេញពីទន្លេមករាងពិបាក ហើយជើងរបស់គេក៏ទន់អស់ដោយសារការធ្វើដំណើរ។ ដូច្នេះព្រលឹងរបស់អ្នកធ្វើធម្មយាត្រាមានការធ្លាក់ចុះដោយសារតែផ្លូវនោះ។

**"រួចគេធ្វើដំណើរពីភ្នំហោរដើរទៅ តាមផ្លូវសមុទ្រក្រហម ដើម្បីនឹងវាងព័ទ្ធស្រុកអេដុម តែបណ្ដាជនមានចិត្តរវាត ដោយព្រោះផ្លូវនោះ" ជនគណនា 21:4**

យ៉ាងណាពួកគេនៅតែបន្តទៅមុខ ពួកគេប្រាថ្នាចង់បានផ្លូវដែលល្អជាងនេះ។ ឥលូវនេះនៅមុខគេបន្តិច នៅខាងឆ្វេងដៃនៃផ្លូវមានវាលស្មៅមួយ និងជណ្ដើរឆ្លងទៅវាលស្មៅនោះ ហើយវាលស្មៅនោះហៅថា "វាលស្មៅក្បែរផ្លូវ។" បន្ទាប់មកគ្រីស្ទាននិយាយទៅកាន់មិត្តគាត់ថា "ប្រសិនបើវាលស្មៅនេះនៅតាមផ្លូវរបស់យើង យើងនឹងចូលទៅ។" បន្ទាប់មកគាត់ទៅកាន់ជណ្ដើរមើល ហើយឃើញថាផ្លូវនៅក្បែររបងម្ខាងទៀត។ "នេះតាមសេចក្ដីប្រាថ្នារបស់ខ្ញុំហើយ" គ្រីស្ទាននិយាយថា "នេះជាផ្លូវទៅស្រួលបំផុតហើយ ពេញដោយសង្ឃឹមអើយ តោះចូរយើងទៅនោះ។"

សង្ឃឹមៈ តែប្រសិនបើផ្លូវនេះនឹងនាំយើងចេញពីផ្លូវនោះ?

គ្រីស្ទានៈ "ដូចមិនអីចឹងទេ" ម្នាក់ទៀតនិយាយ "មើលទៅ តើវាមិនមែនទៅស្របក្បែរផ្លូវយើងទេឬអី?" ដូច្នេះពេញដោយសង្ឃឹមត្រូវបានមិត្តរបស់គាត់បបួលបាន ក៏ទៅតាមគាត់ទៅម្ខាងទៀតតាមជណ្ដើរ។ នៅពេលដែលពួកគេទៅដល់ម្ខាងទៀត ហើយទៅដល់លើផ្លូវ ពួកគេឃើញថាវាស្រួលសម្រាប់ជើងរបស់ពួកគេ ហើយពួកគេបានសម្លឹងមើលទៅមុខពួកគេ ឃើញមានបុរសម្នាក់កំពុងដើរដូចជាពួកគេដែរ (ហើយឈ្មោះរបស់គាត់គឺ ទំនុកចិត្តដែលអសារឥតការ)។ ដូច្នេះពួកគេក៏ស្រែកហៅគាត់ ហើយសួរគាត់ថាផ្លូវនេះនាំទៅណា? គាត់បាននិយាយថា "ទៅកាន់ឃ្លោងទ្វារស្ថានសួគ៌" "មើលទៅ" គ្រីស្ទាននិយាយថា "តើខ្ញុំមិនបានប្រាប់អ្នកដូច្នេះទេឬ? អ្នកនឹងឃើញថា

យើងត្រូវហើយ” ដូច្នេះពួកគេក៏ដើរតាមទៅ ហើយគាត់បានដើរពីមុខពួកគេ។ តែមើលទៅ ពេលយប់ក៏មកដល់ ហើយងងឹតកាន់តែខ្លាំង។ ដូច្នេះពួកគេនៅពីក្រោយមើលគាត់ដែលដើរខាងមុខលែងឃើញ។

ដូច្នេះអ្នកដែលដើរខាងមុខ (លោកទំនុកចិត្តឥតប្រយោជន៍ តាមឈ្មោះនោះ) មើលមិនឃើញផ្លូវខាងមុខគាត់ ក៏ធ្លាក់ចូលទៅក្នុងរណ្តៅជ្រៅទៅ។

**“ដ្បិតពួកអ្នកដែលដឹកនាំសាសន៍នេះ គេនាំឲ្យវង្វេងទេ ហើយពួកអ្នកដែលគេនាំមុខ នោះក៏ត្រូវបំផ្លាញទៅ” អេសាយ 9:16**

ជារណ្តៅដែលព្រះអម្ចាស់នៃទឹកដីនោះបង្កើតមកក្នុងគោលបំណង ចាប់មនុស្សល្ងីល្ងើដែលមានសិរីល្អខាងឥតប្រយោជន៍ ហើយត្រូវបានកិនទៅជាបំណែកៗដោយការធ្លាក់ចូលទៅ។

ពេលនេះគ្រីស្ទាននិងគ្នារបស់គាត់បានឮគាត់ធ្លាក់ចុះទៅ។ ដូច្នេះពួកគេបានស្រែកសួរពីហេតុការ តែមិនមានអ្នកណាឆ្លើយតបសោះ ពួកគេគ្រាន់តែឮសម្លេងទ្ងូញថ្ងូរប៉ុណ្ណោះ។ បន្ទាប់មកពេញដោយសង្ឃឹមនិយាយថា "តើពេលនេះយើងនៅទីណា?" បន្ទាប់មកគ្នារបស់គាត់ក៏នៅស្ងៀម ហើយគិតថាគាត់បាននាំគេចេញពីផ្លូវហើយ។ ហើយពេលនេះក៏ចាប់ផ្តើមភ្លៀងនិងផ្គរលាន់ដែលបំភ្លឺពេញដោយសភាពគួរភ័យខ្លាច ហើយទឹកឡើងយ៉ាងលឿនភ្លាមៗ។

បន្ទាប់មកពេញដោយសង្ឃឹមថ្ងូរនៅក្នុងខ្លួនថា "ឱប្រសិនបើខ្ញុំនៅតែដើរតាមផ្លូវរបស់ខ្ញុំវិញនោះ!"

គ្រីស្ទានៈ តើអ្នកណាអាចគិតដឹងថាផ្លូវនេះនឹងនាំយើងចេញពីផ្លូវនោះ!

សង្ឃឹមៈ ខ្ញុំបានខ្លាចការនេះតាំងពីដំបូងមកម្ល៉េះ។ ដូច្នេះក៏បានប្រាប់អ្នកដោយបំរាមយ៉ាងស្រទន់ផង។ ខ្ញុំគួរតែបាននិយាយច្បាស់ជាងនេះ តែអ្នកចាស់ជាងខ្ញុំ។

គ្រីស្ទានៈ បងប្អូនល្អអើយ កុំបាក់ទឹកចិត្តអី។ ខ្ញុំសុំទោសដែលខ្ញុំបាននាំអ្នកចេញពីផ្លូវ ហើយដែលខ្ញុំបានធ្វើឱ្យអ្នកចូលនៅក្នុងគ្រោះថ្នាក់ដែលកំពុងមកនេះ។ សូមប្អូនអត់ទោសឱ្យខ្ញុំផងចុះ។ ខ្ញុំមិនបានធ្វើដោយមានបំណងអាក្រក់ឡើយ។

សង្ឃឹមៈ បងអើយ ចូរស្ងប់ចិត្តចុះ ខ្ញុំអត់ទោសឱ្យបងហើយ ហើយចូរជឿថាការនេះនឹងបានជាការល្អដល់យើង។

គ្រីស្ទានៈ ខ្ញុំរីករាយណាស់ដែលមានបងប្អូនពេញដោយមេត្តានៅជាមួយខ្ញុំ។ តែយើងមិនគួរឈរនៅទីនេះទេ ចូរយើងព្យាយាមបកទៅក្រោយវិញ។

សង្ឃឹមៈ តែបងប្អូនល្អអើយ ចូរឱ្យខ្ញុំបានដើរខាងមុខវិញ។

គ្រីស្ទានៈ ទេ សូមអ្នកឱ្យខ្ញុំទៅមុខវិញ ក្រែងមានគ្រោះថ្នាក់ណាមួយនោះ ខ្ញុំនឹងបាននៅទីមួយ ព្រោះដោយសារខ្ញុំយើងទាំងពីរត្រូវចេញពីផ្លូវ។

សង្ឃឹម៖ "ទេ" ពេញដោយសង្ឃឹមនិយាយថា "អ្នកមិនត្រូវទៅខាងមុខឡើយ ដោយសារគំនិតរបស់អ្នកកំពុងមានការលំបាក់ អាននឹងនាំអ្នកចេញពីផ្លូវម្តងទៀត។" បន្ទាប់មក ដោយសារការលើកទឹកចិត្តរបស់ពួកគេ ពួកគេឮសម្លេងមួយនិយាយថា "ចូរដាក់ចិត្តអ្នកទៅរកផ្លូវធំទៅ ទាំងជាផ្លូវដែលអ្នកចាកចេញហើយចូលទៅម្តងទៀតក៏ដោយ។"

**"ចូរធ្វើទីសម្គាល់តាមផ្លូវ ហើយដោតដំរុយចុះ ចូរតាំងចិត្តតម្រង់ទៅឯថ្នល់ គឺជាផ្លូវដែលឯងបានទៅតាមនោះ ឱព្រហ្មចារីនៃសាសន៍អ៊ីស្រាអែលអើយ ចូរវិលមកវិញ ចូរវិលមកឯទីក្រុងរបស់ឯងទាំងនេះចុះ" យេរេមា 31:21**

មកដល់ពេលនេះទឹកបានឡើងយ៉ាងខ្លាំង ហេតុនោះផ្លូវដែលត្រឡប់ទៅវិញក៏គ្រោះថ្នាក់យ៉ាងខ្លាំង។ (បន្ទាប់មកខ្ញុំគិតថាការដើរចេញពីផ្លូវនោះស្រួលជាងនៅពេលដែលយើងនៅក្នុងផ្លូវ ពេលនៅក្រៅផ្លូវពិបាកចូលវិញណាស់)។ តែពួកគេនៅតែផ្សងគ្រោះដើម្បីនឹងត្រលប់ទៅវិញ តែវាងងឹតខ្លាំងពេក ហើយទឹកជំនន់ក៏ឡើងខ្ពស់ខ្លាំង ដែលនៅពេលគេត្រឡប់ទៅវិញ ពួកគេត្រូវតែលង់ទឹកប្រហែលជាប្រាំបួនដប់ដង។

## យក្សនៃការអស់សង្ឃឹម

មិនថាពួកគេប្រើគ្រប់ជំនាញដែលពួកគេមានយ៉ាងណា ពួកគេក៏មិនអាចទៅដល់ជណ្តើរនៅយប់នោះដែរ។ ដូច្នេះចុងក្រោយ សម្រាកនៅក្រោមជំរកមួយពួកគេក៏អង្គុយចុះនៅទីនោះរហូតដល់ថ្ងៃរះឡើយ តែដោយសារហត់នឿយពេក ពួកគេក៏ដេកលក់។ ពេលនេះ នៅមិនឆ្ងាយពីកន្លែងដែលពួកគេដេក

មាន វិមានមួយហៅថា "វិមានសង្ស័យ" ដែលម្ចាស់ទីនោះហៅថា ការអស់សង្ឃឹមយ៉ាងខ្លាំង ហើយពេលនេះពួកគេកំពុងតែដេកនៅលើទឹកដីរបស់គាត់ ដូច្នេះគាត់ក៏ក្រោកពីព្រលឹង ហើយដើរចុះដើរឡើងនៅក្នុងដីរបស់គាត់ ក៏ចាប់បានគ្រីស្ទាននិងគ្នាគាត់ពេញដោយសង្ឃឹមដែលដេកលក់នៅក្នុងទឹកដីគាត់។ បន្ទាប់មក ដោយសម្លេងតឹងរឹងនិងគម្រោះ គាត់ធ្វើឱ្យពួកគេភ្ញាក់ឡើង ហើយបានសួរពួកគេថា មកពីណា និងហេតុអ្វីបានជានៅក្នុងទឹកដីនេះ។ ពួកគេបានប្រាប់គាត់ថា ពួកគេជាអ្នកធ្វើធម្មយាត្រា ហើយបានវង្វេងផ្លូវ។

យក្សនៃការអស់សង្ឃឹម៖ បន្ទាប់មកយក្សក៏និយាយថា "យប់នេះអ្នកបានល្មើសនឹងខ្ញុំហើយ ដោយបានទន្ទ្រាំនិងដេកនៅលើទឹកដីរបស់ខ្ញុំ ហើយដូច្នេះអ្នកត្រូវទៅជាមួយខ្ញុំ។" ដូច្នេះពួកគេត្រូវបង្ខំឱ្យទៅ ដោយសារគាត់ខ្លាំងជាងពួកគេ។ ពួកគេក៏មិនមានអ្វីច្រើននឹងនិយាយដែរ ដោយសារពួកគេដឹងខ្លួនថាធ្វើខុស។ ដូច្នេះយក្សក៏ដេញពួកគេឱ្យដើរទៅមុខគាត់ ហើយដាក់ពួកគេចូលទៅក្នុងវិមាន ទៅក្នុងគុកយ៉ាងងងឹតមួយ ដែលអាក្រក់ និងស្អុយរហូតដល់វិញ្ញាណរបស់មនុស្សទាំងពីរនេះ។

**"ទ្រង់បានធ្វើឲ្យទាំងអ្នកដែលស្រឡាញ់ទូលបង្គំ និងពួកគឿនឃ្លាតឆ្ងាយពីទូលបង្គំទៅ ពួកមិត្តភក្តិរបស់ទូលបង្គំក៏បាត់ទៅ ក្នុងសេចក្តីងងឹតហើយ។"**

**ទំនុកដំកើង 88:18**

នៅទីនេះ ពួកគេក៏ផ្តេកខ្លួន ពីពេលព្រឹកថ្ងៃពុធរហូតដល់យប់ថ្ងៃសៅរ៍ មិនបានញាំនំប៉័ងសូម្បីតែបន្តិច ឬទឹកមួយដំណក់ឡើយ មិនមានពន្លឺ ឬមានអ្នកណាមកសួរសុខទុក្ខពួកគេដែរ។ ដូច្នេះពួកគេនៅក្នុសភាពមួយដ៏អាក្រក់

ហើយនៅឆ្ងាយពីមិត្តភក្តិ និងអ្នកស្គាល់។ ពេលនេះនៅទីនេះ ត្រីស្វានមាន
សេចក្តីសោកសង្រេងទ្វេរដង ពីព្រោះដោយសារតែយោបល់មិនត្រឹមត្រូវ
របស់គាត់ ដែលពួកគេត្រូវនាំមកចូលនៅក្នុងការលំបាកនេះ។

ពេលនេះយក្សនៃការអស់សង្ឃឹមមានប្រពន្ធម្នាក់ ឈ្មោះថាភាពខុសគ្នា។ ដូច្នេះនៅពេលគាត់បានចូលដេកទៅ គាត់បានប្រាប់ប្រពន្ធគាត់ពីអ្វីដែលគាត់បានធ្វើ គឺគាត់បានយកអ្នកទោសពីរបីនាក់មក ហើយបានដាក់ពួកគេទៅក្នុងគុក ដោយសារបានល្មើសចូលមកក្នុងដីគាត់។ ហើយគាត់ក៏បានសួរនាងផងដែរថា តើគាត់គួរធ្វើដល់ពួកគេយ៉ាងណាថែមទៀតទើបល្អ។ ដូច្នេះនាងក៏បានសួរគាត់ថា ពួកគេជាអ្វី តើពួកគេមកពីណា ហើយតើពួកគេទៅណា។ ហើយគាត់ក៏ប្រាប់នាងទៅ។ នាងក៏ផ្តល់ការព្រឹក្សាដល់គាត់ថា ពេលដែលគាត់ក្រោកនៅព្រឹកឡើយ ត្រូវវាយពួកគេដោយគ្មានមេត្តា។ ដូច្នេះពេលគាត់ក្រោកឡើង គាត់យកដំបងដ៏គ្រោះថ្នាក់មួយ ដើរចុះទៅរកគុកទៅកាន់ពួកគេ ហើយដំបូងក៏ដាក់ពិន្ទុដល់ពួកគេប្រៀបដូចជាពួកគេជាសត្វឆ្កែអីចឹង បើទោះជាពួកគេមិនបាននិយាយពាក្យមិនសមរម្យដល់គាត់ក៏ដោយ។ បន្ទាប់មកគាត់ក៏វាយទៅលើពួកគេ វាយដំដោយមិនខ្លាចរអារ ដោយសារការនោះ ពួកគេមិនអាចនឹងជួយខ្លួនបាន ក៏មិនអាចត្រឡប់ទៅដីវិញបាន។ រួចមក គាត់ក៏ចេញទៅហើយទុកពួកគេចោល ដើម្បីឱ្យពួកគេស្រោកស្រានពីសេចក្តីវេទនារបស់ពួកគេ ហើយឱ្យទួញសោកដោយការលំបាករបស់ពួកគេ។ ដូច្នេះថ្ងៃនោះពួកគេមិនបានធ្វើអ្វីឡើយក្រៅពីដកដង្ហើមធំនិងទួញយំយ៉ាងខ្លាំង។ យប់បន្ទាប់ នាងនិយាយជាមួយនឹងប្តីរបស់នាងអំពីពួកគេទៀត ហើយដឹងថាពួកគេនៅរស់នៅឡើយ ក៏បានផ្តល់យោបល់ដល់គាត់ឱ្យ

ណែនាំពួកគេឱ្យរកផ្លូវដោយខ្លួនឯង។ ដូច្នេះពេលព្រឹកមកដល់ គាត់ទៅកាន់ពួកគេដោយឫកពារអាក្រក់ដូចមុខដែរ ហើយឃើញថាពួកគេមានការឈឺចាប់ដោយសារស្នាមរំពាត់ដែលគាត់បានវាយថ្ងៃមុននោះ គាត់ប្រាប់ពួកគេថា ក្នុងកាលដែលពួកគេនឹងមិនអាចចេញរួចពីទីនោះទេ ផ្លូវតែមួយរបស់ពួកគេនោះគឺ ត្រូវសម្លាប់ខ្លួន មិនថាដោយកាំបិត ខ្សែបង្វៀ ឬថ្នាំពុលឡើយ។ "សម្រាប់អ្វីទៅ" គាត់និយាយថា "តើអ្នកជ្រើសយកជីវិត ទាំងដែលឃើញហើយថាវាមានតែភាពល្វីងជូរចត់នោះ?" តែពួកគេចង់ឲ្យគាត់ដោះលែងឱ្យពួកគេទៅ ដូច្នោះគាត់មើលទៅយ៉ាងអាក្រក់ដល់ពួកគេ ហើយស្ទុះទៅរកពួកគេ ដោយមិនសង្ស័យធ្វើឱ្យពួកគេស្លាប់ដោយផ្ទាល់ តែគាត់បានធ្លាក់ចូលទៅក្នុងរណ្ដៅរបស់គាត់មួយ ដោយសារជួនកាលនៅក្នុងអាកាសធាតុមានថ្ងៃរះធ្លាក់ចូលទៅក្នុងរណ្ដៅ ហើយរង្វេង (អស់មួយរយៈ) ការប្រើប្រាស់ដៃរបស់គាត់ ដូច្នេះដើរចេញទៅ ហើយចាកចេញពីពួកគេ (ដូចមុន) ដើម្បីនឹងពិចារណាត្រូវធ្វើអ្វី។ បន្ទាប់មកអ្នកទោសពិក្សាគ្នាគេ ថាតើវាល្អទេដែលធ្វើតាមគាត់ឬក៏អត់។ ហើយពួកគេក៏ចាប់ផ្ដើមពិភាក្សាដូច្នេះថា

គ្រីស្ទានៈ "បងប្អូនអើយ" គ្រីស្ទាននិយាយ "តើយើងគួរធ្វើអ្វី? ជីវិតដែលយើងកំពុងរស់នៅនេះវេទនាណាស់ ចំពោះខ្ញុំវិញ ខ្ញុំមិនដឹងថាត្រូវធ្វើអ្វីទេទើបល្អ មិនដឹងថារស់នៅដូច្នេះ ឬស្ដេចចេញពីដៃនោះទេ។ ព្រលឹងខ្ញុំជ្រើសយកការដាច់ខ្យល់ស្លាប់ជាជាងការរស់នៅ។"

**"បានជាចិត្តនៃទូលបង្គំស៊ូស្លាប់ដោយច្របាច់ក ហើយក៏រើសយកសេចក្ដីស្លាប់ជាជាងឆ្អឹងទាំងនេះ" យ៉ូប 7:15**

ហើយផ្ទះស្រួលជាងគុកនេះសម្រាប់ខ្ញុំ តើយើងនឹងត្រូវគ្រប់គ្រងដោយយក្សនេះឬ?

សង្ឃឹម៖ ពិតណាស់សភាពយើងពេលនេះគួរឱ្យភ័យខ្លាចណាស់ ហើយសេចក្តីស្លាប់គួរឱ្យស្វាគមន៍សម្រាប់ខ្ញុំជាងការនៅទីនេះ។ តែចូរយើងពិចារណាថា ព្រះអម្ចាស់នៃប្រទេសដែលយើងទៅមានបន្ទូលថា "អ្នកមិនត្រូវសម្លាប់ឡើយ" ទេ មិនត្រូវធ្វើទៅកាន់អ្នកផ្សេងទៀតឡើយ។ លើសពីនោះទៀត យើងត្រូវបានហាមមិនឱ្យយកយោបល់របស់មនុស្សនេះហើយសម្លាប់ខ្លួនយើងឡើយ។ ក្រៅពីនោះ អ្នកដែលសម្លាប់អ្នកផ្សេងទៀតអាចធ្វើបាន តែបាននាំទោសសម្លាប់គេមកលើរូបខ្លួនឯង តែអ្នកដែលសម្លាប់ខ្លួន គឺសម្លាប់រូបកាយនិងព្រលឹងក្នុងពេលតែមួយ។ ហើយលើសពីនោះទៀត បងអើយ អ្នកនិយាយពីភាពសុខស្រួលនៅក្នុងផ្នូរ តែតើអ្នកភ្លេចពីស្ថាននរកហើយមែនទេ ដែលជាកន្លែងដែលអ្នកសម្លាប់មនុស្សមួយចំនួនទៅនោះ? "ដោយគ្មានអ្នកសម្លាប់គេណាដែលមានជីវិតអស់កល្បជានិច្ចឡើយ។" ហើយចូរយើងពិចារណាម្តងទៀត ថាគ្រប់ទាំងក្រិត្យវិន័យទាំងអស់មិននៅក្នុងដៃរបស់យក្សនៃសេចក្តីអស់សង្ឃឹមនោះឡើយ តាមដែលខ្ញុំយល់អ្នកផ្សេងទៀតក៏ត្រូវបានគាត់យកមកដូចយើងដែរ តែបានគេចរួចពីកណ្តាប់ដៃរបស់វា អ្នកអាចដឹងបាន តែព្រះដែលធ្វើឱ្យលោកិយនេះធ្វើឱ្យយក្សនៃសេចក្តីអស់សង្ឃឹមនេះស្លាប់ ដែលនៅពេលមួយគាត់ភ្លេចនឹងចាក់សោរយើងទុកនោះ? ឬ តែគាត់អាចនឹងក្នុងពេលខ្លីមានរណ្តៅមួយនៅខាងមុខយើង ហើយនឹងមិនអាចប្រើដៃជាងរបស់គាត់មិនបាននោះ? ហើយប្រសិនបើវាកើតឡើងម្តងទៀត សម្រាប់ខ្ញុំវិញខ្ញុំសម្រេចថានឹងយកបេះដូងរបស់មនុស្សចេញ

ហើយព្យាយាមអស់ពីកម្លាំងរបស់ខ្ញុំចេញពីកណ្ដាប់ដៃរបស់គាត់។ ខ្ញុំល្ងង់ណាស់ដែលមិនបានសាកធ្វើពីមុនមកនេះ។ តែយ៉ាងណាក៏ដោយបងអើយ ចូរយើងអត់ធ្មត់ ហើយស៊ូទ្រាំមួយរយៈសិន ពេលនឹងមកដល់ដែលនឹងនាំយើងឱ្យបានរួចខ្លួន តែកុំឱ្យតែយើងសម្លាប់ខ្លួនឯងបានហើយ។

ដោយពាក្យទាំងនេះពេញដោយសង្ឃឹមពេលនេះបានធ្វើឱ្យគំនិតរបស់បងប្អូនគាត់បានត្រឹមត្រូវវិញ ដូច្នេះពួកគេនៅបន្តជាមួយគ្នា (នៅក្នុងទីងងឹត) នៅថ្ងៃនោះ នៅក្នុងសភាពក្រៀមក្រំនិងមិនសប្បាយចិត្តសោះ។

ដល់ពេលល្ងាច យក្សចុះទៅគុកម្ដងទៀត ដើម្បីមើលថាអ្នកទោសរបស់គេបានស្ដាប់តាមយោបល់របស់គេដែរទេ។ តែនៅពេលដែលគាត់មកទីនោះ គាត់ឃើញពួកគេនៅរស់ ហើយពិតណាស់នៅមានជីវិតទាំងអស់ ដោយចង់បាននំប៉័ងនិងទឹក ហើយដោយសារតែរបួសពួកគេបានទទួលពេលដែលគាត់វាយពួកគេ នោះពួកគេមិនអាចធ្វើអ្វីច្រើនទេក្រៅពីដកដង្ហើម។ ប៉ុន្តែខ្ញុំនិយាយថា គាត់បានរកឃើញថាពួកគេមានជីវិតរស់នៅ ដូចនោះគាត់ក៏បានខឹងយ៉ាងខ្លាំង ហើយប្រាប់ពួកគេថា ដោយឃើញពួកគេមិនស្ដាប់តាមគាត់ វាអាក្រក់ជាងដែលពួកគេមិនបានកើតមកនោះ។

ដោយការនេះពួកគេភ័យញាប់ញ័រយ៉ាងខ្លាំង ហើយខ្ញុំគិតថាគ្រីស្ទានបានសន្លប់ទៅ តែពេលគាត់ដឹងខ្លួនបន្តិចមកម្ដងទៀត ពួកគេក៏បានជជែកគ្នាពីយោបល់របស់យក្សម្ដងទៀត ហើយគិតថានឹងធ្វើតាមឬអត់ជាការល្អ។ ពេលនេះគ្រីស្ទានហាក់ដូចជាចង់ធ្វើតាមម្ដងទៀត តែពេញដោយសង្ឃឹមបានផ្ដល់ចម្លើយជាលើកទីពីរ។

សង្ឃឹម៖"បងខ្ញុំអើយ" គាត់និយាយថា "ចូរចង់ចាំថាអ្នកធ្លាប់ក្លាហានប៉ុណ្ណា ដែលបានមកដល់ទីនេះ? អាប៉ូឡេអុងមិនអាចនឹងបំបែកបងបានផង ហើយក៏មិនមានអ្នកណាដែលអ្នកបានឮ បានជួប និងមានអារម្មណ៍ដែលនៅក្នុងជ្រលងនៃម្លប់សេចក្ដីស្លាប់ធ្វើបានផង។ តើមានការលំបាកអ្វី សេចក្ដីភ័យក្លាចអ្វី ការភ្ញាក់ផ្អើលអ្វី ដែលអ្នកបានឆ្លងកាត់ ហើយមិនមានអ្វីសោះក្រៅពីភាពភ័យខ្លាចនោះ? អ្នកឃើញហើយថាខ្ញុំនៅក្នុងគុកជាមួយអ្នកដែរ ដែលខ្ញុំជាមនុស្សកំសោយជាងអ្នកពីធម្មជាតិទៅហើយ! ហើយយក្សនេះបានធ្វើឱ្យខ្ញុំមានរបួសដូចអ្នកដែរ ហើយក៏ដកយកនំប៉័ងនិងទឹកចេញពីមាត់ខ្ញុំ ហើយខ្ញុំទួញយំជាមួយអ្នកដោយគ្មានពន្លឺ តែចូរយើងធ្វើខំប្រឹងអត់ធ្មត់បន្តិចថែមទៀត។ ចូរចង់ចាំថាអ្នកធ្លាប់ជាមនុស្សក្លាហានយ៉ាងណានៅក្នុងជំនួញដែលឥតប្រយោជន៍នោះ ហើយមិនទាំងក្លាចដល់ច្រវ៉ាក់ ឬទ្រុងផង ទាំងមិនខ្លាចស្លាប់ដោយត្រូវបង្ហូរឈាមផង។ យ៉ាងហោចណាស់គេចផុតពីសេចក្ដីអាម៉ាស់ដែលត្រូវរកឃើញថាមិនមែនជាគ្រីស្ទានវិញ ដូច្នេះចូរយើងខិតខំស៊ូដោយអត់ធ្មត់តាមដែលយើងអាចធ្វើបាន។

ពេលនេះយប់ក៏មកដល់ម្ដងទៀត ហើយយក្សនិងប្រពន្ធកំពុងដេកលើគ្រែ នាងក៏សួរគាត់ពីអ្នកទោស។ ថាតើពួកគេបានទទួលយកដំបូន្មានរបស់គាត់ឬទេ? ដែលគាត់បានឆ្លើយតបថា "ពួកគេជាមនុស្សដែលពូកែបញ្ឆោតពួកគេជ្រើសរើសយកការលំបាកទាំងអស់ ជាជាងលះបង់ជីវិតខ្លួនឯង"។ បន្ទាប់មកនាងបាននិយាយថា" ចូរយកពួកវាចូលក្នុងសួននៃវិមាននៅថ្ងៃស្អែក ហើយបង្ហាញឆ្អឹងនិងលលាដ៍ក្បាលរបស់អ្នកដែលអ្នកបានបញ្ជូនទៅនោះរួចហើយហើយធ្វើឱ្យពួកគេជឿថា មួយសប្ដាហ៍ពួកគេនឹងមកដល់ទីបញ្ចប់ អ្នកក៏នឹងត្រូវហែកពួកវាជាបំណែកៗដែរ ដូចដែលអ្នកបានធ្វើចំពោះពួកវា

ដែលមកមុនៗនោះ។”
ដូច្នេះពេលព្រឹកឡើងយក្សបានទៅរកពួកគេម្តងទៀត ហើយយកពួកគេទៅក្នុងទីធ្លាប្រាសាទ ហើយបង្ហាញពួកគេដូចជាប្រពន្ធរបស់គាត់បានប្រាប់គាត់។ គាត់បាននិយាយថា "ទាំងនេះជាអ្នកធ្វើធម្មយាត្រាដូចអ្នកដែរ មានម្តងនោះពួកគេបានរំលោភលើទឹកដីរបស់ខ្ញុំដូចអ្នកបានធ្វើ ហើយនៅពេលខ្ញុំគិតថាវាត្រឹមត្រូវនោះ ខ្ញុំក៏បានហែកពួកគេជាបំណែក ហើយដូច្នេះក្នុងរយៈពេលដប់ថ្ងៃខ្ញុំនឹងធ្វើដល់អ្នក ទៅចុះ ហើយចូលទៅក្នុងរូងរបស់អ្នកម្តងទៀត!
ហើយជាមួយនោះគាត់បានវាយពួកគេរហូតទៅដល់ទីនោះ។ ដូច្នេះពួកគេដេក ពេញមួយថ្ងៃនៅថ្ងៃសៅរ៍ក្នុងសភាពទួញសោកដូចកាលពីមុន។ ឥឡូវនេះ ពេលរាត្រីបានមកដល់ ហើយនៅពេលដែលលោកស្រីរូញរា និងប្តីរបស់នាងលោកយក្សបានចូលគេង ពួកគេបានចាប់ផ្តើមជជែកគ្នាពីអ្នកទោសរបស់ពួកគេ។ ហើយយក្សចាស់បានងឿងឆ្ងល់ថាការវាយដំនិងការទូន្មានរបស់គាត់មិនបានធ្វើឱ្យពួកគេស្លាបបានទេ។ ហើយភរិយារបស់គាត់បានឆ្លើយតបថា"ខ្ញុំខ្លាច” ថាពួកគេរស់នៅដោយសង្ឃឹមថានឹងមានអ្នកខ្លះនឹងជួយរំដោះពួកគេ ឬថាពួកគេមានកូនសោរដែលជាមធ្យោបាយដែលពួកគេសង្ឃឹមថានឹងរត់គេចរួចទេដឹង”។ "ហើយអ្នកនិយាយអញ្ចឹង ប្រពន្ធជាទីស្រឡាញ់?" យក្សបាននិយាយ។ ដូច្នេះខ្ញុំនឹងតាមរកពួកគេនៅពេលព្រឹក។

នៅថ្ងៃសៅរ៍ ប្រហែលពាក់កណ្តាលយប់អ្នកធ្វើធម្មយាត្រាចាប់ផ្តើមអធិស្ឋាន ហើយបន្តអធិស្ឋានរហូតជិតភ្លឺ។

ឥឡូវនេះមុនពេលថ្ងៃមកដល់ គ្រីស្ទានល្អ ប្រៀបដូចជាម្នាក់វាងភ្ញាក់ផ្អើលពាក់កណ្តាល បាននិយាយនៅក្នុងឃ្លាដ៏រំភើបនេះថា "មនុស្សល្ងីល្ងើអើយ"

គាត់បាននិយាយថា "ខ្ញុំត្រូវនៅក្នុងគុកងងឹតស្អុយដូច្នេះ ក្នុងកាលដែលខ្ញុំអាចដើរដោយសេរីភាពបាននោះ! ខ្ញុំមានកូនសោមួយនៅក្នុងទ្រូងរបស់ខ្ញុំដែលត្រូវបានគេហៅថាការសន្យា ដែលខ្ញុំយល់ថាវានឹងបើកសោនៅក្នុងវិមានសង្ស័យនេះ។ បន្ទាប់មកពេញដោយសង្ឃឹមនិយាយថា " នោះជាដំណឹងល្អបងប្រុសល្អអើយ ដកវាចេញពីទ្រូងរបស់អ្នក ហើយព្យាយាមបើកមើល"។

បន្ទាប់មកគ្រីស្ទានបានទាញវាចេញពីទ្រូងរបស់គាត់ ហើយចាប់ផ្តើមសាកនៅមាត់ទ្វារ (ពេលដែលគាត់បង្វិលកូនសោរ) ទាញមកវិញ រួចហើយទ្វារបានបើកយ៉ាងស្រួល។ ហើយគ្រីស្ទាននិងពេញដោយសង្ឃឹមទាំងពីរនាក់ក៏បានចេញមកក្រៅ។ បន្ទាប់មកគាត់បានទៅទ្វារខាងក្រៅដែលនាំទៅដល់ទីធ្លាប្រាសាទ។ ហើយជាមួយនឹងកូនសោរបស់គាត់បានបើកទ្វារនោះផងដែរ។ បន្ទាប់ពីនោះ គាត់បានទៅទ្វារដែក ព្រោះទ្វារនោះនឹងត្រូវបានបើកដែរ។ ប៉ុន្តែសោនោះពិបាកខ្លាំងណាស់ ប៉ុន្តែសោរនោះនៅតែបើកវាបាន។ បន្ទាប់មកពួកគេបានបើកទ្វារដើម្បីធ្វើឱ្យការរត់គេចខ្លួនរបស់ពួកគេយ៉ាងលឿន ប៉ុន្តែក្លោងទ្វារនោះនៅពេលដែលវាបានបើក ធ្វើឱ្យមានសម្លេងឡើងយ៉ាងខ្លាំង ដូច្នេះវាបានធ្វើឱ្យភ្ញាក់ផ្អើលដល់យក្សនៃការអស់សង្ឃឹម ដែលគេប្រញាប់ប្រញាល់ដេញតាមអ្នកទោសរបស់គេ គេមានអារម្មណ៍ថាអវយវៈរបស់គេត្រូវបរាជ័យ ពីព្រោះរណ្តៅរបស់គាត់បាននាំគាត់ម្តងទៀត ដូច្នេះគាត់មិនអាចដេញតាមពួកគេបានឡើយ។ ពួកគេបន្តដំណើរទៅ រហូតមកដល់ផ្លូវធំរបស់ស្តេចម្តងទៀត។ ហើយពួកគេក៏មានសុវត្ថិភាពដែរ ពីព្រោះ

ពួកគេនៅក្រៅអំណាចរបស់គេ។

ឥឡូវនេះនៅពេលដែលពួកគេបានឆ្លងកាត់តាមស្ពានមក ពួកគេបានចាប់ផ្តើមឈ្លោះជាមួយខ្លួនពួកគេនូវអ្វីដែលពួកគេគួរធ្វើនៅត្រង់ជណ្តើរនោះ ដើម្បីការពារអ្នកដែលមកក្រោយដើម្បីកុំឱ្យធ្លាក់ចូលក្នុងកណ្តាប់ដៃរបស់យក្សនៃសេចក្តីអស់សង្ឃឹមទៀត។ ដូច្នេះពួកគេបានយល់ព្រមតំឡើងសសរមួយនៅទីនោះ ហើយឆ្លាក់នៅខាងលើនូវប្រយោគនេះថា "លើសពីជណ្តើរនេះទៅគឺជាផ្លូវទៅកាន់វិមានសង្ស័យដែលត្រូវបានរក្សាទុកដោយយក្សនៃសេចក្តីអស់សង្ឃឹម ដែលមើលងាយព្រះមហាក្សត្រនៃប្រទេសស្ថានសួគ៌ ហើយព្យាយាមបំផ្លាញអ្នកធ្វើធម្មយាត្រាដ៏បរិសុទ្ធរបស់ទ្រង់ផង។" ដូច្នេះមនុស្សជាច្រើនដែលដើរតាមក្រោយ បានអានអ្វីដែលបានសរសេរហើយរួចផុតពីគ្រោះថ្នាក់។ រួចមក ពួកគេបានច្រៀងដូចតទៅ៖

"យើងបានចេញពីផ្លូវ ហើយនៅពេលដែលយើងរកឃើញថា ជាជំហាននៅលើទឹកដីដែលហាមឃាត់។ ហើយឱ្យអ្នកដែលមកក្រោយយកចិត្តទុកដាក់<br>មិនដូច្នោះនឹងធ្វើឱ្យពួកគេបានដូចជាយើងដែរ។ មិនដូច្នេះពួកគេនឹងក្លាយជាអ្នកទោសរបស់វា ដោយការរំលោភបំពាន អាមួយដែលមានវិមានហៅថា<br>សង្ស័យ ហើយឈ្មោះវាហៅវា អស់សង្ឃឹម។"

## ភ្នំដែលគួរគាប់ចិត្ត

ពួកគេទៅរហូតដល់ "ភ្នំដែលគួរគាប់ចិត្ត" ដែលជាកម្មសិទ្ធិរបស់ព្រះអម្ចាស់នៃភ្នំនោះ ដែលយើងដែលបាននិយាយពីទ្រង់ពីមុនមក។ ដូច្នេះពួកគេឡើងទៅលើភ្នំ ដើម្បីសម្លឹងមើលសួនច្បារនិងដើមឈើ ចម្ការទំពាំងបាយជូរ និងប្រភពទឹកហូរ ជាកន្លែងដែលគេបានផឹក និងសម្អាតខ្លួនពួកគេ ហើយបរិភោគពីចម្ការទំពាំងបាយជូរដោយសេរី។ នៅពេលដែលពួកគេនៅលើកំពូលភ្នំទាំងនេះ អ្នកគង្វាលកំពុងឱ្យចំណីដល់ហ្វូងសត្វ ហើយពួកគេឈរនៅក្បែរផ្លូវធំ។ ដូច្នេះអ្នកធ្វើធម្មយាត្រាបានទៅកាន់ឯពួកគេ ហើយបានរៀន

ពីដំបងរបស់ពួកគេ (ដែលជាធម្មតាដល់អ្នកធ្វើធម្មយាត្រាដែលហាត់នឿយ នៅពេលដែលពួកគេនិយាយជាមួយអ្នកណាម្នាក់តាមផ្លូវ) ពួកគេសួរថា "តើភ្នំដែលគួរគាត់ចិត្តទាំងនេះជារបស់អ្នកណា? ហើយតើសត្វចៀមទាំងនេះជារបស់អ្នកណាដែលស៊ីចំណីនោះ?

អ្នកគង្វាល៖ ភ្នំទាំងនេះជាទឹកដីរបស់ព្រះអេម៉ាញ៉ូអែល ហើយភ្នំទាំងនេះនៅមើលឃើញទីក្រុងរបស់ទ្រង់ផង ហើយចៀមទាំងនេះជារបស់ទ្រង់ ហើយទ្រង់បានលះបង់ព្រះជន្មទ្រង់សម្រាប់ពួកគេផង។

**"ខ្ញុំជាអ្នកគង្វាលល្អ ឯគង្វាលល្អ ក៏ស៊ូតែប្តូរជីវិតជំនួសចៀម។" យ៉ូហាន 10:11**

គ្រីស្ទាន៖ តើនេះជាផ្លូវទៅកាន់ទីក្រុងស្ថានសួគ៌មែនទេ?

អ្នកគង្វាល៖ អ្នកកំពុងនៅលើផ្លូវហ្នឹងតែម្តង។

គ្រីស្ទាន៖ តើវាឆ្ងាយប៉ុន្មានដែរទៅដល់ទីនោះ?

គង្វាល៖ វាពិតជាឆ្ងាយខ្លាំងណាស់សម្រាប់អ្នកនឹងទៅទីនោះ។

គ្រីស្ទាន៖ តើផ្លូវមានសុវត្ថិភាព ឬគ្រោះថ្នាក់ទៅ?

គង្វាល៖ សុវត្ថិភាពសម្រាប់អ្នកដែលនឹងមានសុវត្ថិភាព តែសម្រាប់អ្នកបះបោរវិញនឹងត្រូវដួលនៅទីនោះហើយ។

**"តើមានអ្នកណាដែលមានប្រាជ្ញា ឱ្យយល់សេចក្តីទាំងនេះបាន ឬមានគំនិតវាងវៃឱ្យបានស្គាល់សេចក្តីទាំងនេះផង ដ្បិតអស់ទាំងផ្លូវរបស់ព្រះយេហូវ៉ាសុទ្ធតែទៀងត្រង់ ពួកអ្នកសុចរិតនឹងដើរក្នុងផ្លូវនោះ តែមនុស្សទុច្ចរិតនឹងជំពប់ដួលក្នុងផ្លូវនោះវិញ។" ហូសេ 14:9**

គ្រីស្ទាន៖ តើនៅកន្លែងនេះមានការបន្ធូរស្បៀយដល់អ្នកធ្វើធម្មយាត្រាដែលនឿយហត់និងដួលតាមផ្លូវទេ?

គង្វាល៖ ព្រះអម្ចាស់នៃភ្នំនេះបានឱ្យយើងធ្វើការចាត់ចែង មិនឱ្យពួកគេភ្លេចនិងកំសាន្តចិត្តដល់អ្នកប្លែកមុខទេ។

**"ចូរមានសេចក្តីស្រឡាញ់គ្នា ជាបងប្អូនជានិច្ច។ កុំភ្លេចសេចក្តីថៅរ៉ៅឡើយ ដ្បិតមនុស្សខ្លះបានទទួលទាំងទេវតា ឱ្យសំណាក់នៅឥតដឹងផង ដោយមានសេចក្តីនោះឯង។" ហេព្រើរ 13:1, 2**

ដូច្នេះសេចក្តីល្អនៃកន្លែងនេះគឺនៅខាងអ្នកហ្នឹងហើយ។

ខ្ញុំបានឃើញនៅក្នុងសុបិនរបស់ខ្ញុំផងដែរថា នៅពេលដែលអ្នកគង្វាលយល់ឃើញថាពួកគេជាអ្នកធ្វើដំណើរ ពួកគេក៏បានសួរសំណួរដល់ពួកគេ (ដែលពួកគេបានឆ្លើយសំណួរដូចនៅកន្លែងផ្សេងទៀតដែរ) ដូចជា "តើអ្នកមកពីណា?" ហើយ "បានមកតាមផ្លូវនេះដោយរបៀបណា?" ហើយ "ដោយវិធីអ្វី

ដែលអ្នកស៊ូទ្រាំមកដល់ទីនេះ?" ដោយសារមនុស្សមិនច្រើនទេដែលបានមកដល់ទីនេះបង្ហាញមុខរបស់ពួកគេនៅលើភ្នំទាំងនេះ" តែនៅពេលដែលអ្នកគង្វាលឮចម្លើយរបស់ពួកគេ ក៏ពេញចិត្ត ក៏មើលទៅកាន់ពួកគេដោយក្តីស្រឡាញ់ ហើយនិយាយថា "សូមស្វាគមន៍មកកាន់ភ្នំដែលគួរគាប់ចិត្ត!"

អ្នកគង្វាលដែលខ្ញុំនិយាយនោះមានឈ្មោះថា ចំណេះដឹង បទពិសោធន៍ ប្រុងប្រយ័ត្ន និងស្មោះត្រង់ បានដឹកដៃនាំពួកគេ ទៅនៅក្នុងតង់សំណាក់របស់ពួកគេ ហើយឱ្យពួកគេបានចូលរួមជាមួយនឹងអ្វីដែលរួចរាល់នាពេលបច្ចុប្បន្ននេះ។ ពួកគេនិយាយថែមទៀតថា "យើងចង់ឱ្យពួកអ្នកនៅស្នាក់ទីនេះមួយរយៈ ដើម្បីឱ្យបានស្គាល់ពួកយើង ហើយក្រៅពីនោះទៀតដើម្បីនឹងកំសាន្តចិត្តដល់ខ្លួនអ្នកជាមួយរបស់ល្អៗនៃភ្នំគួរគាប់ចិត្តនេះ។" បន្ទាប់មកពួកគេប្រាប់ថា ពួកគេស្កប់ចិត្តនឹងស្នាក់នៅ ហើយពួកគេក៏ទៅកន្លែងសម្រាករបស់ពួកគេនៅពេលយប់ទៅ ដោយសារវាយប់ជ្រៅដែរហើយ។

បន្ទាប់មកខ្ញុំឃើញនៅក្នុងសុបិនរបស់ខ្ញុំថា ពេលព្រឹកឡើងអ្នកគង្វាលបានហៅទៅកាន់គ្រីស្ទាននិងពេញដោយសង្ឃឹម ឱ្យមកដើរជាមួយពួកគេនៅលើភ្នំ។ ដូច្នេះពួកគេក៏ទៅជាមួយពួកគាត់ ហើយដើរមួយសន្ទុះ ដោយបានឃើញរូបភាពស្រស់ស្អាតពីគ្រប់ជ្រុង។ បន្ទាប់មកអ្នកគង្វាលនិយាយទៅកាន់គ្នាទៅវិញទៅមកថា "តើយើងគួរតែបង្ហាញការអស្ចារ្យដល់អ្នកធ្វើធម្មយាត្រាទាំងនេះទេ?" ដូច្នេះនៅពេលដែលគេសម្រេចថានឹងធ្វើ ក៏យកពួកគេទៅលើកំពូលភ្នំជាមុនសិនហៅថា "កំហុស" ដែលមានភាពទេរខ្លាំងនៅម្ខាងទៀតដែលឆ្ងាយ ហើយប្រាប់ពួកគេឱ្យមើលទៅខាងក្រោមទៅកាន់បាតវា។ ដូច្នេះគ្រីស្ទាននិងពេញដោយសង្ឃឹមបានមើលទៅក្រោម ហើយបានឃើញ

នៅបាតនោះមានបុរសពីរបីនាក់ត្រូវបានកិនទៅជាបំណែកៗដោយសារត្រូវបានធ្លាក់ពីលើកំពូលភ្នំមក។ បន្ទាប់មកគ្រីស្ទាននិយាយថា "តើវាមានន័យយ៉ាងម៉េច?" អ្នកគង្វាលឆ្លើយថា "តើអ្នកមិនដែលឮពីពួកគេ ដែលត្រូវបានឱ្យធ្វើខុស ដោយបានស្តាប់តាមហ៊ីមីនុស និងហ្វីលេថឺស ពីសេចក្តីជំនឿនៃការរស់ពីស្លាប់ឡើងវិញនៃរូបកាយនោះ?"

**"ហើយសម្ដីគេនឹងស៊ីរូងដូចជាដំបៅក្លាយ ក្នុងពួកនោះមានឈ្មោះហ៊ីមេនាស និងភីលេត។ ដែលបានជ្រុលហួសចេញពីសេចក្ដីពិត ទាំងនិយាយថា សេចក្ដីរស់ឡើងវិញ បានកន្លងទៅហើយ គេក៏បង្ខូចសេចក្ដីជំនឿរបស់អ្នកខ្លះដែរ។"**
**ធីម៉ូថេទី២ 2:17, 18**

ពួកគេបានឆ្លើយថា "បាទបាន។" បន្ទាប់មកអ្នកគង្វាលនិយាយថា "ពួកគេជាអ្នកដែលអ្នកបានឃើញត្រូវវាយបែកជាបំណែកៗនៅបាតភ្នំនេះហើយ ហើយពួកគេនៅរហូតដល់សព្វថ្ងៃនេះដោយមិនបានកប់ (ដូចដែលអ្នកឃើញហ្នឹង) ទុកជាគម្រូដល់អ្នកផ្សេងទៀតឱ្យគេឮថាពួកគេបានឡើងខ្ពស់ពេក ឬការដែលគេមកជិតមាត់ភ្នំនេះខ្លាំងពេក។"

បន្ទាប់មកខ្ញុំបានឃើញថាពួកគេត្រូវបាននាំទៅលើកំពូលភ្នំផ្សេងទៀត ហើយភ្នំនោះមានឈ្មោះថា "ការដាស់តឿន" ហើយប្រាប់ពួកគេឱ្យមើលទៅទីឆ្ងាយ។ ដែលពេលពួកគេមើលទៅ ពួកគេឃើញថា តាមដែលពួកគេគិតទៅ មានមនុស្សបីបួននាក់កំពុងដើរចុះឡើងនៅក្នុងផ្នូរដែលនៅទីនោះ។ ដែលពួកគេសង្កេតឃើញថាមនុស្សទាំងនោះខ្វាក់ភ្នែក ដោយសារជួនកាល

ពួកគេជំពប់ដួលនៅលើផ្នូរ ហើយដោយសារតែពួកគេមិនអាចចេញរួចពីទីនោះផង។ បន្ទាប់មកគ្រីស្ទាននិយាយថា "តើនេះមិនន័យយ៉ាងណា?"

អ្នកគង្វាលក៏ឆ្លើយថា "តើអ្នកមិនបានឃើញថា នៅខាងក្រោមភ្នំទាំងនេះបន្តិច មានជណ្ដើរដែលនាំចូលទៅកាន់វាលស្មៅដែលនៅខាងឆ្វេងដៃ។" ចេញពីជណ្ដើរនោះមានផ្លូវដែលនាំតម្រង់ទៅវិមាននៃការសង្ស័យ ដែលត្រូវរក្សាដោយយក្សនៃសេចក្ដីអស់សង្ឃឹម ហើយមនុស្សទាំងនេះ (ចង្អុលទៅកាន់ពួកគេដែលនៅក្នុងកន្លែងផ្នូរ) ម្ដងនោះបានមកធ្វើធម្មយាត្រាដូចជាអ្នកធ្វើនេះដែរ រហូតមកដល់ជណ្ដើរនោះផង គឺដោយសារតែផ្លូវត្រូវនោះវាពិបាកនៅទីនោះ ពួកគេក៏ជ្រើសដើរចេញពីវាទៅកាន់វាលស្មៅ ហើយនៅទីនោះត្រូវយក្សនៃសេចក្ដីអស់សង្ឃឹមចាប់ ហើយបោះចូលទៅក្នុងវិមាននៃសេចក្ដីសង្ស័យ ជាកន្លែងដែលពួកគេត្រូវឃុំមួយរយៈនៅក្នុងគុកងងឹត យក្សក៏បានយកភ្នែករបស់ពួកគេចេញ ហើយឱ្យពួកគេដើរនៅក្នុងចំណោមផ្នូរខ្មោច ជាកន្លែងដែលគេទុកពួកនោះចោលឱ្យវង្វេងរហូតមកដល់សព្វថ្ងៃនេះ ដែលពាក្យរបស់អ្នកប្រាជ្ញមួយនឹងត្រូវសម្រេចបំពេញគឺ "អ្នកដែលវង្វេងចេញពីផ្លូវនៃការយល់ដឹង នឹងត្រូវនៅក្នុងក្រុមជំនុំរបស់មនុស្សស្លាប់។"

**"មនុស្សណាដែលវង្វេងចេញពីផ្លូវនៃប្រាជ្ញា នោះនឹងសម្រាកនៅក្នុងចំណោមមនុស្សស្លាប់ហើយ។" សុភាសិត 21:16**

បន្ទាប់មកគ្រីស្ទាននិងពេញដោយសង្ឃឹមសម្លឹងមើលគ្នាទៅវិញទៅមកជាមួយនឹងទឹកភ្នែកហូរចេញមកក្រៅ តែមិនបាននិយាយអ្វីទៅកាន់អ្នកគង្វាលឡើយ។

បន្ទាប់មកខ្ញុំឃើញនៅក្នុងសុបិនរបស់ខ្ញុំថា អ្នកគង្វាលនាំពួកគេទៅកន្លែងមួយទៀត នៅក្នុងបាត ដែលមានទ្វារមួយនៅម្ខាងនៃភ្នំ ហើយពួកគេបានបើកទ្វារ ហើយឱ្យពួកគេមើលទៅខាងក្នុង។ ដូច្នោះ ពួកគេបានមើលទៅក្នុងឃើញថាវាងងឹតនិងពេញដោយផ្សែងយ៉ាងខ្លាំង។ ហើយពួកគេគិតថាពួកគេបានឮសម្លេងនោះដូចជាសូរសន្ធឹកលាន់ដូចភ្លើង ហើយសម្លេងយំរបស់មនុស្សមួយចំនួនត្រូវធ្វើទារុណកម្ម ហើយពួកគេក៏ធំក្លិនស្ពាន់ធម៌។ បន្ទាប់មកគ្រីស្ទាននិយាយថា "តើនេះមានន័យយ៉ាងណា?" បន្ទាប់មកអ្នកគង្វាលប្រាប់ពួកគេថា "នេះជាផ្លូវនៅក្បែរទៅកាន់ស្ថាននរក ជាផ្លូវដែលមនុស្សកំពុតដើរ និយាយទៅកាលដែលពួកគេលក់សិទ្ធិជាកូនច្បងរបស់ពួកគេជាមួយអេសាវ ដូចដែលលក់ម្ចាស់របស់ពួកគេដែរជាមួយនឹងយូដាស ដូចជាការអង្គាប់ដល់ដំណឹងល្អជាមួយលោកអាឡិចសាន់ដឺ និងការកុហកនិងការលាក់បាំងជាមួយនឹងអាណានាសនិងសាហ្វីរ៉ាប្រពន្ធរបស់គាត់។

សង្ឃឹម៖ បន្ទាប់មកពេញដោយសង្ឃឹមនិយាយទៅកាន់អ្នកគង្វាលថា "ខ្ញុំយល់ឃើញថាការទាំងនេះកើតមានដល់ពួកគេ ដល់គ្រប់គ្នា ជាការបង្ហាញពីអ្នកធ្វើធម្មយាត្រា ដូចដែលយើងមានពេលនេះ តើពិតមែនទេ?"

គង្វាល៖ បាទ ហើយរក្សាវាទុកឱ្យបានយូរផង។

សង្ឃឹម៖ តើពួកគេនឹងទៅឆ្ងាយប៉ុណ្ណានៅក្នុងធម្មយាត្រានៅក្នុងគ្រារបស់ពួកគេនោះ ក្នុងកាលដែល ពួកគេត្រូវបានបោះចោលដោយវេទនាបែបនេះ?

គង្វាល៖ អ្នកខ្លះបានទៅឆ្ងាយទៀត ហើយខ្លះទៀតមិនបានមកដល់ភ្នំនេះផង។

បន្ទាប់មកអ្នកធ្វើធម្មយាត្រានិយាយគ្នាថា "យើងត្រូវការស្រេកឱ្យខ្លាំងរកកម្លាំងថែមទៀត។"

គង្វាល៖ អេ ហើយអ្នកនឹងត្រូវប្រើវានៅពេលដែលអ្នកមានវាដែរ។

មកដល់ពេលនេះអ្នកធ្វើធម្មយាត្រាមានបំណងចង់ទៅមុខ ហើយអ្នកគង្វាលចង់ឱ្យពួកគេទៅដែរ។ ដូច្នេះពួកគេបានដើរជាមួយគ្នាទៅកាន់ទីបំផុតនៃភ្នំ។ បន្ទាប់មកអ្នកគង្វាលនិយាយគ្នាថា "ចូរយើងបង្ហាញដល់អ្នកធ្វើធម្មយាត្រាពីទ្វារទៅកាន់ទីក្រុងស្ថានសួគ៌ ប្រសិនបើពួកគេចេះមើលឆ្លុះកញ្ចក់នៃទស្សនៈនេះ។" អ្នកធ្វើធម្មយាត្រាបានទទួលយកទង្វើនោះដោយសេចក្តីស្រឡាញ់ ដូច្នេះពួកគេត្រូវបាននាំទៅទៅកាន់កំពូលភ្នំមួយហៅថា "ច្បាស់លាស់" ហើយបានឱ្យកែវដល់ពួកគេមើល។ បន្ទាប់មកពួកគេសាកល្បងមើល តែការចង់ចាំនៃរឿងចុងក្រោយដែលអ្នកគង្វាលបានបង្ហាញដល់ពួកគេ ធ្វើឱ្យដៃរបស់ពួកគេញ័រ ដោយសារសេចក្តីកំសោយ ពួកគេមិនអាចមើលតាមកែវនោះឱ្យនឹងនរបានឡើយ។ តែពួកគេបានគិតថា ពួកគេបានឃើញអ្វីមួយដូចជាឃ្លោងទ្វារ ហើយសិរីល្អខ្លះនៃទីនោះ។ បន្ទាប់មកពួកគេក៏ចេញទៅ ហើយច្រៀងបទនេះថា

"ដូច្នេះដោយអាថ៌កំបាំងរបស់អ្នកគង្វាលត្រូវបានបង្ហាញមក ដែលជារឿងត្រូវបានរក្សាទុកមិនឲ្យមនុស្សផ្សេងទៀតដឹង។ ចូរមករកអ្នកគង្វាលមក

ប្រសិនបើអ្នកអាចឃើញការដែលជ្រៅ ការដែលលាក់កំបាំង ហើយការដែលសម្ងាត់ផង។″

នៅពេលដែលពួកគេជិតចាកចេញទៅ មានអ្នកគង្វាលម្នាក់បានឱ្យក្រដាស់កំណត់ផ្លូវដល់ពួកគេ ម្នាក់ទៀតប្រាប់ពួកគេឱ្យប្រយ័ត្ននឹងអ្នកដែលនិយាយបញ្ជោរ អ្នកទីបីប្រាប់ពួកគេឱ្យប្រយ័ត្នថាពួកគេនឹងមិនដេកនៅលើដីដែលត្រូវបានដាក់ស្នេហ៍ ហើយអ្នកទីបួនប្រាប់ពួកគេទៅរកព្រះ។ ដូច្នេះខ្ញុំក៏ភ្ញាក់ពីការយល់សប្តរបស់ខ្ញុំ។

*[The End of the Part 1 Volume I – 2]*